193+ 272,50-

លេខ ៣០ ខែ មេសា - ឧសភា - មិថុនា ព. ស. ២៥១២

Cs 86
1968

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

DU CAMBODGE
DEPOT LEGAL

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES

CENTRE DU CAMBODGE

AVRIL - MAI - JUIN 1968

N° 30

**Imprimerie HENRY**
93-97 PREAH BAT ANG ENG
PHNOM-PENH
CAMBODGE

# BORDEREAU

*des pièces adressées à* Monsieur le Conservateur de la BIBLIOTHEQUE NATIONALE à PHNOM PENH

*N°* 008/68

| SOMMAIRE DES PIÈCES | NOMBRE de pièces | OBSERVATIONS |
|---|---|---|
| - Revue trimestrielle "LA LUMIERE BOUDDHIQUE" N° 30 de 1968 ............ | 8ex. | Pour dépôt légal |

Reçu 1 pièce ci-dessus mentionnée

*Signé :*

Phnom-Penh, le 30 Août 1968

*Le Directeur,*

P.K - 36
1968 - 30

លេខ ៣០ ខែ មេសា - ឧសភា - មិថុនា ព. ស. ២៥១២

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម - មជ្ឈមណ្ឌលកម្ពុជរដ្ឋ

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES

CENTRE DU CAMBODGE

AVRIL - MAI - JUIN 1968

N° 30

ចាងហ្វាងនៃការផ្សាយ : អេង - សុត

បណ្ណាធិការ : នង - លន់

ទីសំណាក់ការបណ្ដោះអាសន្ន : វត្តឧណ្ណាលោម ភ្នំពេញ

Directeur de publication : ENG - SOTH

Gérant : NONG - LONN

Siège provisoire : Watt Unnalom Phnom-Penh

— CAMBODGE —

# ពន្លឺពុទ្ធចក្រ លេខ ៣០

| អត្ថបទ | មាតិការឿង | ទំព័រ |
|---|---|---|


១– *គារវបុគ្គល ១០ ចំពូក សម្ដេចព្រះសង្ឃរាជ* **ជ. ណ. ជោតញ្ញាណោ** ..... ១

២– *ពុទ្ធសាសនា ការល្បងពិចារណាឲ្យយល់ជាក់* សម្ដេចក្រុមព្រះ **សុីសុវត្ថិ-មុនីវង្ស** ២

៣– *ការស្រាវជ្រាវប្រវត្តិលោកវិសេសដូង* សហជីវិន **ឈឹម-ស៊ុម** ...... ១២

៤– " *សម្ដេចព្រះសុគន្ធាធិបតី* (ប៊ុម) សហជីវិន **អេង-សុត** ... ២២

៥– *ព្រះរាជក្រឹត្យលេខ ២១៤ន.ស. ចុះថ្ងៃទី ២៨-៨-៥០ ស្ដីពីការបង្កើតសាលាធម្មវិន័យ* ២៤

៦– *សេចក្ដីឆ្លើយតបទៅលោកគ្រូ* ណឹង-ហ្គាលី *កូវខានត្បូង* សហជីវិន **ស្វ-រំណោម** ២៩

៧– *អំពីការធ្វើឲ្យមានអាយុតិច និង អាយុច្រើន* ព្រះសាសនមុនី **ភឹម-តូវ** ..... ៣៣

៨– *សេចក្ដីព្យាយាម ភិក្ខុ* **ធាវ-ឆែស្មុក** សីលានន្ទ ............... ៤២

៩– *សកម្មភាពផ្សេង ៗ របស់គណៈកម្មាធិការនាយកនៃពុម្ពមក* ............... ៤៥

# គារវបុគ្គល ១០ ចំពូក

ពុទ្ធោ បច្ចេកពុទ្ធោ ច អរហា អគ្គសាវកោ
មាតា បិតា គរុ សត្ថា ទាយកោ ធម្មទេសកោ
បណ្ឌិតេហិ ឥមេ ទស ន ទុក្ខំតិ ជានិយា ។

ពាក្យកាព្យឲ្យស្មើនឹងគាថា ៖

## បទព្រហ្មគីតិ

ព្រះពុទ្ធព្រះបច្ចេក និងឯកអគ្គារហា អគ្គសាវកា និងមាតាបិតាផង ។ គ្រូនិងសាស្ត្រាចារ្យ និងទាយកឥតមោះហ្មង និងអ្នកទេស្នាផង កុំយង់ឃ្នងឆ្គងប្រមាថ ។ បុគ្គលទាំងដប់នេះ ប្រាជ្ញគួរពិះរេសម្អាត ត្រូវកុំបីប្រមាថ គួរឱហាតឲ្យចងចាំ ។ ថាមិនត្រូវប្រទូស្ត ឬរឹងរូសធ្វើឲ្យគ្គាំ – ឆ្គងខុសក្រែងនឹងនាំ – ឲ្យបានទុក្ខឃើញទាន់ភ្នែក ។

ខ្ញុំតែងពាក្យកាព្យនេះ ដោយរិះរេមិនរារែក មិនតែងចេញឲ្យប្លែក ពីគាថាបាលីឡើយ ។ អ្នកណាបានគោរព បុគ្គលដប់ពុំគោះតើយ តាមបែបខាងលើហើយ អ្នកនោះរែងជួបក្តីសុខ ។ មានរឿងតំណាលថា ពួកទេព្តានិរទុក្ខ ព្រះឥន្រ្ទជាប្រមុខ តែងសំពះទិសទាំងដប់ ។ គឺទិសទាំងប្រាំបី ទិសក្រោមលើដោយសព្វគ្រប់ លើកអម្រាមទាំងដប់ ប្រណម្យឆ្ពោះជននានា ។ ដែលគេបានប្រព្រឹត្ត សុចរិតឥតសង្កា ទោះនៅត្រង់ទីណា ក៏ដោយចុះឥតរើសមុខ ។ ថាសូមឲ្យជននោះ បានវរាតឃ្លាតចាកទុក្ខ តាំងពីនេះទៅមុខ សូមបានសុខអាយុវែង ។ ព្រោះហេតុនោះបានជា ព្រះសាស្តាទ្រង់សម្តែង ថាជនទាំងនោះឯង ទោះទេព្តាក៏រាប់អាន ។ ទេព្តាទាំងតូចធំ តែងបង្គំមករាល់ប្រាណ ឆ្ពោះជនទាំងប៉ុន្មាន ដែលបានកាន់សីលនិងធម៌ ។ ហេតុនេះសាធុជន កុំទំរន់គួរត្រេកអរ ឆ្ពោះធម៌ដ៏បវរ ដែលព្រះពុទ្ធទ្រង់សរសើរ ៕៚—

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃសុក្រ ទី ១៩ កក្កដា ព.ស. ២៥១២ គ.ស. ១៩៦៨

សម្តេចព្រះសង្ឃរាជ ជ. ណ. ជោតញ្ញាណោ

ប. អ. ស. – អ. ម. រ.

# ព្រះពុទ្ធសាសនា

## ការសាកល្បងពិចារណាឲ្យយល់ជាក់ (តនិងចប់)

និពន្ធដោយសម្តេចក្រុមព្រះ ស៊ីសុវត្ថិ - មុនីរ៉េត

## ភាវនា - សមាធិ

*ដើម្បីឲ្យបានសម្រេចនូវភាវនានិងបញ្ញា គួរតែពិចារណាឲ្យយល់ជាក់តាមគន្លងពុទ្ធសាសនាសិន ដូចម្តេចហៅថា ភាវនា ឬសមាធិ ?*

សមាធិ *តាមគន្លងពុទ្ធសាសនាដែលមានមនុស្សយល់ច្រឡំនោះ ដល់យកទៅប្រតិបត្តិក៏ខុសដែរ ។ មានជនបំពួកខ្លះជឿថា សមាធិជាវត្តទំនៀមទម្លាប់តាមបច្ចេកទេស ដោយគ្រាន់តែបរិកម្មនូវបូមន្តទាំងពួង, អុជទៀន, ធូប ហើយសូម្បីតែពុទ្ធបរិស័ទដែលជាឧបាសក - ឧបាសិកា និងបណ្តាភិក្ខុសង្ឃខ្លះទៀត ក៏មានការយល់ច្រឡំពីរឿងនេះដែរ ។ បុគ្គលពួកនេះ គិតតែពីសូត្រស្វាធ្យាយនូវធម៌ដែលរៀនចាំមាត់នាំឲ្យតែខូចពេលវេលា ហើយឥតបាននូវផលប្រយោជន៍អ្វីក្រៅពីនាំឲ្យកាន់តែចាំរត់មាត់នូវធម៌ដែលសូត្រនោះឡើយ ។ មានភិក្ខុសង្ឃខ្លះប្រព្រឹត្តកាន់តែគ្រោតគ្រាតថែមទៀត ។ មានមនុស្សម្នាក់ បាននាំរឿងមកតំណាលប្រាប់យើងដោយក្តីស្ញប់ស្ញែងរបស់ខ្លួនថា នៅកំពង់ស្ពឺមានភិក្ខុមួយអង្គប្រព្រឹត្តអាំងថ្ងៃក្តៅ ឬឆ្អើរភ្លើងពីក្រោមគ្រែ ។ ត្រង់នេះព្រះថេរៈនាមវលពោលរាហុល ក៏បានពោលឲ្យដឹងដែរថា នៅពេលថ្មីៗក្នុងប្រទេសឥណ្ឌា មានសាមណេរជាតិអង់គ្លេសមួយរូបខំព្យាយាមឲ្យបានដល់ទិព្វសោត ដោយខ្លួនលោកទើបនឹងសម្រេចបានដល់នូវទិព្វចក្ខុ ។ ព្រះថេរៈបានបន្ថែមសេចក្តីថា គំនិតបែបនេះ គ្រាន់តែជាចិត្តវិបល្លាសទេ គឺថាយោគាវចរបើតាមស្មាន មានគោលដៅចង់តែឲ្យបានសម្រេចនូវឫទ្ធិរបស់ចិត្ត ឬអាថ៌កំបាំងតែប៉ុណ្ណោះទេ ។*

*បើយ៉ាងនេះតើ ដូចម្តេចហៅថា ភាវនា តាមយោបល់របស់ព្រះថេរៈនាមវលពោលរាហុល ភាវនាតាមគន្លងនៃពុទ្ធសាសនា គឺជា* វប្បកម្ម *ឬការបណ្តុះបណ្តាលពត់ចិត្តនេះឯង ។ សមាធិមានគោលបំណងដើម្បីកម្ចាត់ចោលនូវគ្រឿងមន្ទិលសៅហ្មងពីខន្ធសន្តាន, កម្ចាត់ចោលនូវអាសវៈទាំងពួងដែលជាគ្រឿងធ្វើចិត្តឲ្យល្អក់ ដូចយ៉ាង* កាមតណ្ហា, បដិឃៈ, ព្យាបាទ, ថីនមិទ្ធៈ, ឧទ្ធច្ចៈ, កុក្កុច្ចៈ *និង* វិចិកិច្ឆា *ជាដើម ហើយចំរើនញ៉ាំងកុសលធម៌ឲ្យកើតមាន* សមាធិ, សតិ, បញ្ញា, ឆន្ទៈ, វីរិយៈ *ញាណជាគ្រឿងត្រិះរិះសេចក្តីទុកចិត្ត, សេចក្តីជ្រះថ្លាសប្បាយ ហើយនិងភាពស្ងប់ចាកអារម្មណ៍ ដើម្បី*

ជាគ្រឿងគោងទៅរកវិបស្សនាបញ្ញា ឲ្យបានឃើញច្បាស់ តាមសភាពពិតតាមសច្ចបរមត្ថកាត់កិលេសចូលកាន់ " ព្រះនិព្វាន " ។

## ការនាមានពីរប្រការគឺ

១– សមថ ឬ សមាធិ ជាគ្រឿងពត់ចិត្តឲ្យយាងចុះក្នុងសភាពស្ងប់ចាកអារម្មណ៍ទាំងពួងក្នុងការប្រតិបត្តិឲ្យនៅតែមួយ បិត្តេកគ្គតា ឬ ឯកគ្គតាចិត្ត ។ សមថៈនេះញាំងយោគាវចរឲ្យបានទៅដល់នូវអាចក៏បាំងជាន់ខ្ពស់ដែលជាផល ជាអរហត្តផលញាណ សំខតៈ ហើយឥតមានបច្ច័យទាក់ទងទៅនឹងការស្វែងរកអរិយសច្ច, និងសភាពពិតសោះឡើយ ។

ព្រះតថាគតបានទ្រង់បំពេញសមថកម្មដ្ឋាននេះតាំងពីមុនការត្រាស់ដឹងម៉្លេះ ហើយទ្រង់បានជ្រាបច្បាស់ថា សមថកម្មដ្ឋាន គ្រាន់តែជាដំណើរឲ្យរស់នៅដោយសុខសាន្តក្នុងបច្ចុប្បន្នជាតិតែប៉ុណ្ណោះ (ទិដ្ឋធម្ម - សុក្ខវិហារ) ។

២– វិបស្សនា ដែលព្រះអង្គមានបុណ្យបានទ្រង់រកឃើញនោះ ជាវិធីខាងបំបែកធាតុដោយផ្អែកទៅលើសតិ, សតិសម្បជញ្ញៈ, អប្បមាទ, អនុបស្សនា នេះជាការស្វែងរកឲ្យដឹងជាក់ពីធម្មជាតិតាមសភាពពិតនៃវត្ថុទាំងពួង ។

សមាធិបែបនេះ មានតែក្នុងពុទ្ធសាសនាទេ ។ ការនាមានមកស្រាប់ហើយនៅមុនពុទ្ធកាល តែថាជាផ្លូវពុំអាចនាំសត្វចេញចាកវដ្តសង្សារឡើយ ។ ផ្ទុយទៅវិញ សមាធិមានប្រយោជន៍ត្រឹមតែលើសកម្មភាពពល់ថ្ងៃរបស់យើង គឺជាសកម្មភាពដែលមានលាយចម្រុះដោយទុក្ខសោកនិងសេចក្តីសប្បាយលាយទៅដោយវាចានិងគំនិត លាយទៅដោយកិច្ចធុរៈខាងផ្លូវគំនិតនិងប្រាជ្ញារបស់យើង ។ សមាធិនេះមានសេចក្តីពន្យល់យ៉ាងពិស្តារក្នុងសតិបដ្ឋានសូត្រ គម្ពីរទីឃនិកាយ ដែលលោកចែកជាបួនផ្នែកដូចតទៅនេះ

ក· កាយានុបស្សនាសតិបដ្ឋាន ការរំពឹងពីរូបកាយ,

ខ- វេទនានុបស្សនាសតិបដ្ឋាន ការរំពឹងពីវេទនា,

គ- ចិត្តានុបស្សនាសតិបដ្ឋាន ការរំពឹងពីចិត្ត,

ឃ· ធម្មានុបស្សនាសតិបដ្ឋាន ការរំពឹងពីធម៌ ទុក្ខំ អនិច្ចំ អនត្តា ។

វត្ថុជាសារវន្ត ក្នុងវិបស្សនាទីមួយៗនៅត្រង់សតិ, សតិសម្បជញ្ញៈ, អនុបស្សនា នេះឯង

ព្រះភគវន្តសម្ពុទ្ធ បានត្រាស់សម្ដែងថា

មានតែផ្លូវមួយទេ ដែលនាំមនុស្សឲ្យទៅកាន់ទីរំលត់នូវអាសវក្កិលេស, ទៅកាន់ទីឈ្នះលើទុក្ខទុក្ខ ទោមនស្សទុក្ខ, ទៅកាន់ទីកម្ចាត់បំផ្លាញនូវទុក្ខក្នុងកាយនិងចិត្ត, ទៅកាន់អរិយមគ្គ, ទៅកាន់សិវដ្ឋាន ពោលគឺព្រះនិព្វានបាន នេះឯងជាអង្គបួនប្រការនៃសតិបដ្ឋាន ។

កាលបើយោគាវចរចម្រើនវិបស្សនាត្រូវប្រកបដោយវីរិយៈ, មនសិការៈ, តម្កល់សតិ, កម្ចាត់ចោល នូវរាគៈនិងបលិពោធក្នុងលោកចេញឲ្យអស់ ។ បើពោលម្យ៉ាងទៀតថា ត្រូវឲ្យមានឆន្ទៈ គឺពិចារណាពីកាយ, ពីវេទនា, ពីចិត្ត, និងពីធម៌មោះមុត ដោយជម្រុះចោលនូវរាគៈនិងបលិពោធ ដើម្បីញុំាងចិត្តឲ្យចុះស៊ប់ទៅក្នុងភាវនាកុំឲ្យងាករេបាន ទើបនឹងយល់ច្បាស់ពីធាតុក្ដីដែលកើតឡើង ព្រោះថាចិត្តរបស់មនុស្សនេះប្រាស់ប្រាលរបុលរប៉ូចណាស់មិននៅស្ងៀមទេ ដោយមានអារម្មណ៍ទីទៃមកជន្ទ ។ បើយ៉ាងនេះ យោគាវចរពុំអាចនឹងទាញចិត្តឲ្យស្ងប់ចុះតែក្នុងអារម្មណ៍មួយបានឡើយ ម៉្លោះហើយក៏មុខជានឹងបានលទ្ធផលថយវិញពុំខាន ។

ចូរយើងល្បងពិចារណាពីការងារដែលកំពុងជាប់ដៃធ្វើមកជាឧទាហរណ៍ចុះ ។ ក្នុងពេលត្រិះរិះនោះ កម្រមានមនុស្សដែលមិនងាកចិត្តទៅរកអារម្មណ៍ដទៃណាស់ តែថាបើយើងព្យាយាមទាញចិត្តរបស់យើងកុំឲ្យនឹកគិតទៅរកការណ៍ដទៃឲ្យនៅតែស្ងប់ចុះជាប់នឹងការងាររបស់យើងនោះ យើងមុខជានឹងបានសម្រេចមិនខាន ។ ក្នុងពេលនេះហើយដែលយើងផ្គង់ចិត្តរបស់យើងចំពោះតែការងារដែលកំពុងធ្វើ ឥតមាននឹកនាទៅរកទីដទៃ ។ ខណៈនោះ ការងាររបស់យើងហាក់ដូចជាងាយជាងគិតស្មាន ហើយការដោះស្រាយចំណោទ ក៏ហាក់ដូចជាធូរស្រួលដែរ ។ ដូច្នេះត្រូវតែផ្ដោតចិត្តទៅលើការងារកុំបីងាករេទៅរកទីដទៃឲ្យសោះ ។ ក្នុងពេលធ្វើសមាធិ យោគាវចរ ត្រូវកាន់យកនូវអាកប្បកិរិយាយ៉ាង-ណាមួយ ចំពោះរឿងនេះក្នុងសតិបដ្ឋាន មានសម្ដែងថា :

មានភិក្ខុមួយអង្គចូលទៅក្នុងព្រៃ ឬនៅក្រោមដើមឈើ ឬក៏នៅក្នុងកុដិដ៏ស្ងាត់ឆ្ងាយដាច់ស្រយាល ហើយពត់ភ្នែនតម្រង់ខ្លួនតម្កល់ស្មារតីសម្ពឹងចំទៅខាងមុខ ការចម្រើនភាវនានេះ ត្រូវរើសរកទីស្ងាត់, សុខសាន្ត, កុំឲ្យឮសូរស័ព្ទផ្សេង ៗ ។ លក្ខណៈនេះជាជំនួយសំខាន់ដល់ចិត្តក្នុងការប្រមូលអារម្មណ៍ឲ្យចុះស៊ប់ក្នុងកម្មដ្ឋានណាមួយ កុំឲ្យអណ្ដែតត្រសែតទៅកាន់អារម្មណ៍ដទៃ ដែលច្រើនតែចូលមកជន្ទ ៗ ត្រង់ដែលថាឲ្យពែនជើងនោះ ឥរិយាបថនេះពុំជាទីគាប់ចិត្តនៃមនុស្សគ្រប់រូបទេ ទាំងពុំមែនមានសារ

សំខាន់ណាស់ផងទៀត ។ ត្រង់ដែលសំខាន់នោះគឺ យោគាវចររើសយកឥរិយាបថណាមួយដែលងាយស្រួលដល់ខ្លួន ហើយតាំងសតិអារម្មណ៍ឲ្យស៊ប់ក្នុងកម្មដ្ឋាននោះទៅ តែថាការរឹងប្រឹងស្រាស់ត្រូវកុំឲ្យមានទាល់តែសោះ ។ ការចម្រើនកម្មដ្ឋានត្រូវធ្វើដោយឆ្មេចក្កក ផ្ចង់ចិត្តត្រង់ទៅរកចុងច្រមុះទើបប្រពៃ ។

រំពឹងពីកាយរបស់ខ្លួននោះគឺ ត្រូវឲ្យដឹងច្បាស់ថា កាយនេះប្រព្រឹត្តអ្វី, មានឥរិយាបថយ៉ាងណា, មានអ្វីខ្លះជាគ្រឿងផ្សំបង្កើត **បញ្ចក្ខន្ធ** ហើយថានឹងប្រែក្លាយទៅជាអ្វីក្នុងឥរិយាបថដូចជា ដកដង្ហើម, ទៅ, មក, ឈរ, អង្គុយ ។ យោគាវចរត្រូវពិចារណាឲ្យដឹងច្បាស់ថា ទីបំផុតនៃកាយនៅឯណា លុះដល់ខ្លួនស្លាប់ទៅសាច់ស្បែកនឹងទៅជាចំណីក្អែងទៅជាផេះ ឬជាចំណីនៃដង្កូវ មុននឹងនៅតែឆ្អឹងក្រាលលើធរណី ការចម្រើនកាយានុបស្សនាសតិបដ្ឋាននេះ បានត្រឹមតែកើតញាណទស្សនៈ គ្រាន់តែជាបរិវិតក្កតែប៉ុណ្ណោះទេ ។

រំពឹងពីវេទនា គឺឲ្យដឹងជាក់ថាអារម្មណ៍ទាំងពួងដែលមកប៉ះនឹងចិត្តទាំងខាងអាក្រក់, ទាំងខាងល្អ, ទាំងខាងមិនល្អ, មិនអាក្រក់នោះ ធ្វើចិត្តឲ្យស្លុះទៅយ៉ាងណា ឲ្យដឹងថាវេទនានីមួយៗដែលប៉ះត្រូវហើយ តើរលត់ទៅយ៉ាងណា? ការចម្រើនវេទនានុបស្សនាសតិបដ្ឋាននេះ គ្រាន់តែឲ្យកើតញាណទស្សនៈ គ្រាន់តែជាបរិវិតក្កប៉ុណ្ណោះទេ ។

រំពឹងពីចិត្ត គឺឲ្យដឹងថាធម្មជាតរបស់ចិត្តនេះដូចម្តេច ? ចេញផុតឬជាប់ចំពាក់នឹងកិលេស, ជាចិត្តឆាប់ខឹងឬស្លូតបូត, ជាចិត្តរាយមាយឬទេ, ជាចិត្តអោនជ្រប់ឬទេ, ជាចិត្តតូចឬមានទំហំ, ជាចិត្តខ្ពង់ខ្ពស់ឬទាបថោក, ជាចិត្តមូលក្នុងអារម្មណ៍ឬទេ ជាចិត្តរួចផុតឬនៅជាប់ចំពាក់ ចិត្តនេះកើតមានមកហើយរលត់ទៅយ៉ាងណា ? ។ ការចម្រើនចិត្តានុបស្សនាសតិបដ្ឋាននេះ គ្រាន់តែឲ្យកើតញាណទស្សនៈ, ឲ្យកើតបរិវិតក្កប៉ុណ្ណោះទេ ។

រំពឹងពីធម៌ ពីរឿងផ្សេងៗនេះ គឺឲ្យមានសម្បជញ្ញៈច្បាស់ពីអំពើដែលយោគាវចរប្រព្រឹត្ត, ពីអត្តភាពខាងកាយឬចិត្តរបស់ខ្លួន ។ ការរំពឹងពីធម្មានុបស្សនាសតិបដ្ឋាននេះ គ្រាន់តែឲ្យកើតញាណទស្សនៈ, គ្រាន់តែឲ្យកើតបរិវិតក្កប៉ុណ្ណោះទេ បទមាតិកាពីសមថៈនៅមានច្រើនទៀត ស្រេចហើយតែយោគាវចរ ចង់រើសយកបទណាមកចម្រើនក៏បានដែរ អ្នកចម្រើនកម្មដ្ឋានគប្បីភាវនាពីនីវរណធម៌ដូចខាងក្រោមនេះក៏បានគឺ

កាមច្ឆន្ទៈ ចិត្តជាប់ចំពាក់ក្នុងកាមទាំងពួង,

ព្យាបាទៈ ចិត្តប្រទូស្ត ស្អប់ខ្ញឹងច្រើន,

ថីនមិទ្ធៈ ចិត្តងោកងក់ ខ្ជិលច្រអូសទ្រមក់,

ឧទ្ធច្ចកុក្កុច្ចៈ ចិត្តរាយមាយ អណ្ដែតអណ្ដូង,

វិចិកិច្ឆា ចិត្តសង្ស័យ មិនដាច់ស្រេច ។

ចូរយើងល្បងលើកយកទោសចិត្តមកពិចារណា ។ ទោសចិត្តកើតឡើងពីបុព្វហេតុច្រើនប្រការណាស់ ធំក៏មាន តូចក៏មាន ។ កាលណាបើយើងបណ្ដោយតាមកំហឹងឲ្យទោសចិត្តគ្របសង្កត់បាន ហើយប្រតិកម្មដែលបង្កើតឡើង ច្រើនតែកម្រទំនប់បាន ហើយអាចទាញយើងឲ្យប្រព្រឹត្តអំពើដែលគិតមិនដល់ក្នុងពេលដែលយើងឥតមានទោសៈ ។ សូមសង្កេតមើលចុះ តើបទឧក្រិដ្ឋកើតដោយអំណាចទោសយ៉ាងណា ? បើដឹងហើយ តើត្រូវរម្ងាប់កំហឹងតាមបែបណា ?

ទោះបីកម្លាំងកំហឹងគ្របសង្កត់យ៉ាងណាក្ដី មនុស្សត្រូវតែបេះអត់ធ្មត់ទំមាត់សង្កត់ចិត្តរបស់ខ្លួនកុំគប្បីបណ្ដោយឲ្យវាជាន់លើបានឡើយ ។ កាលណាតែវាកើតមកភ្លាមត្រូវតែទប់សង្កត់យកឈ្នះវា, យកឈ្នះខ្លួនយើងឲ្យបានគឺថា កុំស្ដីនិយាយ, កុំធ្វើអ្វីៗប្រយ័ត្នកុំឲ្យវាដឹកទាញបាន ។ រួចហើយត្រូវត្រិះរិះពិចារណារកបុព្វហេតុនៃកំហឹងនោះ ដោយឆន្ទៈ ដោយការយល់ចិត្តច្វើម ដោយករុណា ។ ត្រូវ-តែកម្ចាត់កំហឹងដូចជាវត្ថុអ្វីមួយឥតប្រយោជន៍ ចង្រៃឧបទ្រពដល់ខ្លួនយើងជាមនុស្សដទៃ ។ កាលបើពិនិត្យពិចារណាដល់វិបាកជាមហន្តភយ ដែលកំហឹងអាចនឹងបង្កើតឡើង យើងនឹងឃើញថា គួរតែកុំបណ្ដោយចិត្តឲ្យទៅតាមកម្លាំងនៃកំហឹងដោយភ្លេចខ្លួននោះឡើយ ។ កាលណាបើយើងយល់ពីវិបាកនៃកំហឹងនេះច្បាស់ហើយនោះ យើងនឹងឈ្នះខ្លួនយើង ហើយឯផលអាក្រក់កើតពីកំហឹងនោះ ក៏នឹងថយចុះជាលំដាប់ទៅផងដែរ តទៅក៏នឹងលែងមានសោះតែម្ដង ។ ទាល់តែតាំងចិត្តបានយ៉ាងដូច្នេះ ទើបគេអាចបម្រើការងារបាន ដោយចិត្តស្អាតផូរផង់លែងមានភគតណ្ហា ។

អង្គនៃកម្មដ្ឋានទៅមានក្រៅពីនេះទៀត ដល់ទៅសែសិបប្រការតាមដែលមានពោលក្នុងអត្ថបទទាំងពួង ។ ក្នុងទីនេះ យើងយកមកពិចារណាខ្លះដូចតទៅនេះ

- ធម្មវិចយៈ ការស្រាវជ្រាវនិងការស្វែងរកនូវបណ្ហាទាំងពួងក្នុងធម៌ ។
- វីរិយៈ សេចក្ដីប្រឹងប្រែងក្នុងការងារដោយប្ដេជ្ញាថាឲ្យទាល់តែបានសម្រេចដូចប្រាថ្នា ។

**បីតិ** សេចក្ដីសប្បាយត្រេកអរចិត្តដែលជាគុណសម្បត្តិមួយផ្ដុំដោយនឹងសន្ទានចិត្តជាទុតិយដ្ឋិ, ជាចិត្តអស់អាប់កើតទុក្ខព្រួយ ។

— **បស្សទ្ធិ** ជាចិត្តទន់ភ្លន់មិនរឹងប្រឹងស្រាស់ គឺជាយោគាវចរត្រូវបន្ទន់កាយនិងចិត្តតាមករណី ។

— **ឧបេក្ខា** ចិត្តស្ងប់មិនរំភើបក្នុងវិបល្លាសផ្សេងៗដែលកើតឡើងក្នុងជីវិត ។

— **មេត្តាព្រហ្មវិហារ** ផ្សាយសេចក្ដីស្រឡាញ់លើមនុស្សសត្វទៅគតរើសមុខ ។

— **ករុណាព្រហ្មវិហារ** ។ល។

បើពោលដោយសង្ខេបទៅ ការបម្រើនភាវនានេះតាំងនៅលើ :

— ឆន្ទៈដ៏មុតមាំនិងការប្ដាក់ចិត្តយ៉ាងស្មោះ,

— សតិឬសតិសម្បជញ្ញៈ,

— រស់នៅតែក្នុងបច្ចុប្បន្ន តែជាដូច្នេះក៏ពុំមែនដល់ទៅប្រានចោលនូវគំនិតពីអតីត និងអនាគតនោះសោះទេ ឲ្យតែកាលទាំងពីរប្រការមានបច្ច័យទាក់ទងគ្នានឹងបច្ចុប្បន្ន ដែលជាជីវិតរស់នៅមែនៗនេះ ។

— បំភ្លេចចោលកុំនឹកនាដល់អំពើដែលប្រព្រឹត្តកន្លងទៅហើយ ។

— រស់នៅក្នុងអំពើដែលប្រព្រឹត្ត កុំគប្បីរស់នៅក្នុងចិត្តគិតនឹក ។

បរិយាយមកដល់ទីនេះ ឃើញថាជាទីបំផុតនៃបទវិចារណ៍របស់យើង ក្នុងការល្បងពិចារណាឲ្យយល់ពីពុទ្ធសាសនាហើយ ។ យើងយល់ឃើញថាមាគ៌ាដ៏ប្រពៃបានត្រាយនិងចង្អុលបង្ហាញលម្អដែរហើយ នៅតែត្រាច់ចរតាមមាគ៌ានេះ ដែលជាធុរកិច្ចនៃបុគ្គលមួយរូបៗនោះឯង ។

**អត្តាហិ អត្តនោ នាថោ**

ខ្លួនគប្បីជាទីពំនាក់របស់ផងខ្លួន ។

# BUDDHASĀSANĀ

## "ESSAI DE COMPREHENSION"

## PAR S. A. R. SAMDECH KROM PREAH SISOWATH MONIRETH

*(Suite et Fin)*

BHĀVANĀ.— La méditation.

Pour réaliser le Samadhi et le Paññā, il est bon de connaître ce que le Bouddhisme entend par Bhāvanā ou méditation.

La méditation bouddhique est aussi mal comprise et faussement mise en pratique. Certains croient que c'est un rituel technique consistant à réciter les formules, à brûler des bougies etc... etc... et des bouddhistes eux-mêmes et parmi eux des Bhikkhus, n'échappent pas à cette fausse croyance. Ils passent ainsi des heures à psalmodier les textes appris par cœur, perdant leur temps et n'ayant qu'un profit : retenir ces textes. Il y en a d'autres qui font pire, ainsi on nous a rapporté — avec accent d'admiration — qu'un bonze à Kg-Speu, se brûle à l'ardeur du soleil ou fait faire du feu sous son lit. Le vénérable Wépola Rahula a signalé "qu'il y a quelque temps, en Inde, il y avait une nonne bouddhiste anglaise qui s'efforçait de développer le pouvoir de voir par les oreilles, alors qu'elle était encore en possession d'une vision oculaire parfaite". Ces idées comme celle-ci, a-t-il ajouté, ne sont que "perversions mentales". Un tel but ne vise qu'à obtenir, s'imagine-t-on, des pouvoirs spirituels ou mystiques.

Que signifie donc Bhāvanā ?

Le Bhāvanā bouddhiste, selon le Vénérable Wépola Rahula, signifie "culture" ou "développement" mental. Il a pour but de "débarrasser l'esprit de ses impuretés, de ce qui le trouble comme les désirs sensuels, la haine, la malveillance, l'indolence, les tracas et agitations, les doutes; et à cultiver les qualités telles que la concentration, l'attention, l'intelligence, la volonté, l'énergie, la faculté d'analyser, la confiance, la joie, le calme conduisant finalement à la plus haute sagesse qui voit les choses telles qu'elles sont et qui atteint la Vérité Ultime, "le Nibbana".

Il y a deux formes de méditation :

1°).— Le Samatha ou Samādhi qui est le développement "de la concentration mentale, de la fixation unificatrice de l'esprit (Cittekaggata)". Il conduit les pratiquants aux "plus hauts états mystiques" qui sont des "productions, des créations mentales" (Samkhata), et qui n'ont aucun rapport avec la recherche bouddhique de la Vérité, de la Réalité. Le Bouddha l'a pratiquée avant son Eveil et a estimé que ce "n'est qu'une manière de demeurer heureux dans cette existence" (Ditthadhamma-Sukkhavihara).

2°).— Le Vipassanā qui est découvert par le Bienheureux, est "une méthode analytique basée sur l'attention, la prise de conscience, la vigilance, l'observation". C'est la recherche à voir réellement dans la nature des choses afin de comprendre clairement et pleinement comment elle est.

Cette méditation spécifiquement bouddhiste — le Samādhi existait déjà avant le Buddha — ne nous met pas hors de notre vie. Elle intéresse, au contraire, toutes nos activités journalières, "avec nos tristesses et nos joies, avec nos paroles et nos pensées, avec nos occupations morales et intellectuelles". Elle se trouve expliquée dans le Satipatthāna Sutta du Dīgha Nikaya qui contient quatre sections qui sont :

a).— Méditation sur notre corps—(Kāya).

b).— Méditation sur nos sensations—(Vedanā).

c).— Méditation sur notre esprit—(Citta).

d).— Méditation sur des sujets moraux et intellectuels—(Dhamma).

Dans chacune de ces formes de méditation, l'essentiel réside dans l'attention, la prise de conscience (Sata), l'observation (Anupassanā).

Le Bhagavat dit :

— "Il n'y a qu'un sentier qui conduit à la purification des êtres, à la conquête sur des douleurs et des peines, à la destruction des souffrances physiques et morales, à l'acquisition de la conduite droite, à la réalisation du Nibbāna. Ce sont les quatre sortes d'Etablissement de l'Attention".

C'est demeurer "énergique, compréhensif, et attentif, ayant rejeté les désirs et les soucis mondains", quand on observe son corps ou ses sensations ou son esprit ou les sujets différents. Autrement dit, avoir une volonté ferme en faisant abstraction des désirs et des soucis pour fixer son attention de façon soutenue sur l'objet de la méditation et pour comprendre toutes ses manifestations parce que l'esprit étant trop mobile et trop sollicité par d'autres idées et pensées, risque de ne pouvoir se concentrer sur cet objet. Sinon, le résultat final pourrait être négatif.

Prenons comme exemple : réfléchir sur ce que nous faisons. Ainsi, nous pensons à une affaire en cours. Il est extrêmement rare que nous ne soyons pas amenés ne même temps à penser à bien autres choses. Mais si nous exerçons notre volonté à river l'attention sur le sujet intéressé, nous parviendrons peu à peu à nous y consacrer entièrement. Alors, nous ne sommes plus que pour lui, lui seul nous préoccupe, plus rien ne viendra nous distraire. Le travail semble plus facile qu'il ne paraissait et les solutions aux problèmes posés se présentent plus aisément. Il faut faire corps avec ce que l'on fait sans autres préoccupations.

Quelle doit être l'attitude à prendre et à conserver durant la méditation ?

A ce sujet, dans le Satipatthāna, il est dit :

— "... Un moine étant allé dans la forêt ou au pied d'un arbre ou dans une maison isolée, s'assied, les jambes croisées, le corps droit, son attention fixée devant lui...". C'est avant tout choisir un endroit calme, tranquille avec le moins de bruit possible. Cette condition aide énormément à la concentration de l'esprit sur l'objet de la méditation et à lui éviter de s'égarer sur d'autres sujets qui peuvent le solliciter malgré les efforts faits. Les "jambes croisées" ne conviennent pas à tout le monde ; cette position n'est donc pas la principale. L'essentiel, cependant, est de choisir une position qui nous convient le mieux, la raideur en est exclue, et d'accorder la priorité absolue à l'attention. La concentration de celle-ci s'accomplit mieux avec les yeux fermés et le regard dirigé vers l'extrêmité du nez.

— "Méditer sur son corps c'est savoir exactement ce qu'il fait, quelle est sa position, de quoi est-il composé et comment il pourra devenir, comme respirer, aller, venir, debout, assis..., connaître quelle est la fin de ce corps qui, à la mort, sera réduit en cendres ou rongé par des vers avant de n'être que des os blanchis par le temps. Cette introspection est présente en le méditant seulement pour la connaissance, seulement pour la réflexion...".

— "Méditer sur les sensations, c'est savoir exactement ce qu'on ressent d'agréable, de désagréable ou de neutre ; savoir comment chaque sensation apparaît ou disparait. Cette introspection est seulement pour la connaissance, seulement pour la réflexion...".

— "Méditer sur l'esprit, c'est connaître exactement sa nature : libre ou non de passion, haineux ou sans haine, distrait ou non, recueilli ou non, grand ou sans grandeur, supérieur ou inférieur, concentré ou non, libéré ou non libéré, comment cet esprit apparait ou disparait. Cette introspection est seulement pour la connaissance, seulement pour la réflexion".

— "Méditer sur les sujets différents, c'est avoir conscience exacte de ce que l'on fait, de l'état physique ou mental dans lequel on se trouve... Cette introspection est seulement pour la connaissance, seulement pour la réflexion...".

La liste des méditations n'est pas limitative. Tous les sujets sont bons à méditer. Le choix nous appartient. On méditera avec fruit sur les cinq "empêchements" — Nivarana — que voici :

— les désirs sensuels – (kamacchanda),
– la malvaillance, la haine ou la colère — (Viyapada),
— la torpeur et la langueur — (ṭhina middha)
— l'excitation et les tracas — (uddhacca kukkucca),
— les doutes sceptiques — (vicikiccha).

Prenons en exemple la colère. Celle-ci nous arrive par de nombreuses causes plus ou moins grandes. Et quand nous sommes pris par elle, quand nous nous laissons dominer par elle, la réaction qu'elle provoque, est généralement difficile à contrôler et sera capable de vous amener à accomplir des actes impossibles à concevoir lorsque nous somme à l'état normal. Que de crimes n'ont-ils pas été commis sous l'empire de la colère ? De quelles manières alors la combattre ?

Quelle que soit l'acuité de la colère dont on est la victime à un moment donné, la première chose à faire est de ne jamais se prêter à être entrainé par elle. A son apparition, rester calme, se dominer, être maître de soi, ne rien dire, ne rien faire, éviter d'être emporté. Ensuite, chercher à en connaître la nature de la cause, par la volonté, par la compréhension, par la compassion. Eliminer cette colère comme une chose inutile et néfaste à soi-même plus qu'à autrui. Examiner les conséquences désastreuses qu'elle pourra provoquer et l'on verra combien elles ne méritent aucunement qu'on soit assez faible pour devenir son complice en faisant inconsciemment son jeu. Dès qu'on parviendra à comprendre, on se dominera et l'effet de la colère diminuera peu à peu pour ne plus subsister. C'est à ce point d'arrivée qu'on pourra formuler, dans la sérénité et avec un esprit dépouillé de passion, les jugements.

Il y a encore d'autres sujets de méditation qui sont au nombre de quarante selon les textes. Citons-en quelques-uns que voici :

— "L'investigation et la recherche concernant les divers problèmes sur la doctrine —Dhamma Vicaya.

— "L'énergie—Viriya—de travailler avec détermination jusqu'à ce que le but soit atteint.

— "La joie—Piti—qualité qui s'oppose absolument à une attitude d'esprit pessimiste, sombre ou mélancolique.

— "La détente—Passaddhi—du corps et de l'esprit ; on ne doit pas se raidir ni physiquement ni mentalement.

— L'équanimité—Upekkha—c'est-à-dire être capable de faire face, avec calme, sans en être troublé, à toutes les vicissitudes de la vie.

— "Etendre l'amour universel, illimité et bienveillance sur tous les êtres vivants sans discrimination—Metta.

— "La compassion—Karuna—etc. . . etc. . .

En résumé, l'exercice du Bhavana repose sur :

— la volonté et l'inclination sincères,

— l'attention ou la prise de conscience,

— vivre dans le présent, ce qui n'exclue pas de penser au passé et à l'avenir pourvu qu'ils aient toujours de rapport avec le présent qui est la vraie vie,

— s'oublier complètement et se perdre dans ce qu'on fait,

— vivre dans l'acte et non dans la pensée.

Nous parvenons au terme de notre essai de compréhension du Buddha Sāsanā. Nous nous permettons d'estimer que la Voie est tracée et montrée. Il ne reste plus qu'à l'emprunter et la suivre. C'est l'affaire de chacun...

**"ATTĀ HI ATTANO NĀTHO"**

Attanā va kataṃ pāpaṃ, attanā saṅkilissati;
attanā akataṃ pāpaṃ, attanā va visujjhati;
suddhi asuddhi paccattaṃ, nāñño aññaṃ visodhaye.

Par le soi le mal est fait,
par le soi on est souillé.

Par le soi le mal n'est pas fait,
par le soi on est purifié.

Pureté et impureté sont personnelles.
Personne ne peut purifier autrui.

DHAMMAPADA N° 165

# ការស្រាវជ្រាវប្រវត្តិលោកវិសេស ង៉ួង
## របស់បណ្ឌិតមហា ឈឹម - ស៊ុម អតីតសាស្ត្រាចារ្យ

## និទាន
## (INTRODUCTION)

(លោកវិសេស **ង៉ួង** ជាកវីឯកមួយរូបក្នុងរជ្ជកាលនៃព្រះបាទសម្ដេច **ព្រះនរោត្តម**) ។

ក្នុងកាល ព.ស. ២៤៥៨ គ.ស. ១៩១៥ ខ្ញុំ (ឈឹម ស៊ុម) មានអាយុ ១០ ឆ្នាំ កំពុងសិក្សានៅវត្តថ្មល់កា[1] ឃុំចសែត ស្រុកគងពិសី ខ្ញុំបានហាត់អានសាស្ត្រាល្បែងនិងច្បាប់ផ្សេងៗដ៏ច្រើន ។ បណ្ដាសាស្ត្រាល្បែងទាំងនោះ មានសាស្ត្រាល្បែងមួយខ្សែជាល្បើករបស់លោកតាវិសេស **ង៉ួង** ឈ្មោះសាស្ត្រា **សុវណ្ណពិលាប** ខ្លះហៅ **សាស្ត្រានននមាស** ។ តមកខ្ញុំហាត់អានសាស្ត្រាទេសន៍ រហូតដល់មហាជាតក៍ គឺមហាវេស្សន្តរជាតក ព្រមទាំងល្បើកដូដកដែលជាស្នាដៃរបស់លោកតាវិសេស **ង៉ួង** ដែរ ។ ទោះបីល្បើកទាំងនោះបាត់បង់អស់ ខ្ញុំស្រាវជ្រាវរកឯកសារពុំទាន់ឃើញ ក៏ខ្ញុំនៅចាំអាចសូត្រមាត់ទទេបានខ្លះ ។

តមក គ.ស. ១៩១៨ ខ្ញុំជាសាមណេរមានអាយុ ១៣ ឆ្នាំ ខ្ញុំមកនៅសិក្សាក្នុងសំណាក់លោកគ្រូអាចារ្យ **ពៅ - កន** អតីតចៅអធិការសឹកចេញពីវត្តហូរញ៉ៅ មកកលំនៅនាភូមិទួលខ្ពស់ (ឃុំវាល) ខាងជើងជិតវត្តអង្គទន្ទាប់ ហៅវត្តត្រពាំងឈ្មើង (កាលណោះវត្តនោះនៅក្នុងឃុំគរក្រស ឥឡូវបញ្ចូលទៅក្នុងឃុំព្រៃញាតិ ស្រុកគងពិសី) ជាវត្តដែលលោកតាអាចារ្យ **ង៉ួង** ធ្លាប់ជាចៅអធិការ ។ ទោះបីខ្ញុំជាសិស្សសិក្សាបាលី ប៉ុន្តែព្រោះហេតុលោកគ្រូខ្ញុំជាកវី ខ្ញុំក៏ស្ម័គ្រក្នុងការរៀនតែងកាព្យផង ។ លោកគ្រូខ្ញុំបានបង្ហាញឯកសាររបស់លោកតាអាចារ្យ **ង៉ួង** ខ្លះផង ទាំងកូនក្មួយលោកគ្រូខ្ញុំ ក៏ចាំកំណាព្យលោកតាអាចារ្យ **ង៉ួង** ច្រើនមេ ច្រើនគ្នាផង ទើបកំណាព្យកំប៉ុកកំប៉ុកទាំងនោះខ្លះ ធ្លងជាប់មកក្នុងសតិសម្បជញ្ញៈរបស់ខ្ញុំដល់សព្វថ្ងៃនេះ ដែលខ្ញុំនឹងសរសេរតទៅខាងចុង ។

តាំងពីខ្ញុំជាក្រុមជំនុំព្រះត្រៃបិដក គ.ស. ១៩៣៣ ជាសាស្ត្រាចារ្យបាលី គ.ស. ១៩៤២ ខ្ញុំចូលចិត្តតែងកាព្យក្នុងពេលទំនេរខ្លះៗ ជាហេតុបណ្ដាលឲ្យមនោសញ្ចេតនារបស់ខ្ញុំ ប្រវត្តទៅជាប់នឹងឧបការគុណរបស់លោកខាងលើនេះពុំសូវភ្លេច ។ លោកតាអាចារ្យ **ង៉ួង** ពុំមែនជាគ្រូផ្ទាល់របស់ខ្ញុំទេ,

---

១ វត្តថ្មល់កានេះ សម្ដេចព្រះសង្ឃរាជ ជ. ណ. ទ្រង់ប្រោសព្រះរាជទាននាមថ្មី ដើម្បីឲ្យស្របនឹងបាលីថា "វត្តធនសិរី" ដូច្នេះវិញពី គ.ស. ១៩៦៤ តាមនាមព្រះសកធន ដំកុកធំខ្ញុំជាអ្នកកវត្តនេះ ។ នៅទីមុខវត្តនេះ រដ្ឋាភិបាលបានបង្កើតមន្ទីរតំបន់រដ្ឋបាលមួយ ពីឆ្នាំ ១៩៦៥ ឥឡូវនេះ រដ្ឋាភិបាលកំពុងចាត់ការបង្កើតទៅជាសាលាស្រុក ។

ប៉ុន្តែខ្ញុំបានចំណេះពីលោក គឺឯកសារកំគាប់កំគោច ដែលសុទ្ធតែជាពាក្យកាព្យយកមកប្រៀបធៀបនឹងការបង្រៀនរបស់គ្រូខ្ញុំផង ។ ខ្ញុំតាំងលោកកង់ទឹកប៉ាំងមុខថា ជាគ្រូខ្ញុំដែរ ។ ខ្ញុំចង់សរសេរជីវប្រវត្តិរបស់លោកគ្រូអាចារ្យ ពៅ - កន គ្រូខ្ញុំយ៉ាងណា, ក៏ចង់សរសេរជីវប្រវត្តិរបស់លោកតាអាចារ្យ ដ៏ង យ៉ាងនោះដែរ, បានជាក្នុងកាល ព. ស. ២៤៩៩ គ. ស. ១៩៥៧ ខ្ញុំដឹងថាបព្វជិតមួយរូបព្រះនាម ដ៏ង - ភឿង ជាចៅបង្កើតរបស់លោកតាអាចារ្យ ដ៏ង បួសម្តងទៀតក្នុងគ្រាដែលខ្លួនចាស់ ក្នុងសំណាក់លោកគ្រូ កែវ - ឡុង ចៅអធិការវត្តលៃទពែន ដែលប្រែឈ្មោះតៗមក សព្វថ្ងៃហៅវត្តអគ្គព្រះពានខាងត្បូងមន្ទីរពេទ្យចម្រើនសុខភាព របស់សម្តេចព្រះសង្ឃរាជ ជំ. ណាត. ឃុំកោះកោះ ស្រុកគងពិសី ។ ខ្ញុំបានទៅដល់ទីនោះសួរផ្ចាល់លោកគ្រូ កែវ - ឡុង ដែលកើតទាន់លោកតាអាចារ្យ ដ៏ង ផង ផ្ចាល់លោកតា ដ៏ង - ភឿង ជាចៅបង្កើតរបស់លោកតាអាចារ្យ ដ៏ង ផង បានការខ្ទះយកមកសរសេរជាក់កន្ទាងដើមសៀវភៅទសជាតក៍របស់លោកគ្រូ អ៊ុ - បៅ ដែលខ្ញុំត្រូវបោះពុម្ពផ្សាយច្រើនដងមកហើយ ។

តមកនៅថ្ងៃ ៧ ។ ១០ ឆ្នាំម្សាញ់សប្តស័ក ព. ស. ២៥០៨ គ. ស. ១៩៦៥ ជាថ្ងៃភ្ជុំបិណ្ឌ ខ្ញុំត្រូវនាំគ្រួសារទៅរួមធ្វើបុណ្យភ្ជុំ បង្សុកូលឧទ្ទិសផលជូនលោកគ្រូព្រះសព ពៅ - កន នាវត្តហួរពៅព្រមទាំងចង់ស្រាវជ្រាវឲ្យជាក់ច្បាស់ នូវជីវប្រវត្តិលោកតាអាចារ្យដ៏ងផង ខ្ញុំក៏ចេញដំណើរពីភ្នំពេញតាំងពីព្រលឹមដល់វត្តហួរពៅ មុនអ្នកស្រុកដិតខាង, ខ្ញុំបានជួបនឹងចាស់ព្រឹទ្ធាចារ្យជាច្រើននាក់ ដែលខ្ញុំបានណាត់ពេលសុំជួប មាន :

១- លោកគ្រូបណ្ឌិតមហា គុប - កឹម[1] ព្រះជន្ម ៨៤ ឆ្នាំ (មហា ៤ ប្រយោគ កន្ទងជំនាន់ជាមួយនឹងសម្តេចព្រះសង្ឃរាជ) ដែលជាអតីតចៅអធិការសឹកចេញពីវត្តហួរពៅទៅនៅភូមិគ្រសាំងដីមៃ,

២- លោកតា មឿក - អួក នៅភូមិព្រៃទទឹង,

៣- លោកតា ទេស - ស៊ុម — ដ —

៤- លោកតា ឃួន — ដ —

៥- លោកតា មុី - សឿង នៅភូមិដើមរកាជាដើម ដែលសុទ្ធតែកើតទាន់លោកតាអាចារ្យដ៏ង ហើយស្គាល់ច្បាស់ព្រមទាំងចាំកំណាព្យខ្ទះរបស់លោកតាអាចារ្យ ដ៏ង ផង ។

---

១ លោកគ្រូមហា កឹម ជាសិស្សលោកគ្រូព្រះសព មឿង អតីតចៅអធិការវត្តហួរពៅ ។ លោកគ្រូ មឿង ជាសិស្សលោកតាអាចារ្យ ដ៏ង ។ លោកតែងប្រើលោកគ្រូមហា កឹម កាលជាយុវជនមានអាយុ ១២ ឆ្នាំដល់អាយុ ១៦ ឆ្នាំ ឲ្យយកអាហារចំណីអាហារស្ងោរទៅជូនលោកតាអាចារ្យដ៏ងប្អូនដប់ដងក្នុងខែនិមួយ ។ ។ ហេតុដូច្នេះ ទើបលោកគ្រូមហា កឹម នេះ បានជាអ្នកស្និទ្ធស្នាលចេញចូលក្នុងផ្ទះនៃលោកតាអាចារ្យដ៏ងដូចកូនក្នុងផ្ទះ ។

ខ្ញុំសួរចាស់ៗ ទាំងនេះមួយរយៈម្តងៗ ឲ្យស្មៀនខ្ញុំសរសេរតាមបានសេចក្តីដូចតទៅនេះ

## កំណើត និង ការសិក្សា

នៃ

# លោកតាអាចារ្យ ជួង

លោកតាអាចារ្យ**ជួង** ចាប់កំណើតក្នុងគ្រួសារអ្នកងារ មាតាបិតាមាននាមពុំប្រាកដ នាភូមិតាំងលប ឃុំព្រះនិព្វាន ស្រុកគងពិសី ជាប់ព្រំប្រទល់នឹងស្រុកកណ្ដាលស្ទឹង (ឆ្នាំកំណើតពុំប្រាកដ[១]) ។ លោកតាអាចារ្យជួងកាលឋិតនៅក្នុងបឋមវ័យជាកុមារ បានសិក្សាអក្សរភាសាខ្មែរ រហូតដល់បានផ្នួសជាបព្វជិត សិក្សាបាលីក្នុងវត្តព្រះនិព្វាន (ព្រះឧបជ្ឈាយាចារ្យរបស់លោកពុំប្រាកដជានាមអ្វី) ។ ក្នុងគ្រាដែលលោកជាភិក្ខុ បានចេញទៅសិក្សាបាលីក្នុងវត្តគុក មុខភ្នំព្រះរាជទ្រព្យ (ឧដុង្គ) ។ កាលនោះនៅក្នុងខេត្តសម្រោងទង ។

តាមប្រសាសន៍ចាស់ៗ ទាំងនោះថា លោកតាអាចារ្យ **ជួង** ធ្លាប់តំណាលប្រាប់គេរឿយៗ ថា លោកគ្រូព្រះមហារាជធម្ម **អ៊ុន** វត្តគុកកាចណាស់, មនុស្សម្នាម្នះរៀននឹងលោកពុំបានទេ, មានតែម៉ុកក្លែងទើបផ្គាប់ព្រះទ័យលោកគ្រូ ។ ថា : អម្បាលខ្ញុំជាមនុស្សរហ័សរហួនអាចទទួលបង្គាប់ប៉ុណ្ណោះហើយ ធ្វើរហូតប៉ុណ្ណោះបាន, ក៏នៅតែពុំសូវត្រូវព្រះទ័យលោកដែរ ។ ថា : លោកឲ្យរៀនប្រែបាលីមួយថ្ងៃមួយសន្លឹក, ខ្ញុំសុំរៀន៥សន្លឹកលោកពុំព្រម, ខ្ញុំទទូចសុំញឹកៗ លោកបែរជាថា គាត់ឯងរៀនមិនចេះទេ ។ ខ្ញុំអន់ចិត្តក៏លាលោកទៅស្រុកសៀម ។ លោកថា សៀមខ្មោចអី ! ។ ទោះបីលោកមិនអនុញ្ញាត ក៏ខ្ញុំអាងថាលាហើយ ក៏ចេញដំណើរទៅដល់បាត់ដំបង ខំរៀនសៀមផង ហាត់ទេសមហាជាតក៍ផង ។ ខ្ញុំឃើញគម្ពីរមហាជាតក៍ចេះតែស្ញើរចិត្ត បានជាខ្ញុំកែពាក្យក្នុងគម្ពីរមហាជាតក៍ច្រើនអន្លើៗ ។ លោកគ្រូមហាជាតក៍បន្ទោសខ្ញុំថា ម្ដេចក៏បំផ្លាញរបស់គេ ។ ខ្ញុំឆ្លើយថា មិនបំផ្លាញទេ, ជួយធ្វើឲ្យពីរោះទេតើ ។ លោកគ្រូមហាជាតក៍បោះគម្ពីរដែលខ្ញុំកែនោះឲ្យមកខ្ញុំ ។ ខ្ញុំនឹកតូចចិត្តក៏វេចគម្ពីរនោះ[២] លាលោកមកស្រុកវិញ (ដំណើរការណ៍ដែលចាស់ៗបានប្រាប់ខ្ញុំដូចខាងលើនេះ គួរឲ្យខ្ញុំយល់ថា

---

១ លោកគ្រូមហា កឹម ថា កាលលោកតាអាចារ្យជួងស្លាប់, ខ្លួនលោកមានអាយុ ១៦ ឆ្នាំ ត្រូវនឹង គ. ស. ១៨៩៧ ។ ថាលោកតាអាចារ្យជួង មានអាយុជាង ៩០ ឆ្នាំ ។ បើគិតអាយុ ៩០ គត់ឃើញថាកើតក្នុង គ. ស. ១៨០៧ ។ ២ គម្ពីរនេះ ដែលអ្នកគងពិសីហៅថា មហាជាតក៍លោកវិសេសជួង ។ មួយបែបទៀត គេហៅថា មហាជាតក៍ច្បាប់ហ្លួង ឬ មហាជាតក៍ព្រះអង្គឌួង ដែលលាយដោយពាក្យសៀមចម្រុះនឹងពាក្យខ្មែរ ។

លោកតាអាចារ្យ **ដួង** រៀនបាលីពុំទាន់មានការចេះច្រើនប៉ុន្មានទេ ហើយជាមនុស្សដែលពាក្យចាស់ថា លឿនហួសបន្ទោល ជាហេតុនាំឲ្យអនាគតរបស់ខ្លួនមិនបានលូតលាស់ល្អផង) ។

## ជីវភាពក្នុងភេទបព្វជ្ជា
នៃ
## លោកតាអាចារ្យ ដួង

ចាស់ៗទាំងនេះនិយាយប្រាប់ខ្ញុំតទៅទៀតថា លោកតាអាចារ្យដួង កាលត្រឡប់មកគង់នៅក្នុងវត្តព្រះនិព្វានវិញ មានកិត្តិស័ព្ទល្បីល្បាញខ្ទរខ្ទារពាសពេញទាំងខេត្ត ព្រោះហេតុលោកទេសន៍មហាជាតក៍ពីរោះណាស់ ហើយជាមនុស្សរហ័សមានប្រាជ្ញាវាងវៃ សម្តីរអិល ធ្វើការឥតខ្ជិល អាចបំពេញបំណងអ្នកត្រូវការបានភ្លាមៗ ។ មិនតែប៉ុណ្ណោះ ក្នុងវេលាដែលលោកចាស់ចិត្តចាស់គំនិតបន្តិចហើយ លោកបានរៀនព្រះកម្មដ្ឋានក្នុងវត្តព្រះនិព្វានថែមទៀត ។

មានវត្តមួយឈ្មោះវត្តអង្គទទាប់ ហៅត្រពាំងឈើង ខាងត្បូងវត្តព្រះនិព្វាន ខាងលិចភ្នំហូរពៅ លោកគ្រូចៅអធិការទទួលអនិច្ចធម្មទៅ នៅលោកតាចាស់មួយអង្គព្រះនាម **ហ៊ីង** ពិការជើងនិមន្តដើរពុំបាន ប៉ុន្តែមានចរិយាល្អ ក៏ភិក្ខុសាមណេរ ព្រមទាំងឧបាសក-សិកា ប្រគេននាទីជាចៅអធិការចំពោះលោកតា **ហ៊ីង** នេះ ។ លោកតាហ៊ីងពុំព្រមទទួល ទើបបបួលគ្នាទៅនិមន្តលោកគ្រូអាចារ្យ **ដួង** មកតាំងជាចៅអធិការ ។ លោកគ្រូអាចារ្យ **ដួង** បានឋាន ជាចៅអធិការ មានការគោរពចំពោះលោកតា **ហ៊ីង** ដូចគ្រូនិងសិស្ស ។ លោកគ្រូអាចារ្យ **ដួង** បានបំពេញបព្វជិតកិច្ចក្នុងឋានៈជាចៅអធិការ ព្រមទាំងបានបង្រៀនមហាជាតក៍និងព្រះកម្មដ្ឋានផង (ពុំដែលឮថាបង្រៀនបាលីទេ) ។

តមកលោកតា **ហ៊ីង** មានគាថាជូន សិស្សគណ ញាតិមិត្រខំព្យាបាលរោគរបស់លោកដោយវិធីផ្សេងៗ ។ លោកគ្រូអាចារ្យ **ដួង** បានតែងកំណាព្យមួយរឿងហៅថា **រឿងតាហ៊ីង** (ឥតមាននរណាចាំកំណាព្យនេះទេ, ទោះបីខ្ញុំស្រាវជ្រាវរក ក៏ពុំឃើញឯកសារនោះសោះ, ប៉ុន្តែអ្នកធ្លាប់អានកំណាព្យនោះ ចាំសេចក្ដីបានខ្លះ) ។

ក្នុងគ្រាព្យាបាលរោគនៃលោកតា **ហ៊ីង** មានបុរសម្នាក់ឈ្មោះស់ នៅភ្នំជីសូរ[1] ជាសិស្សលោកតា

---

១ ភ្នំនេះអ្នកខ្លះហៅភ្នំព្រះឥសូរ នៅស្រុកសម្រោង ខេត្តតាកែវសព្វថ្ងៃ មានព្រះវិហារព្រះពុទ្ធសាសនាពីបុរាណមកដល់សព្វថ្ងៃ ។ អ្នកខេត្តនានានៃកម្ពុជាធ្លាប់តែងកាត់ទៅបន់ស្រន់ដោយជំនឿថា មានព្រះពុទ្ធរូបស័ក្តិសិទ្ធិក្នុងទីនោះ ។

ហ៊ីង បាននាំលោកទៅព្យាបាលពេតនាកុំដីស្វរនោះ ។ គ្រូពេទ្យឈ្មោះ **សុខ** ជាអ្នកមើលជំងឺ ។

លោកគ្រូអាចារ្យដួង តាមទៅបម្រើលោកតាហ៊ីង លើកំពូលភ្នំដីស្វរអស់វេលាជាង ១ ខែ ។ ព្រោះហេតុទីនោះជាកន្លែងស្ងាត់ លោកមានក្តីអផ្សុកព្រោះទំនេរ ដួនជាបានឃើញសត្វអកទាំងគូនៅលើភ្នំដីស្វរមានកូនខ្ចី ទើបលោកប្រតិដ្ឋរឿងអកនោះ តែងជាកាព្យបានមួយរឿងទៀត ឲ្យឈ្មោះថា **ល្បើកអក**[១] ។

លុះលោកតាហ៊ីង បានជាចាកពេតហើយ លោកគ្រូរឮប់មកកាន់វត្តត្រពាំងឈើងវិញទាំងអស់អង្គ ។ លោកគង់នៅជាមួយគ្នាមិនយូរប៉ុន្មាន ក៏អ្នកពប់អានលោកតាហ៊ីង កវត្តមួយទៀតឲ្យឈ្មោះថា **វត្តអង្គព្រះស្រី** (សម្ដីអ្នកស្រុកហៅវត្តអង្គកាដន់) ក្នុងឃុំព្រៃញាតិ ខាងត្បូងជិតវត្តត្រពាំងឈើងនោះ ហើយគេនិមន្តលោកតាហ៊ីង មកទទួលនាទីជាចៅអធិការ ។ វត្តអង្គព្រះស្រីនេះ តអំពីលោកតាហ៊ីង មកមានចៅអធិការ ៤ តំណមកដល់ ព. ស. ២៥០៩ គ. ស. ១៩៦៧នេះ គឺលោកគ្រូ **អ៊ូ, យក់, អ៊ុម** និងលោកគ្រូ **ប៉ាន់** ចៅអធិការសព្វថ្ងៃ ។

ក្រោយពេលដែលលោកតាហ៊ីងបែកទៅនៅវត្តថ្មី លោកគ្រូអាចារ្យដួង ក៏លាចាកសិក្ខាបទដែរ ។ ទៅរៀបអាពាហ៍ពិពាហ៍ជាមួយនឹងសិកាម្នាក់ឈ្មោះ **មាស** នៅភូមិដំដែក ឃុំជាមួយគ្នា ខាងលិចជិតវត្តទាំងពីរនោះ ។

❉

❉ ❉

## ជីវភាពក្នុងភេទជាគ្រហស្ថ
## នៃ
# លោកតាអាចារ្យ ដួង

លោកតាអាចារ្យ ដួង និងឧបាសិកា មាស ចាប់ដៃគ្នាកសាងគ្រួសារតាំងដើមរហូតដល់ទីបំផុតបាន កូនប្រុសម្នាក់ឈ្មោះ **ស្វាយ** កូនស្រីម្នាក់ឈ្មោះ **ម៉ិញ** ។ លោកជាកសិករប្រកបរបរកសិកម្មផង ធ្វើភ្ជួមឆ្នាំងផង តាមសញ្ញាតិជាខ្មែរអ្នកងារពលព្រះ[២] ។ ក្នុងពេលឱកាសមួយខែពីរខែនៃឆ្នាំនីមួយ ៗ

---

១ តាមប្រកពវត្តលែនពែន លោកគ្រូ កៅ - ឡាង និងលោកតា ផ្វង - ភឿង ថា មុនល្បើកអកនេះ លោកគ្រូអាចារ្យដួង បានតែងរឿងសេកសារិកាមួយដែរ ដែលយើងស្គាល់ថា រឿងសេកសារិកានេះ អ្នកនិពន្ធធ្វើតាមរឿងមហោសថ ដោយការដកស្រង់ ។ ២ ក្នុងកម្ពុជរដ្ឋយើង ពីសម័យបុរាណមកទល់នឹងរជ្ជកាលនៃព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ គេចែកវណ្ណៈមនុស្សដូចប្រទេសឥណ្ឌាដែរ គឺក្សត្រ (ស្ដេច), ព្រាហ្មណ៍ (ចារ្យ ឬ បុរោហិត), វេស្សៈ ឬ វៃស្យៈ (អ្នកព្រៃងារ), សូទ្រៈ (អ្នកងារ) ។ អ្នកងារនេះឯងជាវណ្ណៈទាបបំផុត សម្រាប់តែរាជការហៅមកប្រើតាមមុខការផ្សេង ៗ ដែលចែកជាក្រុមដោយរួបរួមថា ពលព្រះ (អ្នកងារសម្រាប់តែធ្វើព្រះស្រែ គឺស្រែដែលហ្លួងដាក់ថ្វាយព្រះសម្រាប់វត្ត), ពលអង្គរក្ស (អ្នកងារដែលគេប្រើជាទាហានរក្សាព្រះអង្គស្ដេច), ពលទ្រមាក់ (អ្នកងាររក្សាដំរីព្រះរាជទ្រព្យ), ពលចៅ (អ្នកងារសម្រាប់ចៅព្រះទីនាំងនាវា), ពលតុន (អ្នកងារសម្រាប់ចូលតុន ផាល់ ចំបាប់ ថ្វាយព្រះមហាក្សត្រទត) ។ ហៅកាត់ថា ពលព្រះ, — អង្គរក្ស, — ទ្រមាក់, — ចៅ, — តុន ។

លោកតែងបង្រៀនទេសន៍មហាជាតក៍ផង បង្រៀនព្រះកម្មដ្ឋានផង ។

លោកតាអាចារ្យជួង មានការមមាញឹកជានិច្ច ព្រោះមានករណីយកិច្ច មិនត្រឹមតែជួបថ្លែងខាងលើនេះប៉ុណ្ណោះទេ ថែមទាំងមានការទទួលភ្ញៀវញឹកញាប់ណាស់ផង ។ ចាស់ៗបានតំណាលប្រាប់ខ្ញុំថា ភ្ញៀវច្រើនប្រភេទ គឺព្រះសង្ឃនិងអ្នកធម៌អាថ៌តែងចូលទៅរកលោក ដើម្បីការសន្ទនាអំពីសេចក្ដីប្រព្រឹត្ត, គ្រហស្ថ ក្មេងកម្លោះតែងចូលទៅរកដែរ ដើម្បីលំហែសេចក្ដីទុក្ខព្រួយក្នុងរឿងស្នេហា គឺកម្លោះដែលមានទុក្ខព្រោះគេមិនឲ្យកូនក្រមុំជាដើម តែងទៅថ្លែងទុក្ខជម្រាបលោក ។ លោកស្ដាប់សេចក្ដីថ្លែងទុក្ខបណ្ដើរ ចាស៊ីករិតបណ្ដើរ ធ្វើកាព្យតាមដំណើរនៃសេចក្ដីទុក្ខនោះ ឲ្យដល់អ្នកកើតទុក្ខនោះបានភ្លាមៗ ។ ហេតុដូច្នេះបានជាអត្ថបទដែលលោកតាអាចារ្យជួងតែង គេឃើញច្រើនតែកំណាព្យស្នេហា ហើយជាអត្ថបទខ្លីៗ ដូចខ្ញុំនឹងសរសេរតទៅខាងចុងនេះខ្លះ ។

ករណីយកិច្ចដូចថ្លែងមកនេះ ជាការចិញ្ចឹមជីវិតរបស់លោកតាអាចារ្យជួង ព្រោះមនុស្សជំនាន់នោះ ទោះបីមិនសូវប្រើប្រាក់កាសជាគ្រឿងឈ្នួលក៏មែនពិត, ប៉ុន្តែគេដឹងគុណរបស់អ្នកធ្វើប្រយោជន៍ឲ្យគេណាស់ គេតែងផ្ដល់ជូនលោកតាំងពីអាហារភោជន សំពត់អាវស្លៀកពាក់ រហូតដល់កម្លាំងជួយធ្វើការផ្សេងៗផង ។ មិនត្រឹមតែគ្រហស្ថទេ សូម្បីបព្វជិត ក៏ជួយផ្គត់ផ្គង់ជីវភាពនៃលោកតានេះដែរ ។

លោកតាអាចារ្យជួង មានសម្បុរសជ្រះ មាឌតូចស្ដើង ខ្ពស់ស្រឡះ សម្ដីរហ័ស សំឡេងស្រួយ មានគេស្រឡាញ់គោរពរាប់អានច្រើន ទោះបីក្នុងជំនាន់នោះ ខ្វរកំពុងប្រកាន់វណ្ណៈ គឺអ្នកព្រៃងារពុំព្រមចងពន្ធរៀបអាពាហ៍ពិពាហ៍នឹងអ្នកងារសោះ សូម្បីត្រឹមតែបរិភោគអាហារ ក៏មិនបរិភោគក្នុងវង់ជាមួយគ្នាផង ម្ដេចគង់រូបលោកតាអាចារ្យជួង គេបំភ្លេចលែងគិតថា លោកជាអ្នកងារ ។ ដូចឧទាហរណ៍តទៅនេះ

១- លោកតាអាចារ្យជួង មានកូនស្រីម្នាក់ឈ្មោះមុញ ជាស្រីក្រមុំធម្មតា មិនស្អាតល្អជាងគេណាស់ទេ ថែមទាំងកើតក្នុងត្រកូលអ្នកងារផង ។ មានមាណពម្នាក់ឈ្មោះ**នាង** នៅឃុំសែនជ័ (សព្វថ្ងៃក្នុងស្រុកសម្រោងទង) កូនអ្នកព្រៃងារ ព្រមព្រៀងជាមួយនឹងមាតាបិតា បានចូលមកស្ដីដណ្ដឹងនាងមុញ ។ លោកតាអាចារ្យជួង ពុំព្រមឲ្យ ដោយការអាងថាខុសប្រពៃណី ដូចជាគេទឹមរទេះដោយគោម្ខាង ក្របីម្ខាង ។ អ្នកកម្លោះឈ្មោះនាង មិនព្រមថយឬឈប់ ព្រោះងប់ជាប់ចិត្តនឹងកេរ្ដិ៍ឈ្មោះរបស់លោកតាអាចារ្យជួង ។ អ្នកកម្លោះ នាង ស៊ូត្រាំខំបម្រើលោកតាអាចារ្យជួង អស់វេលា

៤ឆ្នាំ សុខចិត្តលាជាតិចេញពីអ្នកព្រៃងារ ចូលសញ្ជាតិជាអ្នកងារ តាមលោកតាអាចារ្យដួងវិញ ទើបលោកព្រមឲ្យរៀបអាពាហ៍ពិពាហ៍ ។

២– ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ដែលទ្រង់កំពុងសព្វព្រះរាជហឫទ័យនឹងលោកសុន្ទរវោហារ ម៉ុក (កែង) ទ្រង់ជ្រាបថា លោកម៉ុកនេះមានដៃគូម្នាក់ទៀតឈ្មោះ ដួង[1] ។ ទ្រង់ឲ្យអញ្ជើញលោកតាអាចារ្យដួង មកគាល់ក្នុងព្រះបរមរាជវាំងចតុមុខ ទ្រង់ពិសោធដោយការសន្ទនាផ្ទាល់ព្រះអង្គផង ឲ្យសរសេរជាលាយលក្ខណ៍អក្សរផង ទ្រង់សព្វព្រះរាជហឫទ័យ ទើបទ្រង់ព្រះរាជទានផ្ទាល់ព្រះឱស្ឋនូវឋានៈជាមន្ត្រីស័ក្តិ ៥ ហ៊ូពាន់ មានងារជា "ហ្លួងវិសេសអក្ខរាដួង" ។

លោកតាអាចារ្យដួង មានកិត្តិយសសំខាន់ណាស់ ប្លែកពីមន្ត្រីឯទៀត, ប៉ុន្តែព្រោះហេតុតែលោកជាមនុស្សរហ័សពេក, លោកឆ្លើយទាស់ព្រះរាជឱង្ការថា បើព្រះករុណាទ្រង់ព្រះមេត្តាប្រោសដួង សូមទ្រង់ព្រះមេត្តាអ្នកងារឯទៀតផង គឺសូមឲ្យអ្នកងារទាំងអស់បានរួចខ្លួនជាព្រៃងារ ទើបទូលព្រះបង្គំព្រមទទួលយកកិត្តិយសដ៏ខ្ពង់ខ្ពស់នេះ[2] ។ ការនេះពុំបានសម្រេច ។ លោកតាអាចារ្យដួងបានងារថា "ហ្លួងវិសេសអក្ខរា" ត្រឹមតែព្រះរាជឱង្ការផ្ទាល់ព្រះឱស្ឋប៉ុណ្ណោះ ពុំបានប្រកាសនីយបត្រត្រាតាំងពេញលក្ខណៈជាមន្ត្រីទេ ។ តមកទើបអ្នកងាររួចជាព្រៃងារទាំងអស់គ្នាក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ប្រហែលជាដោយហេតុដែលលោកតាអាចារ្យដួងសុំនោះទេដឹង ? ។

## ស្នាដៃក្នុងការនិពន្ធ
នៃ
# លោកតាអាចារ្យ ដួង

អ្នកនិពន្ធនេះ បានសរសេរជាក់ស្តែងនូវអត្ថបទដូចតទៅនេះ

១– ល្បើករឿងតាហ៊ុង

២– រឿងសេកសារិកា

៣– សាស្ត្រានេនមាស ឬ សុវណ្ណពិលាប

---

១ លោកតាអាចារ្យដួង ចាស់ជាងលោកសុន្ទរវោហារម៉ុក ប្រហែល ៣០ ឆ្នាំ ព្រោះគ្រាដែលព្រះករុណាទ្រង់ប្រទានងារនោះ លោកតាដួងមានអាយុជិត ៧០ ឆ្នាំហើយ ។ ២ សម្តីលោកតាអាចារ្យដួងត្រង់នេះ សឲ្យឃើញទឹកចិត្តរបស់លោកថាជាអ្នកសង្គ្រោះញាតិ ដែលពុទ្ធភាសិតថា ញាតកានញ្ច សង្គហោ ។ ឬបើនិយាយតាមពាក្យសាមញ្ញថា អ្នកស្នេហាជាតិ ដែលជាគំរូមួយដ៏ល្អ សម្រាប់បច្ឆាជនជាន់ក្រោយ យកតម្រាប់តាម ។

៤– សាស្ត្រាផ្អូកផ្គរ ឬ ផ្គរផ្ដាំក្ដាមខ្លួន (ខ្សែ)

៥– ល្បើកអក

៦– ល្បើកដុច

៧– ច្បាប់ទុនអគ្គ

៨– ស័ព្ទផ្គរ

៩– គម្ពីរមហាជាតក៍ (វេស្សន្តរជាតក ដែលលោកកែរបស់គេស្រាប់)

១០– ល្បើកជូជក

១១– កំណាព្យកំប៉ុកកំប៉ុកផ្សេង ៗ ច្រើន ដែលលោកតែងឡើងតាមសេចក្ដីថ្លែងទុក្ខរបស់អ្នកសុំ ។

## សេចក្ដីបញ្ជាក់

ក– ល្បើករឿងតាហ៊ឹង : កំណាព្យនេះ ខ្ញុំពុំដែលឃើញ ថែមទាំងស្រាវជ្រាវរកតៗមក ក៏ពុំឃើញទៀត, ប៉ុន្តែចាស់ៗ ដូចមានទាមខាងដើមនេះប្រាប់ខ្ញុំថា លោកគ្រូអាចារ្យដួង កាលទើបនឹងទទួលឋានៈជាចៅអធិការវត្តអង្គទម្រាប់ បានទៅជាមួយគ្នានឹងលោកតាហ៊ឹងនេះ ដែលចាស់ស្បាជាង ហើយដែលមានសេចក្ដីស្រឡាញ់និងសេចក្ដីគោរពចំពោះលោកគ្រូអាចារ្យដួងផង ។ ពុំដឹងជានៅជាមួយគ្នាបានប៉ុន្មានឆ្នាំ ទើបលោកគ្រូអាចារ្យដួងតែងកាព្យនេះឡើង ក្នុងគ្រាដែលលោកតាហ៊ឹងមានអាពាធធ្ងន់ ។ កាព្យនេះចាស់ៗទាំងឡាយ បាននិយាយប្រាប់ខ្ញុំថាមើលទៅគួរឲ្យអស់សំណើចព្រោះ

១– ផ្ដើមនិយាយពីសង្ខារគាត់តែងមនុស្សលោកមិនឲ្យដូចគ្នា ។ រយៈដំបូងនេះមានសេចក្ដីជាសម្មោកចំលើរូបកងកាយលោកតាហ៊ឹង ដែលពិកពិការ ។

២– និយាយពីសណ្ឋានទ្រង់ទ្រាយ និងអាការៈពិកពិការនៃលោកតាហ៊ឹង ។

៣– និយាយពីអាការពេគនៃលោកតាហ៊ឹង ។

៤– និយាយពីកិរិយាខ្វល់ខ្វាយក្នុងការព្យាបាលពេគ គឺអ្នកខ្លះរកហោរទាយ, អ្នកខ្លះបន់ព្រះសំពះអ្នកតា, អ្នកខ្លះរកគ្រូហ្សុំផ្ញាំសង្កែ, អ្នកខ្លះបញ្ជូនអារក្ស ។ អ្នកភ្លេងលេងអស់ភ្លេងអារក្សមិនចូល ។ ក្នុងការព្យាបាលនេះមានមនុស្សប៉ុន្មាននាក់ អ្នកណាធ្វើអ្វីដោយអាការយ៉ាងណា, នោះសុទ្ធតែមានឈ្មោះចុះជាប់ក្នុងកំណាព្យនោះទាំងអស់ ។

**យោបល់ខ្ញុំ** ខ្ញុំយល់ថា លោកគ្រូអាចារ្យជួង ជាអ្នកប្រាជ្ញខាងកាព្យឃ្លោងសម្បូណ៌វោហារចង់ថាយ៉ាងណាបានយ៉ាងនោះភ្លាមៗ គួរឲ្យកោតសរសើរមែនហើយ, ប៉ុន្តែរឿងនេះ បើពិតដូច្នេះមែន, ខ្ញុំថាកវីរូបនេះសម្បូណ៌ប្រាជ្ញាក្នុងការតែងកាព្យ តែខ្វះសម្បជញ្ញៈ, សម្បូណ៌គំនិតក្នុងបច្ចុប្បន្ន តែខ្វះគំនិតអនាគត ។ នរណាក៏ដោយ បើមានចរិយាបែបនេះ, នោះនឹងធ្វើការពុំសូវបានសម្រេចផលល្អទេ ។

សូមទោស ! លោកតាហ៊ឹងជាមនុស្សចាស់មានគេគប់អានច្រើនណាស់ ហើយថែមទាំងស្រឡាញ់ព្រមទាំងគុំគម្កើងលោកគ្រូអាចារ្យជួងផង ។ គួរបើអីលោកគ្រូអាចារ្យជួងហ៊ានតែងកាព្យជាគ្រឿងដំបូចសើចលេងឲ្យប៉ះពាល់លើពងកាយពិកពិការរបស់លោកតាហ៊ឹង ដែលកំពុងមានអាពាធធ្ងន់ធ្ងរនោះយ៉ាងហ្នឹង ។ នេះមិនមែនចរិយារបស់អ្នកប្រាជ្ញទេ ។ ប្រហែលជាកាព្យហ្នឹងទេដឹង ដែលនាំឲ្យបរិស័ទលោកតាហ៊ឹងបែកចិត្តនាំគ្នាកសាងវត្តអង្គកាដន៍មួយទៀត និមន្តលោកតាហ៊ឹងទៅគង់ជាចៅអធិការក្នុងគ្រាដែលលោកតាហ៊ឹង ជាចាកពេគាពាធហើយ ត្រឡប់ពីក្នុំដីសូរមកវិញ ។

**ខ– រឿងសេកសារិកា** រឿងនេះក៏ជាពាក្យកាព្យដែរ ជាស៊ុំករឹតក៏មាន ជាសៀវភៅបោះពុម្ពក៏មាន, ប៉ុន្តែគ្មាននាមអ្នកនិពន្ធ ។ លោកគ្រូ **កែវ-ឡាង** ចៅអធិការវត្តអង្គព្រះពាន (**លែនពែន**) និងលោកតា **ជួង-ភឿង** បានសរសេរឲ្យការខ្ញុំថា ជាស្នាដៃរបស់លោកគ្រូអាចារ្យជួងដែរ, ប៉ុន្តែពុំដឹងជាតែងក្នុងទីណាឆ្នាំណាទេ ។ ស្មានថា រឿងសេកសារិកានេះប្រហែលជាលោកតែងក្នុងគ្រាដែលទើបនឹងត្រឡប់ពីបាត់ដំបងមកគង់វត្តព្រះនិព្វានវិញ ។

រឿងសេកសារិកានេះមានដើមថា

នេះនឹងថ្លាថ្លែងចែងចារចង　　　លើកតាមទំនងល្បងកាព្យា  
ប្រាំពីរពាក្យពិតគិតបួនឃ្លា　　　ហៅថាមួយបេះរះសេចក្ដី ។  
និទានថាមានសេកសោមសត្វ　　　ប្រាជ្ញប្រាយស្រាយកាត់ការអ្វីៗ  
ព័ណ៌បែតងស្រស់ខិមប្រិមខ្ចី　　　សម្ដីពីរោះក្បោះវាចា ។  
ជាសេកមហោសថពោធិសត្វ　　　នៅក្នុងនគរវេជ្ឈមិថិលា  
ឯស្ដេចសោយរាជ្យទ្រង់នាមថា　　　មហាវិទេហរាស្ត្រវ័ន្ទី[១] ។ល។

---

១ រឿងនេះព្រះអង្គម្ចាស់ នរោត្តម - ភាណុវង្ស បានចាត់ឲ្យផ្ទៀងផ្ទាត់ពាក្យខ្លះហើយបោះពុម្ពក្នុងរោងពុម្ពកម្ពុជវរោភាស ហើយតមក បានជាការផ្សាយរបស់បណ្ណាគារ គីម-សេង ។

រឿងនេះអ្នកនិពន្ធតែងតាមមហោសថជាតកដែលរាប់បញ្ចូលក្នុងទសជាតក៍ ដោយការដកស្រង់យកតែត្រង់រឿងសេកសោមបណ្ឌិត របស់ព្រះមហោសថមកបញ្ចូលសេចក្ដីថែម ឲ្យទៅជាកំណាព្យស្នេហា ។

រឿងនេះនៅក្នុងការសង្ស័យខ្លះរបស់ខ្ញុំ ព្រោះខ្ញុំបានចម្លើយមកថាជារបស់លោកគ្រូអាចារ្យដួង ត្រឹមតែពីប្រកពវត្ដិលេនពៃនមួយប៉ុណ្ណោះ ។ ប៉ុន្ដែខ្ញុំមានជំនឿខ្លះថា ប្រហែលពិតមែន ព្រោះមានបំណុចពីរដែលគួរឲ្យជឿគឺ

១– លោកគ្រូអាចារ្យដួង មានសញ្ជាតិជាអ្នកងារ ។ ក្នុងគ្រានោះគេមិនព្រមឲ្យអ្នកងាររៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកក្រៅងារទេ ។ ប្រហែលលោកគ្រូអាចារ្យដួង ចង់ឲ្យសាធារណជនដឹងថាតាមធម្មជាតិ គ្មានអ្វីជំទាស់ក្នុងរឿងអាពាហ៍ពិពាហ៍នេះទេ, អម្បាលសត្វសេកអាចយកសត្វសារិកាជាប្រពន្ធបាន, តាបសតស៊ីជាតិជាមនុស្ស អាចដាក់សីលផ្នួសយកសត្វកិន្នរីជាប្រពន្ធបាន ដូចមានសេចក្ដីក្នុងរឿងសេកសារិកានោះសព្វគ្រប់ ។

២– ប្រកពវត្ដិលេនពៃន បានឲ្យការថា រឿងនេះលោកតាអាចារ្យដួង តែងក្នុងគ្រាដែលទើបត្រឡប់ពីបាត់ដំបងមកគង់ក្នុងវត្តព្រះនិព្វានវិញ ។ ពាក្យនេះសមគ្នានឹងពាក្យក្នុងរឿងនោះថា

« នេះនឹងថ្វាថ្លែងថែងចារចង លើកតាមទំនងល្បងកាព្យ »

បានសេចក្ដីថា កំណាព្យរឿងសេកសារិកានេះ លោកលើកតាមទំនងដែលមានមកពីបុរាណ ហើយជាការលើកសាកល្បងមុនដំបូងបំផុត ។

(មានតទៅទៀត)

# ប្រវត្តិសម្ដេចព្រះសុគន្ធាធិបតី ប៉ិម

សម្ដេចព្រះសុគន្ធាធិបតី ប៉ិម[១] គង់នៅវត្តស្បែង ព្រះជន្ម៩៤ឆ្នាំ ទ្រង់ជរាពាធជាទម្ងន់ ។ ព្រះបាទសម្ដេចព្រះនារាយណ៍រាជាជាអម្ចាស់ ទ្រង់ជ្រាបអាការរោគ ស្ដេចក៏ទ្រង់នាំព្រះអគ្គមហេសី ព្រះស្នំ ស្រឹង្គារ មួយអន្លើដោយសេនាបតី មន្ត្រីអ្នករាជការ ជាយសបរិវារហែហមព្រះរាជដំណើរចេញពីព្រះពន្លាព្រែកពាក់ព្រ័ត្រ មកបង្គំសួរអាការរោគនៃសម្ដេចព្រះសុគន្ធាធិបតី ប៉ិម នៅវត្តស្បែង ជិតព្រះបរមរាជវាំងឧដុង្គ ទ្រង់ទតឃើញអាការរោគនោះធ្ងន់ណាស់, ទ្រង់មានព្រះរាជហឫទ័យស្នេហា-អាណិតសម្ដេចព្រះសុគន្ធាធិបតីនោះក្រៃពេក, ទ្រង់មានព្រះបន្ទូលថា ញោមឃើញអាការរោគព្រះជិតុនវេលានេះ កើតធម្មសង្វេគពន់ប្រមាណ, ញោមគ្មានព្រះរាជបុត្រនឹងគ្រប់គ្រងព្រះរាជធានីតំណព្រះយុវវង្ស បើគ្មានក្សត្រនឹងសោយរាជសម្បត្តិទេ ព្រះនគរនឹងសូន្យមិនខាន, ខ្ញុំព្រះករុណាសូមនិមន្តព្រះជិតុនឲ្យមេត្តាចាប់បដិសន្ធិនឹងញោមចុះ នឹងបានជួយទំនុកបម្រុងព្រះនគរ, ព្រះពុទ្ធសា-សនា និងថ្កុំថ្កើងរុងរឿងតរៀងទៅ ។

សម្ដេចព្រះសុគន្ធាធិបតី ថ្វាយព្រះពរថា ព្រះមហាបពិត្រ អាត្មាភាពទទួលតាមព្រះរាជនិមន្ត តែពុំចម្រើនវែងឆ្ងាយទេ គ្រាន់តែជាភារៈព្រះមហាបពិត្របន្តិចបាន ។

សម្ដេចព្រះនារាយណ៍រាជា ទ្រង់មានព្រះតម្រាស់ថា បណ្ដាព្រះមហេសីទាំងឡាយ, ព្រះស្នំ ឬព្រះម្នាងទាំងប៉ុន្មាន, បើព្រះជិតុនសព្វព្រះទ័យនឹងឈ្មោះណា សូមមេត្តាចាប់បដិសន្ធិនឹងមហេសីនឹងស្នំនោះចុះ ។ សម្ដេចព្រះសុគន្ធាធិបតី ទ្រង់ឲ្យប្រជុំព្រះមហេសី ព្រះស្នំ ព្រះម្នាងមកជួបជុំទតទាំងអស់ ទ្រង់សព្វព្រះទ័យតែនឹងអ្នកម្នាង **ជែក** វែងម្នាក់ ដោយទ្រង់យល់ថា អ្នកម្នាងតូច ទើបតែនឹងថ្វាយខ្លួន ហើយស្ដេចពុំសូវសព្វព្រះទ័យប្រោសប្រណីផង ទ្រង់មានព្រះទ័យអនុគ្រោះឲ្យមានកេរ្តិ៍ឈ្មោះខ្ពស់រុងរឿង ក៏ថ្វាយព្រះពរថា អាត្មាភាពនឹងអនុគ្រោះអ្នកម្នាងម្នាក់ដែលអង្គុយក្រោយគេបំផុតនោះ, សូមព្រះរាជទានស្ដេចត្រឡប់ទៅព្រះរាជវាំងវិញចុះ ។ ព្រះបាទសម្ដេចព្រះបរមបពិត្រទ្រង់យល់អធ្យាស្រ័យក៏ថ្វាយបង្គំលាឡើងគង់រាជរថចូលព្រះបរមរាជវាំងវិញ ដោយត្រាស់ឲ្យអ្នកម្នាង **ជែ**កវែងជិះកន្ទ្រៀព្រះរាជរថជាមួយ ។ ក្រោយនោះ, សម្ដេចព្រះសុគន្ធាធិបតី ប៉ិម ជ្រាបច្បាស់ថា សង្ខារនឹងបែកធ្លាយ ទើបទ្រង់រំលឹកនូវអនុស្សតិ មានពុទ្ធានុស្សតិជាដើមខ្ជាប់ក្នុងព្រះទ័យ ស្ងប់ចុះក្នុងឈានលោកិយជាអារម្មណ៍, ទ្រង់រំលត់សង្ខារសុគត; ដោយអំណាចបុញ្ញាភិសង្ខារ ក៏បណ្ដាលឲ្យ

---

១ ព្រះសុគន្ធាធិបតីព្រះនាម ប៉ិម នេះ មានឫសគល់ដូងកែវកំណើត គឺថាព្រះអង្គមានព្រះមាតាបិតានាមអ្វី ? មានកំណើតនៅភូមិស្រុកណា ? មានប្រវត្តិរបស់ព្រះអង្គពីកុមារយ៉ាងណា ? នោះគ្មានអ្នកណាដឹងឮឡើយ ។ ប្រវត្តិសាស្ត្រ ក៏មិនឃើញមានកត់ត្រាយ៉ាងណាផងដែរ ។

ព្រុស្ញូវព្ជង៍អាកាសវេហាស៍ លាន់ព្រឺទ្ឋីដូចរន្ទះអសនីបាតទាំង៨ទិស, ព្រះរាជរថដែលស្ដេចគង់ប្រថាប់នោះបណ្ដាលហេតុជាអស្ចារ្យណាស់ រញ្ជួយញាប់ញ័រហាក់ទឹងក្ដុក ៗ លុះស្ដេចយាងដល់ព្រះពន្ធនាព្រែកពាក់ព្រ័ត្រហើយ, មន្ត្រីបានចូលក្រាបបង្គំគាល់ថ្វាយពត៌មានថា សម្ដេចព្រះសុគន្ធាធិបតីទ្រង់សុគតហើយ ៗ សម្ដេចព្រះបរមបពិត្រ ដោយមានមន្ត្រីជាបរិពារហែហមព្រះដំណើរផង បានស្ដេចយាងដល់វត្តស្បែង, ទ្រង់ស្រោចស្រង់ព្រះសពដោយរសសុគន្ធវារីរួចស្រេច ស្ដេចនិមន្តព្រះសពតម្កល់ក្នុងព្រះហិន ត្រាស់បង្គាប់ឲ្យតម្កល់ក្នុងសាលាវត្តស្បែង ឲ្យបាត់ព្រះសង្ឃជាសត្ថីវិហារិក និងជាអន្តេវាសិកនៅថែទាំរក្សាព្រះសពដោយគួរសិន ដ្បិតព្រះនគរពុំទាន់រាបទាប រួចស្ដេចក៏យាងត្រឡប់ទៅព្រះពន្ធនាព្រែកពាក់ព្រ័ត្រវិញ ៗ

រីឯអ្នកម្នាង ជៃ កវែងនោះវិញក្ដី, នាកាលសម្ដេចព្រះបរមបពិត្រទ្រង់ប្រោសប្រាណ ព្រះបរមរាជានុញ្ញាតឲ្យចូលគាល់បម្រើនែបនិត្យជិតព្រះអង្គជាប្រក្រតីរៀងមក, កន្លងបានប្រមាណ ១ ខែ អ្នកម្នាងក៏ទ្រង់គភ៌; ព្រះរាជាទ្រង់ជ្រាបដំណើរនេះ ក៏ទ្រង់រឹតតែប្រោសប្រណីទ្រទ្រង់ថែមទៀត, ទ្រង់តាំងជាស្នំឯក មានចាស់ទុំ ជំទាវ ខុណ្ណាងចូលមកប្រចាំការរក្សាគភ៌ ជាវេនវៀងរាល់ថ្ងៃគ្រប់ពេលវេលា ដោយទ្រង់ជ្រាបថា សម្ដេចព្រះសុគន្ធាធិបតី **ប៊ុម** លោកមកចាប់បដិសន្ធិ ៗ

ចំណែកអ្នកម្នាង **ជៃ** ជាព្រះស្នំឯក កាលទ្រង់គភ៌គ្រប់មាសាហើយ គឺនៅថ្ងៃ ១៥ ៦ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៣១៦ គ.ស. ១៧៧៣ វេលាបច្ចូសសម័យ ទ្រង់ក៏សម្ភពព្រះរាជបុត្រាមួយព្រះអង្គ បង្កើតជាអច្ឆរិយៈនាផ្ទៃអាកាសព្រុស្ញូវខ្ញូរខ្ញារដូចជារន្ទះ ៗ ខណៈនោះសម្ដេចព្រះវររាជបិតា ទ្រង់មានព្រះទ័យត្រេកអរណាស់ ដោយទ្រង់ជ្រាបថា សម្ដេចព្រះសុគន្ធាធិបតី **ប៊ុម** មកចាប់បដិសន្ធិ ទ្រង់ប្រោសប្រទាននាមថា **ព្រះអង្គអេង**, ឯព្រែកពាក់ព្រ័ត្រនោះ ទ្រង់ប្រែនាមឲ្យហៅថា **ព្រែកមានលាភ** វិញ ព្រះស្ដេចបានព្រះរាជបុត្រានៅទីនោះ ៗ ដល់ឆ្នាំមមីឆស័ក ស្ដេចព្រមដោយព្រះអគ្គមហេសី ព្រះម្នាង ព្រះស្នំ ស្រីស្ដារ សេនាបតី នាម៉ឺនសព្វមុខមន្ត្រី ហែស្ដេចយាងចេញពីព្រែកមានលាភ ទៅគង់ឯព្រះរាជវាំងក័កនៅកោះចិន ៗ

ចម្លងចាកព្រះរាជពង្សាវតារ សាស្ត្រាស្លឹករឹត ពីជ ៥៥ ទៅ ជ ៦២

រអ៊ប - សុត ចាងហ្វាងខាងផ្នែកអាផ្ចា

នៅសាលាវិនិច្ឆ័យ ភ្នំពេញ

លេខ ២១៤ ន.ស.

# ព្រះរាជក្រឹត្យ

ព្រះបាទសម្ដេចព្រះនរោត្ដម-សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅអាណាចក្រ កម្ពុជា ជាអម្ចាស់ជីវិតលើត្បូង ។

បានទ្រង់យល់ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ កម្ពុជា ។

បានទ្រង់យល់ សន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី ៨ វិច្ឆិកា ១៩៤៩ ។

បានទ្រង់យល់ព្រះរាជប្រកាសលេខ ១២ ចុះថ្ងៃទី ៩ កុម្ភៈ គ. ស. ១៩៤៣ ស្ដីពីការរៀបចំកិច្ចសាសនា ក្នុងព្រះរាជាណាចក្រ ។

បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ១៣៨ ន. ស. ចុះថ្ងៃទី ២៧ ខែតុលា គ. ស. ១៩៤៧ ស្ដីពីការរៀបចំមន្ទីរស្ដីការ រដ្ឋមន្ត្រីក្រសួងធម្មការ សាសនសិក្សាធិការ និងសិល្បការ ។

បានទ្រង់យល់យោបល់ព្រះសង្ឃនាយកទាំងពីរគណៈ និងយោបល់សម្ដេចព្រះធម្មលិខិត ជាទីឧត្តមប្រឹក្សាគណៈមហានិកាយ ។

តាមសេចក្ដីស្នើសុំ រដ្ឋមន្ត្រីក្រសួងធម្មការ និងសិល្បការ ។

គណៈរដ្ឋមន្ត្រីបានយល់ព្រមផង ។

## ត្រាស់បង្គាប់ដូចមានខាងក្រោមនេះ

អំពីបង្កើតសាលា "ធម្មវិន័យ" នៅគ្រប់វត្តក្នុងព្រះរាជាណាចក្រ សម្រាប់បង្រៀនធម្មវិន័យ ។

## ចំពូក ១

## អំពីសាលានិងរបៀបបង្រៀនក្នុងសាសា

ប្រការ ១– នៅគ្រប់វត្តក្នុងព្រះរាជាណាចក្រ ត្រូវបង្កើតសាលារៀន ហៅថាសាលា "ធម្មវិន័យ" សម្រាប់បង្រៀន ធម្មវិន័យ ។ សាលានេះនឹងអនុញ្ញាតឲ្យទទួលបង្រៀនតែភិក្ខុនិងសាមណេរ ការកសាងសាលានេះ ការថែទាំនិងសម្ភារកិច្ចទាំងប៉ុន្មាន ត្រូវនៅលើបន្ទុកវត្តទីទៃ ។

ប្រការ ២– សាលា ធម្មវិន័យ ត្រូវអនុញ្ញាតឲ្យបង្កើតតាមប្រកាសក្រសួង រដ្ឋមន្ត្រីក្រសួងធម្មការ តាមពាក្យសុំលោកចៅអធិការវត្ត ក្រោយដែលមានយោបល់យល់ព្រមពីអនុគណ, មេគណ, ចៅហ្វាយស្រុក និងចៅហ្វាយខេត្ត ។ ចំណែកខាងគណៈធម្មយុត្តិ ពាក្យសុំត្រូវជូនតាមរយៈចៅហ្វាយស្រុក ទៅចៅហ្វាយខេត្ត ជូនតទៅរដ្ឋមន្ត្រីក្រសួងធម្មការ ព្រមទាំងយោបល់របស់ខ្លួន ។

ប្រការ ៣– សាលា ធម្មវិន័យ ត្រូវមានបីថ្នាក់ ដូចមានខាងក្រោម

ក- ឆ្នាំរៀនទី ១ ថ្នាក់ទី ៣

ខ- ឆ្នាំរៀនទី ២ ថ្នាក់ទី ២

គ- ឆ្នាំរៀនទី ៣ ថ្នាក់ទី ១

កម្មវិធីបង្រៀន ព្រមទាំងកាលបរិច្ឆេទចូលរៀន និងវិស្សមកាល ត្រូវមានកម្រិតតាមប្រកាសក្រសួងរដ្ឋមន្ត្រីក្រសួងធម្មការ ។

ប្រការ ៤– មេរៀនទាំង ២ មុខគឺ ធម្មវិន័យ ពុទ្ធប្បវត្តិនិងសេចក្តីអធិប្បាយសុភាសិត ត្រូវមានរៀនដូចគ្នាទាំង ៣ ថ្នាក់ ប៉ុន្តែវិញ្ញាសាប្រឡងមានខុសគ្នា តាំងពីថ្នាក់ក្រោមឡើងទៅ ។

ប្រការ ៥– ភិក្ខុ ឬសាមណេរ នៅវត្តណាដែលមានសាលា ធម្មវិន័យ ត្រូវតែរៀន ធម្មវិន័យ ខានមិនបាន លើកលែងតែបព្វជិតនោះមានជន្មាយុចាស់ពេក ។

## ចំពូក ២

## អំពីប្រឡង

ប្រការ ៦– ដល់ចុងឆ្នាំសិក្សា សិស្សទាំងឡាយក្នុងថ្នាក់នីមួយៗត្រូវប្រឡង ។ បេក្ខជនស្វែរិនគេខ ឧបាសកនឹងអនុញ្ញាតឲ្យប្រឡងជាមួយនឹងកូនសិស្សបាន ។ រដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវរើសវិញ្ញាសាដាក់ឲ្យប្រឡងដោយការស្ទាត់កំបាំង ។ វិញ្ញាសានេះ ត្រូវធ្វើជាប្រយោគសរសេរទាំងអស់ ។

ប្រការ ៧– ការប្រឡងត្រូវធ្វើនៅភ្នំពេញនៅវត្តធំៗ បើនៅខេត្តក្រៅ ត្រូវប្រឡងនៅវត្តដែលជាទីសំណាក់លោកមេគណ និងអនុគណ ។

ប្រការ ៨– មេប្រយោគត្រូវតាំងតាមប្រកាសក្រសួងរដ្ឋមន្ត្រី ក្រសួងធម្មការ ក្រោយដែលបានពិគ្រោះជាមួយនឹងសម្តេចព្រះសង្ឃនាយកទាំង ២ គណៈ ។

ប្រការ ៩– បេក្ខជនដែលប្រឡងជាប់លេខ ត្រូវទទួលវិញ្ញាបនប័ត្រដូចមានកាយឈ្មោះតទៅនេះ

### ឆ្នាំ ទី ១

ចំណែកសិស្សត្រូវបានវិញ្ញាបនប័ត្រ ធម្មវិន័យ ឈ្មោះ **ធម្មកោសល - ត្រី** ។

ចំណែកឧបាសកត្រូវបានវិញ្ញាបនប័ត្រធម្មសិក្សា ឈ្មោះ **ធម្មវិទូ - ត្រី** ។

## ឆ្នាំ ទី ២

ចំណែកសិស្សត្រូវបានវិញ្ញាបនប័ត្រ ធម្មវិន័យ ឈ្មោះ **ធម្មកោសល - ទោ** ។

ចំណែកឧបាសក —ដ— ធម្មសិក្សា ឈ្មោះ **ធម្មវិទូ - ទោ** ។

## ឆ្នាំ ទី ៣

ចំណែកសិស្សត្រូវបានវិញ្ញាបនប័ត្រ ធម្មវិន័យ ឈ្មោះ **ធម្មកោសល - ឯក** ។

ចំណែកឧបាសក —ដ— ធម្មសិក្សា ឈ្មោះ **ធម្មវិទូ - ឯក** ។

ប្រការ ១០— វិញ្ញាបនប័ត្រមានគំរូដូចៗគ្នា ទំហំប៉ុនគ្នា ប៉ុន្តែពណ៌ខុសគ្នា ។

ប្រការ ១១— វិញ្ញាបនប័ត្រនេះ ត្រូវរដ្ឋមន្ត្រីក្រសួងធម្មការធ្វើ ព្រមទាំងចុះហត្ថលេខានិងត្រា ហើយត្រូវព្រះសង្ឃនាយកទាំងពីរគណៈ ចុះហត្ថលេខានិងត្រាថែមទៀត ។

## ចំពូក ៣

## អំពីការត្រួតត្រានិងតាំងគ្រូបង្ហាត់

ប្រការ ១២— នៅខេត្តក្រៅ សាលាធម្មវិន័យ ត្រូវនៅក្រោមការត្រួតត្រា មេគណនិងអនុគណ ។ ចំណែកខាងគណៈធម្មយុត្តិ ចៅហ្វាយស្រុក និងចៅហ្វាយខេត្ត ត្រូវត្រួតត្រាឲ្យការសិក្សាក្នុងសាលានេះ ប្រព្រឹត្តទៅបានដោយស្រួល ។ នៅព្រះរាជធានី សាលានេះត្រូវនៅក្រោមការត្រួតត្រាផ្ទាល់ចៅអធិការវត្ត ។

ប្រការ ១៣— គ្រូបង្ហាត់ធម្មវិន័យ ត្រូវជ្រើសតាំងតាមប្រកាសក្រសួង រដ្ឋមន្ត្រីក្រសួងធម្មការ តាមពាក្យសុំចៅអធិការ ក្រោយដែលព្រះសង្ឃនាយក បានឲ្យយោបល់យល់ព្រមផង ។ គ្រូនេះត្រូវនៅក្រោមបង្គាប់ចៅអធិការ ។

## ចំពូក ៤

## អំពីការបង្ហាត់បង្រៀនគ្រូ

ប្រការ ១៤— មុនដំបូងនៅវត្តធំៗក្នុងព្រះរាជធានី នឹងបង្កើតឲ្យមានសាលាបំពេញវិជ្ជា ។ ឯគ្រូនៃសាលានេះ ព្រះសង្ឃនាយកត្រូវរើសក្នុងពពួកបណ្ឌិតដែលមានសមត្ថភាពជាងគេ សុំឲ្យតាំងតាមប្រកាសក្រសួង រដ្ឋមន្ត្រីក្រសួងធម្មការ ។

ប្រការ ១៥— ការឧបត្ថម្ភសាស្ត្រាចារ្យ ត្រូវនៅក្នុងបន្ទុកវត្តណាដែលមានសាលាបំពេញវិជ្ជា ។

ប្រការ ១៦– ការរៀបចំសាលាបំពេញវិជ្ជា និងការរើសរកសិស្សសម្រាប់ធ្វើគ្រូ នឹងបញ្ញត្តិជាក្រោយតាមប្រកាសក្រសួង រដ្ឋមន្ត្រីក្រសួងធម្មការ ។

## ចំពូក ៥

### អំពីសៀវភៅរៀន

ប្រការ ១៧– ត្រូវឲ្យមានគណៈកម្មការមួយ មានបព្វជិតទាំងពីរគណៈ ជាសមាជិកដែលមានវិជ្ជាជ្រៅជ្រះសម្រាប់តែងសៀវភៅធម្មវិន័យ ។ សៀវភៅនេះនឹងបោះពុម្ពផ្សាយ កាលណាបើព្រះសង្ឃនាយកទាំងពីរគណៈ បានចុះហត្ថលេខាយល់ព្រមហើយ ។ គណៈកម្មការនេះ ត្រូវតាំងតាមប្រកាសក្រសួងរដ្ឋមន្ត្រីក្រសួងធម្មការ ក្រោយដែលព្រះសង្ឃនាយកទាំងពីរគណៈ បានយល់ព្រមផង។

## ចំពូក ៦

### ហិរញ្ញវត្ថុបញ្ញត្តិ

ប្រការ ១៨– ត្រូវបង្កើតនៅមន្ទីរស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ ឲ្យមានហិបប្រាក់មួយ ហៅថា **ហិបធម្មសម្បត្តិ** មានអ្នកបញ្ជីម្នាក់ ជាអ្នកកាន់កាប់ ។ អ្នកបញ្ជីនេះ ត្រូវរដ្ឋមន្ត្រីក្រសួងធម្មការតាំងហើយត្រូវនៅក្រោមឱវាទរដ្ឋមន្ត្រី ។

ប្រការ ១៩– ហិបប្រាក់នេះ បានចំណូលពីជំនួយថវិកាផ្សេងៗ ពីអំណោយនិងប្រាក់បណ្ដាំពីប្រាក់ចំណេញ ដែលបានមកពីលក់សៀវភៅ ឬបានមកពីធនធានអ្វីឯទៀតដែលអនុញ្ញាតឲ្យទទួល ។

ប្រការ ២០– ហិបប្រាក់នេះ ត្រូវទទួលមុខចំណាយក្នុងការចាត់ចែងជាប្រយោជន៍ការបង្រៀនធម្មវិន័យ ក្រោយដែលរដ្ឋមន្ត្រីក្រសួងធម្មការ បានអនុញ្ញាតឲ្យចំណាយ ។

ប្រការ ២១– តាំងពីឥឡូវរហូតដល់ពេលដែល **ហិបធម្មសម្បត្តិ** មានប្រាក់គ្រប់គ្រាន់នឹងចាយខ្លួនឯងបាននោះ ថ្លៃបោះពុម្ពសៀវភៅរៀនធម្មវិន័យ និងវិញ្ញាបនប័ត្រ ត្រូវនៅក្នុងបន្ទុកបណ្ណាការសន្ធថវិកាជាតិត្រង់មុខចំណាយ បោះពុម្ពផ្សាយសៀវភៅផ្សេងៗ តែប្រាក់នេះត្រូវសងថវិកាវិញ ។ ផលដែលបានមកពីលក់សៀវភៅនេះ ត្រូវប្រមូលបញ្ចូលដាក់ **ហិបធម្មសម្បត្តិ** ហើយរដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវយកទៅបង់ថវិកាវិញ តាមចំនួនប្រាក់ចំណាយបោះពុម្ពផ្សាយ ។

ប្រការ ២២– រដ្ឋមន្ត្រីក្រសួងធម្មការ ត្រូវចាត់ការឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

ព្រះរាជក្រឹត្យធ្វើក្នុងព្រះបរមរាជវាំងចតុមុខ ក្រុងភ្នំពេញ ថ្ងៃច័ន្ទ ១៤ កើត ខែស្រាពណ៍ ឆ្នាំខាល ទោស័ក ព.ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ២៨ សីហា ១៩៥០ ។

| | |
|---|---|
| **តម្កល់នៅ :** | ឡាយព្រះហស្តលេខា : **នរោត្តម-សីហនុ** |
| ក្រសួងធម្មការ | ទទួលព្រះរាជឱង្ការ តម្កល់លើត្បូង |
| មន្ទីរចៅហ្វាយក្រុង | ព្រះអង្គម្ចាស់ក្រុមហ្លួង **ស៊ីសុវត្ថិ-មុនីវង្ស** |
| គ្រប់ខេត្រ | នាយករដ្ឋមន្ត្រី |
| អគ្គលេខាធិការគណៈរដ្ឋមន្ត្រី | ហត្ថលេខា : **ស. មុនីវង្ស** |

| | |
|---|---|
| បានចម្លងត្រឹមត្រូវហើយ | បានយកសេចក្តីក្រាបបង្គំទូលថ្វាយ សូមព្រះ |
| ឧកញ៉ាស្រីធម្មាធិបតី | រាជទានឡាយព្រះហស្តលេខា |
| ភ្ញៀវឈួយក្រសួងធម្មការ | ឧកញ៉ារដ្ឋមន្ត្រីក្រសួងធម្មការ |
| ហត្ថលេខា : **នៃវត្រ-សារុន** | ហត្ថលេខា : **មាស-វើល** |

បានចម្លងត្រឹមត្រូវ
ជ. អ្នកឧកញ៉ាអគ្គលេខាធិការគណៈរដ្ឋមន្ត្រី
ហត្ថលេខា : **ចាយ-ធុល**

សេចក្ដីប្រែចេញពីលិខិតជាភាសាបារាំង ដែលសហជីវិន ស៊ូ - វ៉ែណែម ប្រធាននៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ បានឆ្លើយតបទៅព្រះតេជព្រះគុណ ឈើខ - ហ្គាលី ជាប្រធាននៃ The propulsive committee of the assian Buddhist leader's congregation, Room 701, Dongtang Building, 45, 1-Ka Pil-Dong, Chung Ka, Séoul-Korea. មានសេចក្ដីដូចខាងក្រោមនេះ ។

ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ

ភ្នំពេញ, ថ្ងៃទី ១១ មិថុនា ១៩៦៨

លេខ ៩២/ពុ. ម. ក.

ព្រះតេជព្រះគុណ,

ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ បានទទួលលិខិតរបស់ព្រះតេជព្រះគុណ ចុះកាលបរិច្ឆេទខែមេសា ១៩៦៨ ហើយ ។ ទោះបីមានការយឺតយូរក្រុបានឆ្លើយតបចំពោះព្រះតេជព្រះគុណ ក៏ពុទ្ធិកសមាគម បានបញ្ជាឱ្យខ្ញុំព្រះករុណាសូមសម្ដែងនូវអំណរព្រះគុណដ៏ខ្លាំងក្លា, នូវស័ព្ទសាធុការពរដើម្បីជោគជ័យ ព្រមទាំងសេចក្ដីសរសើរដ៏កក់ក្ដៅ ដើម្បីសេចក្ដីសម្រេចតាមគោលបំណងដ៏ល្អរបស់ព្រះតេជព្រះគុណ ក្នុងការដឹកនាំឱ្យគោលនៃព្រះពុទ្ធសាសនា ទៅជាគោលនៃការគ្រប់គ្រងរដ្ឋ ។

ទស្សនៈរបស់ព្រះតេជព្រះគុណ ចំពោះស្ថានការណ៍អន្តរជាតិ មិនប្លែកអ្វីអំពីទស្សនៈរបស់ខ្ញុំព្រះករុណារាល់គ្នាដែរ ។ ទោះបីអារ្យធម៌របស់យើង បានជឿនលឿនដល់ថ្នាក់ខ្ពស់ណាស់ទៅហើយក៏ដោយ, ដោយសារតែសេចក្ដីប្រាថ្នាមិនចេះអស់មិនចេះហើយ នៃមហាអំណាចចក្រពត្តិនិយមខ្លះនោះ, ពិភពលោកយើងសម័យបច្ចុប្បន្ននេះ មុខជានឹងឈមមុខគ្រប់ពេលវេលា ឆ្ពោះទៅរកសេចក្ដីវិនាសពុំខាន ។ មហាអំណាចទាំងនោះ តែងតែខំប្រឹងឆ្លៀតយកផលអំពីភាពទន់ខ្សោយនៃប្រជាជាតិដែលកំពុងធ្វើដំណើរទៅកាន់វឌ្ឍនភាព, ភាពទន់ខ្សោយនៃអ្នកគ្រប់គ្រងរបស់ប្រជាជាតិទាំងនោះ, តែងផ្គត់ផ្គង់ហើយអុជអាលជម្រុញគោលបំណង រំលោភឈ្លានពានទឹកដី រវាងប្រជាជាតិនិងប្រជាជាតិខ្លះ, តែងផ្គត់ផ្គង់គ្រឿងសស្ត្រាវុធឱ្យដល់ប្រជាជាតិមួយ ហើយបន្ថែមគ្រឿងសស្ត្រាវុធឱ្យដល់ប្រជាជាតិមួយទៀត ដើម្បីបង្កាត់ភ្នក់ភ្លើងសង្គ្រាមឱ្យចេះតែឆេះជាប់ជានិច្ច។ វឌ្ឍនភាពខាងវិទ្យាសាស្ត្រនិងខាងបច្ចេកទេសដែលត្រូវយកទៅប្រើ ដើម្បីលើកតម្កើងឋានៈជីវភាពនៃមនុស្សជាតិ ក៏បែរជាយកទៅបំពេញគោលបំណងយោធា និងការបំផ្លិចបំផ្លាញយ៉ាងរង្គំរង្គាលទៅវិញ ។ ដូច្នេះហើយខ្ញុំព្រះករុណាយល់ថា ការទម្លាក់រឿងនេះឱ្យអ្នកកាន់ព្រះពុទ្ធសាសនាយើងជាអ្នកទទួលខុសត្រូវទៅវិញ ជាការពុំស្របនឹងគតិយុត្តិធម៌ទេ ។

ទោះជាយ៉ាងដូចម្ដេចក៏ដោយ, ខ្ញុំព្រះករុណាក៏ជឿជាក់ដូចព្រះតេជព្រះគុណដែរថា «ពុទ្ធសាសនា ជាសាសនាវិជ្ជមាន, ប្រកបដោយវឌ្ឍនភាព, ជាប្រាកដនិយម, ឧត្តមគតិនិយម ទាំងខាងលទ្ធិ ទាំងខាងមហាទស្សនវិជ្ជា» ។ អាស៊ីទ្វីប សុទ្ធសឹងជាអ្នកកាន់ព្រះពុទ្ធសាសនា; ប៉ុន្តែគួរឲ្យស្ដាយពន់ពេកទៅវិញ មានប្រទេសតិចណាស់ ដែលបានប្រព្រឹត្តតាមតម្រាយមាគ៌ារបស់ព្រះបរមគ្រូ ។

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសទី១ បន្ទាប់អំពីលង្កាទ្វីប ដែលបានលើកតម្កើងព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ហើយជាប្រទេសកាន់ព្រះពុទ្ធសាសនាតែមួយ ដែលបានរចនាព្រះពុទ្ធសាសនាចូលទៅក្នុងរបៀបគ្រប់គ្រងរដ្ឋ ។

សង្គមរាស្ត្រនិយមខ្មែរ ដែលមានអង្គសម្ដេចព្រះ **នរោត្តម-សីហនុ** ជាព្រះប្រធាន បានចាប់បដិសន្ធិឡើងក្រោមបដិមរូបនៃត្រៃបាវចនាថា «**ជាតិ - សាសនា - ព្រះរាជបល្ល័ង្ក**» ។ ពាក្យថា សាសនាក្នុងទីនេះ បានស្ថិតនៅក្នុងឋានៈដ៏ប្រសើរ គឺមានពាក្យថា **ជាតិ** នៅអមខាងមុខ និងពាក្យថា **ព្រះរាជបល្ល័ង្ក** នៅអមខាងក្រោយ ។ មូលហេតុដ៏ប្រកបដោយហេតុ-ផលដ៏ប្រសើរនៃពុទ្ធសាសនា បានជ្រួតជ្រាបទៅលើចិត្តគំនិត ព្រមទាំងបានផ្សាយឥទ្ធានុភាពទៅលើចរិតនៃប្រជាជាតិយើងជាង ៩៩ ៪ ហើយបានបង្កបង្កើតជារបបគ្រប់គ្រងប្រចាំប្រជាជាតិយើង ដែលយើងឲ្យឈ្មោះថា «**សង្គមនិយមព្រះពុទ្ធសាសនាខ្មែរ**» ។ សេចក្ដីពន្យល់ ឬ វិភាគអំពី «សង្គមនិយមព្រះពុទ្ធសាសនា» របស់យើងនោះ មាននៅក្នុងសៀវភៅដែលខ្ញុំព្រះករុណា សូមផ្ញើមកប្រគេនចំនួន ៥ ក្បាល ដើម្បីព្រះតេជព្រះគុណបានជ្រាបពត៌មាន ។ ព្រះសង្ឃពុទ្ធសាសនិកខ្មែរ ជាពួកក្រុមដែលមានលំដាប់ឋានៈដ៏ប្រសើរ; ដំណើរនេះ នាំឲ្យមានសន្និទ្ធពល, កម្លាំងពុទ្ធសាសនានៅប្រទេសកម្ពុជា, ថាមពលរបស់ខ្លួននិងការរីកចម្រើន ព្រមទាំងការតទប់របស់ប្រទេសបានប្រកបជោគជ័យ ចំពោះគោលបំណងវិច្ឆេទកម្ម និងការប្រឹងប្រែងចូលមកជ្រៀតជ្រែកខាងមនោគមវិជ្ជា ឬ លទ្ធិដទៃ ។

ខ្ញុំព្រះករុណាយល់ឃើញថា ហេតុដែលនាំឱ្យព្រះពុទ្ធសាសនា ចុះទន់ខ្សោយជាងសាសនាដទៃ ៗ លើផ្ទៃអន្តរជាតិនាបច្ចុប្បន្នសម័យនេះ មកពីខ្វះសន្និទ្ធពលនេះឯង, មកពីគ្មានលំដាប់ឋានៈដែលជាប្រភពនៃឯកភាព និងឯកភាពនៃអំពើ ។ មួយវិញទៀត ខ្ញុំព្រះករុណាយល់ថា អ្នកកាន់ព្រះពុទ្ធសាសនាខ្វះវិចក្ខណញ្ញាណ ដូចអ្នកជឿកាន់សាសនាដទៃ ៗ គឺមហិច្ឆិតាដឹកនាំឲ្យព្រះពុទ្ធសាសនាមានជោគជ័យក្នុងពិភពលោក ។

ក្នុងឋានៈរបស់ខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនា ១ រូប, ខ្ញុំព្រះករុណាមិនមានបំណងអ្វីនឹងលើកតម្កើងព្រះពុទ្ធសាសនា និងចលនាសម្ពន្ធរបស់យើង ឲ្យមានឋានៈឧត្តុង្គឧត្តមខ្ពង់ខ្ពស់ ជាងសាសនាដទៃៗ ឬចលនាសម្ពន្ធដទៃៗទេ; ប៉ុន្តែខ្ញុំព្រះករុណា អាចបញ្ជាក់ប្រគេនព្រះតេជព្រះគុណព្រោះមានអ្នកសង្កេតការណ៍បរទេស ដែលមិនលំអៀងដោយអគតិជាសាក្សីថា «សង្គមរាស្ត្រនិយម» របស់យើង, «សង្គមនិយមព្រះពុទ្ធសាសនា» របស់យើង បានផ្តល់ភ័ស្តុតាងយ៉ាងជាក់ស្តែងចំពោះយើងរួចមកហើយ ។ កម្ពុជរដ្ឋ ត្រូវបានអន្តរជាតិទទួលស្គាល់ថាជា «**កោះសន្តិភាព**» នៅកណ្តាលមហាសមុទ្រនៃអគ្សន្តរាយ ដែលវាកំពុងបំផ្លិចបំផ្លាញអាស៊ីភាគអគ្នេយ៍, ក្នុងសង្គ្រាមអាមេរិក - វៀតណាមនេះ ដែលជាប្រភពនៃអំពើកាចសាហាវយង់ឃ្នងព្រៃផ្សៃ, នៃទុក្ខវេទនា និងសេចក្តីលំបាករកទីបំផុតគ្មាន ។

សន្តិភាព ដែលអ្នកខ្លះសម្គាល់ថាជាអព្ភូតហេតុដ៏អស្ចារ្យនេះ យើងបានសម្រេចដោយសារគុណបុណ្យនៃព្រះប្រមុខអគ្គមគ្គុទ្ទេសក៍របស់យើង គឺសម្តេចព្រះ **នរោត្តម-សីហនុ** ដែលទ្រង់ប្រកបដោយព្រះគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ និងព្រះប្រាជ្ញាញាណដ៏ភ្លឺស្វាង ហើយដែលមានប្រជាជាតិបានស្ម័គ្ររួបរួមជង្ហែយ៉ាងស៊ប់សួនពីក្រោយព្រះប្រឹស្នាង្គ, ព្រះប្រមុខរដ្ឋរបស់យើង ទ្រង់អាចរក្សាការពារប្រទេសយើង ឲ្យបានរួចផុតចាកអំពើវិច្ឆេទកម្មដែលបំផ្លាញស្រុកទេសនៃអ្នកជិតខាងយើង, ទ្រង់អាចទ្រទ្រង់ប្រទេសយើង ឱ្យរួចផុតចាកការប្រយុទ្ធយ៉ាងសាហាវឃោរឃៅ ដែលជាស្នាដៃនៃមហាអំណាចអ្នកមានបំណងនិងប្រតិស្ឋានអនុត្តរភាពរបស់ខ្លួន ។ កម្ពុជរដ្ឋ បានស្ថិតនៅឆ្ងាយចាកសង្គ្រាមពង្រីកឥទ្ធិពល ឬមនោគមវិជ្ជា ។ ប្រទេសខ្មែរមានមនោគមវិជ្ជាផ្ទាល់របស់ខ្លួន គឺព្រះពុទ្ធសាសនា ។

ទោះបី យើងបានផ្តាច់ចំណងទូតជាមួយនឹងសហរដ្ឋអាមេរិក ទាំងបានទាត់ចោលនូវជំនួយសេដ្ឋកិច្ច និងយោធាអំពីប្រទេសនេះ, យើងគង់អាចស្ថិតនៅឃ្លាតអំពីប្លុកទាំងពីរ ដោយរយៈចម្ងាយស្មើគ្នាបានជាដរាបរៀងមក ។ នេះមិនមែនជាផ្លូវត្រូវ ដែលព្រះសមណគោតមទ្រង់បានត្រាស់បង្ហាញនោះឬទេ ? ដោយហេតុនេះហើយ ទើបនយោបាយក្រៅប្រទេសរបស់យើង ជានយោបាយស្ថិតនៅលើ «**ផ្លូវកណ្តាល មជ្ឈិមាបដិបទា**», ដោយយកផ្លូវនេះជាគោលក្នុងការទាក់ទងជាមួយនឹងបរទេស, យើងប្រកាន់ខ្ជាប់នូវនយោបាយបដិការៈ ព្រមទាំងបញ្ចសីលានៃព្រះបរមគ្រូជាម្ចាស់ ដែលទ្រង់បានត្រាស់ថា «ខ្លួនត្រូវទីពឹងខ្លួន» ប្រទេសកម្ពុជាក៏បាន «ជួយខ្លួនដោយខ្លួនឯង» ក្នុងការស្ថាបនាជាតិរបស់ខ្លួន ។ តាមពិត យើងមិនមែនថាមិនបានជួបនូវ

សេចក្ដីលំបាកទេ ព្រោះយើងមានមធ្យោបាយតិចតួចស្ដួចស្ដើងពេក យើងមិនអាចធ្វើដំហានឲ្យវែងៗទៅមុខបានហួសកម្លាំងទេ ទាំងមិនអាចញ៉ាំងសេដ្ឋកិច្ច ឲ្យល្អតលាស់ក្នុងក្ដាំងហួសប្រមាណបានឡើយ; ប៉ុន្តែប្រទេសរបស់យើង គង់នឹងចេះតែជឿនលឿនទៅមុខជាដរាប ដោយស្ថិតនៅលើមូលដ្ឋានមនោគមវិជ្ជាយ៉ាងមាំ គឺមូលហេតុនៃព្រះពុទ្ធសាសនា ។ លក្ខខ័ណ្ឌទាំងនេះបានពួតផ្គុំគ្នាឡើង ហើយបានធ្វើឲ្យកម្ពុជរដ្ឋរបស់យើង បានទៅជាប្រទេសមួយមានការសុខស្ងប់, មានការរួបរួមគ្នាជាធ្លុងមួយ, មានសេរីភាពគ្រប់គ្រាន់, មានឯករាជ្យពេញលេញ និងមានអធិបតេយ្យដ៏បរិបូណ៌ ។

សូមព្រះតេជព្រះគុណ មេត្តាអភ័យទោស ដោយបានរៀបរាប់ប្រគេនអំពីរបបគ្រប់គ្រងរបស់យើងនេះ ព្រោះថាព្រះតេជព្រះគុណ ក៏គង់អាចជ្រាបបានថា គំនិតលើកតម្កើងគោលព្រះពុទ្ធ-សាសនា ឲ្យទៅជាគោលការណ៍គ្រប់គ្រងប្រជាជាតិនោះ មិនមែនជាហេតុថ្មីសម្រាប់យើងឡើយ; ប៉ុន្តែយើងគង់យល់បានថា ជោគជ័យនៅទីនេះអាចទៅជាបរាជ័យនៅទីដទៃ ឬ ផ្ទុយទៅវិញក៏សឹងតែមានដែរ ។ យើងខ្ញុំព្រះករុណា មានបំណងនឹងថ្លែងការណ៍នេះ ប្រគេនព្រះតេជព្រះគុណដោយផ្ទាល់មាត់ ទាំងបង្ហាញនូវការពិសោធន៍របស់យើង ដើម្បីព្រះតេជព្រះគុណបានជ្រាបផង នៅក្នុងថ្ងៃនៃអនាគតសមាជរបស់ព្រះតេជព្រះគុណ ក៏ប៉ុន្តែយើងខ្ញុំព្រះករុណា មានសេចក្ដីស្ដាយពន់ពេក ព្រោះថាដំណើរដែលប្រទេសយើងទាំងពីរ មិនមានការទាក់ទងគ្នានោះ ជាហេតុនាំឲ្យយើងខ្ញុំព្រះករុណា មិនអាចធ្វើដំណើរមកចូលរួមក្នុងមហាសន្និបាត នៃអ្នកដឹកនាំព្រះពុទ្ធសាសនាក្នុងអាស៊ីទ្វីប ដែលព្រះតេជព្រះគុណបានផ្ដួចផ្ដើងនិងចាត់ចែង ហើយដែលយើងខ្ញុំព្រះករុណាយល់ថាពិតជាមានសារៈប្រយោជន៍នោះបានឡើយ ។

យើងខ្ញុំព្រះករុណា សូមប្រគេនពរសព្វសាធុការដ៏ថ្លៃថ្លាចំពោះព្រះតេជព្រះគុណ ដើម្បីបានសម្រេចនូវជោគជ័យបរមសុខ និងសុភមង្គល !

ក្នុងព្រះចិន្តាដ៏ជាទីគោរពនៃព្រះសម្ពុទ្ធបរមគ្រូ ។

**សុ - ណែម**

ប្រធានគណៈកម្មាធិការនាយក

# អំពីការធ្វើឱ្យមានអាយុតិច និងអាយុច្រើន

មនុស្សទាំងឡាយដែលកើតមកក្នុងលោក ទោះមនុស្សប្រភេទណាក៏ដោយ សុទ្ធសឹងតែស្រឡាញ់ជីវិត ចង់រស់នៅឲ្យបានយឺនយូរគ្រប់ៗគ្នា គឺមិនមានអ្នកណាមួយអាចពោលបដិសេធថាមិនស្រឡាញ់ជីវិតនោះគ្មានសោះឡើយ ។ ពាក្យថាស្លាប់, ថាអស់អាយុ ឬ អាយុខ្លី ជា **អនិដ្ឋារម្មណ៍** គឺអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីពេញចិត្តរបស់មនុស្សទាំងឡាយទេ ។ បើពាក្យថា រស់នៅ, ថាចម្រើនអាយុ ឬ អាយុវែង ទើបជា **ឥដ្ឋារម្មណ៍** គឺអារម្មណ៍ជាទីប្រាថ្នា ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ព្រោះហេតុនោះ មនុស្សទាំងឡាយ សុទ្ធតែតក់ស្លុតខ្លាចស្លាប់យ៉ាងក្រៃលែង ហើយស្រឡាញ់ជីវិត គឺចង់រស់នៅឲ្យបានយឺនយូរ, ចង់ឲ្យបានអាយុវែងគ្រប់ៗគ្នា ។ ឯអ្នកដែលមិនខ្លាចស្លាប់សោះនោះ គឺមានតែសត្វវិសេស ៤ ពួកទេ គឺ **ដំរីអាជានេយ្យ១, សេះអាជានេយ្យ១, គោអាជានេយ្យ១, ព្រះខីណាស្រព១** ។ បណ្ដាសត្វវិសេសទាំង៤នោះ ព្រះខីណាស្រព បានជាលោកមិនខ្លាចស្លាប់ ព្រោះសំយោជនកិលេសមានសក្កាយទិដ្ឋិជាដើម លោកបានលះបង់អស់រលីងពីខន្ធសន្តានទៅហើយ, ចំណែកខាងសត្វវិសេសទាំង ៣ ពួកមានដំរីអាជានេយ្យជាដើម ជាសត្វមានសក្កាយទិដ្ឋិដ៏មានកម្លាំងខ្លាំងក្លៀវក្លាក្នុងសន្តានចិត្ត ឥតកោតញញើតចំពោះសត្វដែលជាប្រតិបក្សនឹងខ្លួនសោះឡើយ បានជាសត្វពួកនេះមិនអើពើនឹងសេចក្ដីស្លាប់ ។

បណ្ដាមនុស្សទាំងឡាយដែលកើតមកហើយ ខ្លះអាយុខ្លីក៏មាន, ខ្លះអាយុវែងក៏មាន ។ មនុស្សដែលមានអាយុខ្លីនោះ អាស្រ័យដោយមានអកុសលកម្មចាស់ចូលមកផ្ដាច់ផ្ដិលជីវិតឲ្យស្លាប់ទៅវិញក៏-មាន, បើគ្មានអកុសលកម្មចាស់ចូលមកផ្ដាច់ផ្ដិលទេ ហើយមនុស្សនោះនៅតែមានអាយុខ្លីដដែល, ត្រង់នេះគួរយល់ថា មនុស្សនោះឯង ខ្វះការឧបត្ថម្ភដោយវត្ថុផ្សេងៗ មានអាហារជាដើមឲ្យបានគ្រប់-គ្រាន់ ពុំនោះសោត ខ្វះអនាម័យ គឺមិនចេះថែទាំរក្សាខ្លួនឲ្យមានសុខភាពល្អ ប្រៀបដូចរុក្ខជាតិដំណាំផ្សេងៗដែលគេដាំ, ដំណាំនោះបើគេដាំដុះឡើងហើយ ប៉ុន្តែបើមិនថែទាំ មិនដាក់ជី មិនស្រោចទឹកជាជំនួយផងទេ ដំណាំនោះក៏មិនអាចនឹងរស់នៅបានយូរឡើយ មុខតែនឹងត្រូវស្វិតស្រពោនហើយត្រូវងាប់ទៅវិញដោយឆាប់រហ័ស យ៉ាងណាមិញ, ជីវិតរបស់មនុស្សទាំងឡាយ បើគ្មានការឧបត្ថម្ភគ្មានការថែទាំរក្សាឲ្យបានដិតដល់ទេ នឹងត្រូវរលត់ស្លាប់បាត់បង់ទៅវិញយ៉ាងឆាប់រហ័ស ក៏ដូច្នោះដែរ ។

មួយយ៉ាងទៀត គេតែងនិយាយថា "បើអាយុមិនទាន់អស់ទេ ទោះបីធ្វើយ៉ាងណាក៏មិនស្លាប់ដែរ, បើអាយុត្រូវអស់ហើយ ទោះបីខំប្រុងប្រយ័ត្ន ឬចិត្តថ្មមរក្សាការពារយ៉ាងណាក៏នៅតែស្លាប់"

មនុស្សប្រែបដូចថាមកនេះ មានពិតមែន ប៉ុន្តែមិនមែនមានទូទៅគ្រប់មនុស្សទេ គឺមានម្នាក់ៗ ដោយសារមនុស្សនោះ មានបុណ្យវាសនាដ៏ខ្ពង់ខ្ពស់ជួយឧបត្ថម្ភជិតដល់ ដូចជាពោធិសត្វជាដើម, ឯមនុស្សសាមញ្ញ ត្រូវតែមានគ្រឿងឧបករណ៍ជួយឧបត្ថម្ភគ្រប់បែបយ៉ាង ទាំងត្រូវថែរក្សាថ្នាក់ថ្នមជានិច្ចផងដែរ ទើបអាយុនោះអាចប្រព្រឹត្តទៅអស់កាលដ៏វែងបាន បើមិនដូច្នោះទេ អាយុក៏ពុំអាចនឹងប្រព្រឹត្តទៅបានឡើយ ។ ប្រៀបដូចគ្រឿងចក្រផ្សេងៗមានរថយន្ត (រទេះឡាន) ឬនាឡិកាជាដើម ដែលគេប្រើប្រាស់សព្វថ្ងៃ, គ្រឿងចក្រទាំងនោះបើគេតម្កល់ទុកនៅស្ងៀម មិនប្រើប្រាស់វាសោះ, គ្រឿងចក្រនោះក៏ឆាប់ខូច គឺបណ្ដាលមកអំពីច្រេះស៊ីមចាប់នាំឲ្យផាស់តាំងដំណើរប្រព្រឹត្តទៅពុំស្រួល, បើប្រើវាញាក់ញីខ្លាបោកបោះខ្លាំងពេក គ្មានការថ្នាក់ថ្នមសោះ ក៏នាំឲ្យឆាប់ខូចអន្តរាយដែរ យ៉ាងណា, ឯរូបកាយរបស់យើងក៏ដូច្នោះដែរ បើយើងនៅសម្ងំស្ងៀមគ្មានធ្វើការអ្វីសោះ រូបកាយនោះក៏ទៅជាផាស់តាំង បណ្ដាលឲ្យកើតរោគស្រពន់ស្ពឹកជាដើមក៏មាន ឬប្រើកាយឲ្យធ្វើការញាក់ញីនឿយហត់ខ្លាំងពេក ក៏នាំឲ្យរូបកាយគ្រាំគ្រាឆាប់អស់អាយុដែរ ព្រោះហេតុនោះ អាយុដែលនឹងប្រព្រឹត្តទៅបានវែងនោះ លុះតែយើងចេះថែទាំរក្សា ការពាររូបកាយឲ្យមានអនាម័យគ្រប់យ៉ាងផងដែរ ទើបអាយុនោះអាចតាំងនៅអស់កាលដ៏យូរបាន ។ ក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត មានសេចក្ដីដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា បុគ្គលណាប្រព្រឹត្តតាមធម៌ទាំង ៥ យ៉ាងហើយ បុគ្គលនោះ នឹងអាចធ្វើខ្លួនឲ្យទៅជាអ្នកមានអាយុវែងបាន, ឯធម៌ទាំង ៥ យ៉ាងនោះគឺ

១– **សប្បាយការី** ធ្វើខ្លួនឲ្យសប្បាយ;

២– **សប្បាយេ មត្តំ ជានាតិ** ដឹងប្រមាណក្នុងការសប្បាយ;

៣– **បរិណតភោជី** បរិភោគអាហារដែលល្មមក្នុងធាតុធ្វើឲ្យរលាយបានស្រួល;

៤– **កាលចារី** ត្រាច់ដើរក្នុងកាលគួរ ឬប្រព្រឹត្តធ្វើការក្នុងកាលគួរ;

៥– **ព្រហ្មចារី** ប្រព្រឹត្តធម៌ដ៏ប្រសើរ គឺមិនល្មោភក្នុងកាម ។

សូមលើកយកមាតិកាធម៌ទីមួយៗនោះ មកអធិប្បាយជាសេចក្ដីសង្ខេបដូចតទៅនេះ ៖

១– ត្រង់ពាក្យថា ធ្វើខ្លួនឲ្យសប្បាយ នោះ បានសេចក្ដីថា ធម្មតាមនុស្សនីមួយៗមិនត្រូវធ្វើខ្លួនឲ្យព្រួយកើតទុក្ខក្រៀមក្រំក្នុងចិត្តជានិច្ចកាលទេ, កាលបើចិត្តជាប្រធាន ឬជាម្ចាស់នៃរាងកាយ កើតទុក្ខព្រួយក្រៀមក្រស់ស្រពោនស្រពាប់ជានិច្ចហើយ, ឯរាងកាយដែលជាទីអាស្រ័យនៅរបស់ចិត្ត ក៏

ត្រូវតែក្រៀមក្រស់ស្រពាប់ស្រពោនទៅតាមគ្នាដែរ ទាំងសាច់ឈាមសោតទៀត ក៏ឡើងល្អក់ស្រក់-ស្រុតស្គាំងស្គមទៅជាលំដាប់ រហូតដល់គំនិតប្រាជ្ញាស្មារតីដែលធ្លាប់តែរហ័សរហួនអង់អាច ក៏ត្រឡប់ទៅជាទន់ខ្សោយផងដែរ យូរទៅនឹងក្លាយទៅជាកើតរោគផ្សេងៗនាំឲ្យអាយុខ្លីក៏មាន; ផ្ទុយពីនេះវិញ ត្រូវធ្វើខ្លួនឲ្យមានការសប្បាយរីករាយចំពោះអារម្មណ៍ដែលល្អ កាលបើចិត្តបានទទួលអារម្មណ៍សប្បាយស្រស់ស្រាយជានិច្ចហើយ, សាច់ឈាមក៏ឡើងថ្លាស្រស់ស្រួល ទាំងគំនិតប្រាជ្ញាស្មារតី ក៏វាងវៃអង់អាច បើនឹងគិតការអ្វីក៏ឆាប់យល់ឆាប់ឃើញ ចំណែកខាងរោគាព្យាធិផ្សេងៗក៏កម្រនឹងកើតឡើងបាន ម្លោះហើយក៏នាំឲ្យរាងកាយមានសុខភាពល្អ អាយុក៏បានវែងផងដែរ ។

២— ត្រង់ពាក្យថា ដឹងប្រមាណក្នុងការសប្បាយ នោះ បានសេចក្ដីថា មនុស្សនីមួយៗមិនត្រូវធ្វើខ្លួនឲ្យសប្បាយរីករាយហួសហេតុពេកទេ កាលបើជួបប្រទះ ឬបាននូវអារម្មណ៍ទាំងឡាយណាមួយ មានរូបារម្មណ៍ជាដើម ដែលជាអារម្មណ៍ជាទីគាប់ចិត្តពេញចិត្ត នាំឲ្យកើតសេចក្ដីសប្បាយរីករាយហើយ មិនត្រូវបណ្ដោយចិត្តឲ្យលង់ឈ្លក់ជាប់ក្នុងសេចក្ដីសប្បាយនោះរហូតដល់ទៅភ្លេចខ្លួន ភ្លេចទ្រព្យរបស់ ភ្លេចប្រពន្ធកូន ភ្លេចការងារប្រចាំខ្លួនឡើយ ។ ធម្មតាចិត្ត បើបណ្ដោយឲ្យកម្រើកខ្លាំងក្នុងការរីករាយហួសហេតុពេកទៅ ក៏ពុំសូវស្រួលដែរ, បើនឹងបណ្ដោយឲ្យកើតទុក្ខក្រៀមក្រំអាប់-អួពេកទៅ ក៏ពុំសូវស្រួលដែរ ព្រោះហេតុនោះ កាលបើមានសេចក្ដីសប្បាយរីករាយកើតឡើងហើយ ត្រូវឲ្យស្គាល់ប្រមាណក្នុងការសប្បាយនោះផង ទើបអាយុនោះអាចប្រព្រឹត្តទៅបានវែង ។

៣— ត្រង់ពាក្យថា បរិភោគអាហារល្មមភ្លើងធាតុធ្វើឲ្យរលាយស្រួល នោះ បានសេចក្ដីថា ការបរិភោគអាហារជាការសំខាន់បំផុត ព្រោះអាហារមានច្រើនប្រភេទគឺ អាហារខ្លះបរិភោគទៅឲ្យគុណក៏មាន, អាហារខ្លះបរិភោគទៅឲ្យទោសក៏មាន ។ អាហារណាដែលបរិភោគចូលទៅហើយ ត្រឡប់ទៅជាឲ្យទោស មានធ្វើឲ្យហើមពោះ ចុះរាគរុះ ទល់ធ្លល់ ចុកសៀត ។ល។ អាហារនោះត្រូវតែវៀរចេញកុំបរិភោគឡើយ ។ អាហារណាដែលបរិភោគចូលទៅហើយ រមែងឲ្យគុណ គឺឲ្យសុខស្រួលមានកម្លាំងកំហែងក្នុងខ្លួន ត្រូវតែបរិភោគអាហារនោះ ប៉ុន្តែមិនត្រូវបរិភោគឲ្យច្រើនកើនលើសហួសប្រមាណ ដល់ថ្នាក់ទល់ហល់ចាក់ច្រាសនោះទេ, មិនត្រូវបរិភោគញឹកញយពេក ទាល់តែភ្លើងធាតុកម្ដៅរំលាយមិនទាន់នោះឡើយ ។ ការបរិភោគរាល់ថ្ងៃត្រូវតែកំណត់ពេលនិងអាហារឲ្យទៀងទាត់ គឺពេលព្រឹកកំណត់ម៉ោងប៉ុន្មាន, ថ្ងៃត្រង់កំណត់ម៉ោងប៉ុន្មាន, ពេលល្ងាចកំណត់ម៉ោង

ប៉ុន្មាន ទាំងអាហារក៏ត្រូវកំណត់ចំនួនឲ្យទៀងទាត់ដែរ; បើបរិភោគម្តងតិចពេក ម្តងច្រើនពេក ទាំងពេលក៏មិនទៀងទាត់ផងទៀត, ការមិនទៀងនេះឯង ក៏សុទ្ធតែជាទោសនាំឲ្យមិនស្រួលក្នុងខ្លួនដែរ ព្រោះហេតុនោះ ការបរិភោគអាហាររាល់ថ្ងៃ គួរកំណត់ពេលឲ្យទៀង, កំណត់ចំនួនអាហារឲ្យទៀង អាហារនោះក៏គួរពិនិត្យឲ្យហ្មត់ចត់ជាមុនសិមបរិភោគ ហើយកុំបរិភោគឲ្យច្រើនពេក តិចពេក គឺលៃ-លកឲ្យគួរដល់ប្រមាណផង ទើបអាយុនោះអាចប្រព្រឹត្តទៅបានវែង ។ កុំបរិភោគឲ្យឆ្អែតហួសប្រ-មាណ រហូតដល់តឹងឡើងកាងពោះទល់ខ្យល់ចាក់ប្រាសរវើសរវាស ទទួលទុក្ខវេទនា ដូចពួកព្រាហ្មណ៍ខ្លះដែលមាននិយាយក្នុងគម្ពីរធម្មបទនោះឡើយ ។ ក្នុងគម្ពីរនោះមាននិយាយថា ព្រាហ្មណ៍ឈ្មោះ **អាហារហត្ថក**ៈ ជាអ្នកលោភបរិភោគច្រើនហួសប្រមាណ, មានពេលខ្លះគាត់បរិភោគហើយងើបក្រោកឡើងពីកន្លែងមិនរួច ទាល់តែស្រែកហៅឲ្យគេជួយទាប់ដៃទាញអូសចេញពីកន្លែង ដែលបរិភោគ ។ ព្រាហ្មណ៍ឈ្មោះ **អលំសាដក**ៈ ជាអ្នកលោភបរិភោគច្រើនដូចគ្នា, ក្នុងពេលដែលគាត់បរិភោគម្តង ៗ ពោះឡើងតឹងណែន ស្លៀកសំពត់មិនជាប់ ។ ព្រាហ្មណ៍ឈ្មោះ **តត្ថវដ្តក**ៈ ជាអ្នកលោភបរិភោគច្រើនហួសប្រមាណដែរ, ពេលខ្លះគាត់បរិភោគច្រើនហួសកម្រិត ពោះឡើងតឹងណែន ត្រង់ខ្លួនស្តូក វិល-វល់នៅតែនឹងកន្លែងបរិភោគ ងើបក្រោកឡើងទៅណាមិនរួច ។ ព្រាហ្មណ៍ឈ្មោះ **កាកមាសក**ៈ ជាអ្នកលោភបរិភោគច្រើនដែរ ប៉ុន្តែព្រាហ្មណ៍នេះបរិភោគច្បិចច្បើមបន្តិច ៗ ទេ តែមិនឈប់, បើមានថ្មើរណា បរិភោគថ្មើរណោះឥតឈប់ឈរ គ្មានវេលាកំណត់ឲ្យទៀងទាត់ឡើយ ។ ព្រាហ្មណ៍ម្នាក់ទៀតឈ្មោះ **ភុត្តវម្មិក**ៈ[១] ក៏ជាអ្នកបរិភោគច្រើនមិនស្គាល់ប្រមាណដែរ, ពេលខ្លះគាត់បរិភោគជ្រុលហួសកំណត់ ពោះឡើងតឹងណែន រឹងខ្លួនស្តូកដូចជាដំបូកងាករេខ្លួនមិនកើត ។

សេចក្តីដែលបានអធិប្បាយដូចខាងលើនេះ បញ្ជាក់ឲ្យឃើញថា ការបរិភោគច្រើនពេកក៏ជាទោស ការបរិភោគតិចពេកក៏ជាទោស បរិភោគគ្មានពេលកំណត់ឲ្យទៀងទាត់ក៏ជាទោស ។ មួយ-យ៉ាងទៀត មានមនុស្សលោភខាងស៊ី និយាយជាពាក្យត្លុកកំប្លែងថា មនុស្សយើងកើតមករស់នឹងស៊ី បើមានហើយត្រូវតែស៊ីឲ្យឆ្អែត មិនដែលនរណាងាប់ពីព្រោះស៊ីទេ ។ ពាក្យដែលគេថានេះ ត្រូវខ្លះដែរ មិនមែនខុសទាំងអស់ទេ ប៉ុន្តែការស៊ីនោះ គួរលៃលកឲ្យដឹងប្រមាណផងដែរ ទើបរាងកាយអាចប្រព្រឹត្តទៅស្រួលបាន ប្រៀបដូចជាគ្រឿងចក្រមានរទេះឡាន ឬរ៉ឺម៉កជាដើម បើគេដាក់របស់

១ ក្នុងគម្ពីរខ្លះថា ភុត្តវម្មិកកៈ ព្រាហ្មណ៍នេះបរិភោគច្រើនជ្រុលហួសកម្រិត ទាល់តែក្អួតចង្អោរមកវិញ ។

បន្តិចបន្តួចផ្ទុកស្រាល ក៏នាំឲ្យគ្រឿងចក្រនោះលោតរលាក់រលែកខ្លាំងពេក, បើគេដាក់របស់ផ្ទុកធ្ងន់ច្រើនហួសកម្រិត ក៏នាំឲ្យមានគ្រោះថ្នាក់មានបែកកង់ បាក់ចន្លាស់ជាដើម មិនស្រួលយ៉ាងណា, ឯរាងកាយរបស់យើងបើបរិភោគតិចពេក ឬច្រើនពេក ក៏ដូច្នោះដែរ, ព្រោះហេតុនោះ ការបរិភោគគួរលៃឲ្យល្មមកុំឲ្យច្រើនពេក តិចពេក ហើយគួរពិនិត្យមើលអាហារនោះឲ្យបានហ្មត់ចត់ផង សមដូចភាសិតបុរាណថា **បើស្រឡាញ់ខ្លួនឱ្យស្ងួនបំណី** ។ ការដឹងប្រមាណក្នុងការបរិភោគនេះ អាចធ្វើខ្លួនយើងឲ្យស្រាលរហ័សរហួន, មិនធ្ងន់ខ្លួនមិនស្អឹះស្អុះ មិនតឹងពិបាកក្នុងខ្លួន ដូចមានរឿងក្នុងគម្ពីរធម្មបទដែលតំណាលអំពីស្តេច **បសេនទិកោសល** ទ្រង់សោយព្រះក្រយាស្ងោយច្រើនហួសប្រមាណ, ថ្ងៃមួយ ទ្រង់ស្តេចទៅគាល់ព្រះសម្មាសម្ពុទ្ធ ដោយមានព្រះកាយលំបាករសាប់រសល់ មិនអាចទឹងតង់ឲ្យត្រង់ព្រះអង្គក្នុងទីដ៏សមគួរបាន ទើបព្រះពុទ្ធបរមគ្រូទ្រង់ជ្រាបហើយត្រាស់ថា មហារាជ ទ្រង់ស្តេចមកនេះ មិនទាន់បានសម្រាកព្រះអង្គទេដឹង ! ហើយទ្រង់ត្រាស់ទៀត មានសេចក្តីជាអាទិ៍ថា បុគ្គលអ្នកបរិភោគភោជនច្រើនហួសប្រមាណ រមែងបានសេចក្តីទុក្ខលំបាកយ៉ាងនេះ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ព្រះពុទ្ធដីកានៃព្រះសម្មាសម្ពុទ្ធហើយទ្រង់មានសេចក្តីអៀនខ្មាស ទើបទ្រង់សោយបន្ថយព្រះក្រយាស្ងោយ តាំងពីអង្ករ ១៦ នាឡិ ចុះមកនៅត្រឹមតែអង្ករ ១ នាឡិប៉ុណ្ណោះ ក៏សុខស្រួលស្រាលព្រះកាយមិនលំបាកដូចមុន, ថ្ងៃក្រោយមក ទ្រង់ស្តេចយាងទៅគាល់ព្រះពុទ្ធជាម្ចាស់ទៀត ហើយក្រាបទូលអត្ថថា សូមទ្រង់ព្រះមេត្តាប្រោស, ឥឡូវ ខ្ញុំព្រះអង្គមានសុខភាពស្រួលក្នុងខ្លួនណាស់ បើទុកជារត់តាមសេះ ឬដំរីដែលលឿន ក៏អាចរត់តាមទាន់បានដែរ ។ នេះឯងបញ្ជាក់ឲ្យឃើញថា ការបរិភោគតិចល្មមសមគួរមិនច្រើនពេក មិនតិចពេកនេះ អាចធ្វើរាងកាយឲ្យមានសុខភាពស្រួល កាលបើរាងកាយប្រព្រឹត្តទៅបានស្រួលហើយ អាយុក៏បានវែងផងដែរ ។

៤– ត្រង់ពាក្យថា ត្រាច់ដើរក្នុងកាលគួរ ឬប្រព្រឹត្តធ្វើការក្នុងកាលគួរ នោះ បានសេចក្តីថា ការដើរលេងក្តី ការដើរដោយមានកិច្ចការអ្វីក្តី គួរដើរក្នុងកាលគឺកំណត់ឲ្យដឹងថា ពេលថ្មើរនេះគួរដើរកំសាន្តបាន, ពេលថ្មើរនេះគួរឈប់សម្រាក, ពេលថ្មើរនេះគួរដេក; មិនដើរលេងជ្រកមមកក្នុងទីកៀនកោះហួសពេលវេលា ដែលជាហេតុនាំឲ្យជួបប្រទះនឹងគ្រោះថ្នាក់ ឬអន្តរាយណាមួយឡើយ ។ ការប្រព្រឹត្តធ្វើកិច្ចការអ្វីផ្សេងៗ ទោះការរៀនសូត្រក្តី ធ្វើការងារណាមួយក្តី ក៏គួរកំណត់ពេលតាមកាលគួរដែរ គឺកំណត់ឲ្យដឹងថា ពេលនេះគួររៀនឬធ្វើការ, ពេលនេះគួរឈប់សម្រាក, ពេលនេះគួរដេក;

មិនត្រូវធ្វើការងារ ឬរៀនសូត្រខ្លាំងពេកហួសពេលវេលា ដែលជាហេតុនាំឲ្យកើតរោគនោះឡើយ បើប្រព្រឹត្តធ្វើការងារ ឬរៀនសូត្រជាដើមចេះលៃលកតាមកាលគួរហើយ, រាងកាយយើងក៏មានសុខភាពស្រួលល្អ កាលបើរាងកាយបរិបូណ៌ដោយសុខភាពហើយ, អាយុក៏បានវែងផងទៀត ។

៥– ត្រង់ពាក្យថា ប្រព្រឹត្តធម៌ដ៏ប្រសើរ គឺមិនល្មោភក្នុងកាម នោះ បានសេចក្ដីថា ធម្មតាមនុស្សអ្នកបរិភោគកាម រមែងបណ្ដោយចិត្តឲ្យកើតកើនល្មោភក្នុងកាម ស្រវឹងជាប់ចិត្តក្នុងកាម នាំឲ្យខូចការងារដែលត្រូវធ្វើ, ខូចការរៀនសូត្រ, ខូចពេលត្រូវសម្រាក ឬពេលត្រូវដេកពួនទាំងអស់, ម្យ៉ាងហើយក៏ជាហេតុនាំឲ្យកើតរោគផ្សេងៗប្រចាំនៅក្នុងកាយ ទៅជាមនុស្សពិកពិការក៏មាន ។ ផ្ទុយពីនេះទៅវិញ អ្នកដែលមិនល្មោភក្នុងកាម មិនស្រវឹងជាប់ចិត្តក្នុងកាមទេ ច្រើនជាមនុស្សមិនសូវមានរោគ, បរិបូណ៌ដោយសុខភាព កាលបើរាងកាយមានសុខភាពល្អ អាយុក៏អាចប្រព្រឹត្តទៅបានវែងដែរ ។

សេចក្ដីដែលបានអធិប្បាយមកដូចខាងលើនេះ ហាក់ដូចជាបដិសេធកម្មគឺកុសលនិងអកុសលពីអតីតចោលទាំងអស់ មិនឃើញមាននិយាយដល់ផង ។ អាយុរបស់មនុស្សសត្វដែលវែង - ខ្លីនោះ ក្រែងផលកម្មពីអតីតកម្រិតទុកឲ្យមកមិនមែនទេឬ ? បើទុកជាផលកម្មពីអតីតកម្រិតទុកឲ្យមកមានមែនក៏ដោយ ប៉ុន្តែបើគេប្រុងប្រយ័ត្នការពារខ្លួនដោយវិធីគ្រប់យ៉ាងទៅ ក៏អាចការពារបញ្ចៀសផលកម្មនោះមិនឲ្យចូលមកជ្រៀតជ្រែកបានខ្លះដែរ ព្រោះកម្មពីអតីតអាស្រ័យនឹងកម្មបច្ចុប្បន្ន វៀរលែងតែកម្មពីអតីតនោះមានកម្លាំងធ្ងន់ពេក ទើបគេពុំអាចនឹងការពារបាន សមដូចពាក្យគេតែងនិយាយថា ចោរក្រៅស្រុកដែលវាហ៊ានចូលមកប្លន់ ពីព្រោះមានចោរក្នុងស្រុកវាឲ្យដៃ, ខ្មោចបិសាចវាហ៊ានចូលធ្វើមកពីខ្លួនឯងមានគ្រោះ, សត្វរុយវាតាមចោមរោម មកពីខ្លួនមានរបួស យ៉ាងនេះជាដើម ។ បើយើងប្រុងប្រយ័ត្នមិនធ្វេសប្រហែស, ការពាររក្សាខ្លួនដោយវិធីអនាម័យគ្រប់យ៉ាង ឬយើងប្រព្រឹត្តបំពេញកុសលធម៌ផ្សេងៗ មាន **អបចាយនធម៌** ជាដើមឲ្យកើតមានគ្រប់គ្រាន់ហើយ, ការប្រុងប្រយ័ត្ននិងកុសលធម៌នោះ ជាកម្លាំងមួយអាចជួយការពារពាំង ឬបញ្ចៀសនូវវិបត្តិអន្តរាយទាំងឡាយ គឺកម្មពីអតីត ឬកម្មបច្ចុប្បន្នបានខ្លះដែរ, ពុំនោះសោត ដូចមនុស្សខ្លះប្រព្រឹត្តធ្វើបាបកម្មដ៏អាក្រក់ក្រៃលែងក្នុងបច្ចុប្បន្ន ហើយបាបកម្មនោះរកឱកាសចូលមកជ្រៀតជ្រែកបៀតបៀនឲ្យផលពុំកើត ខ្លួនគេក៏នៅតែបានសុខ - ចម្រើនរុងរឿង គួរឲ្យអ្នកផងគោរពសរសើរថែមទៀត, ត្រង់នេះអ្នកមានវិចារណញ្ញាណគួរសន្និដ្ឋានថា មនុស្សនោះឯង មាន **បយោគសម្បត្តិ** (ការដល់ព្រមដោយប្រយោគ) គឺចេះលៃលក

ទុកដាក់ខ្លួនតម្រូវតាមកាលៈទេសៈ គឺគេដឹងថា សម័យនេះគួរទទួលសំណូក សម័យនេះគួរចៀសវាង, សម័យនេះគួរគេចខ្លួនថយចេញ, សម័យនេះគួរចូលខ្លួនមកប្រាស្រ័យទាក់ទងអែបអបយ៉ាងនេះជាដើម កាលបើគេមានបយោគសម្បត្តិគ្រប់គ្រាន់ហើយ គេក៏អាចចៀសវាងផុតពីវិបត្តិអន្តរាយដែលបណ្ដាលមកអំពីបាបកម្មនោះបានខ្លះដែរ, ផែកខាងកុសលកម្មវិញ ក៏ដូចគ្នា បើគេបានប្រព្រឹត្តបំពេញកុសលកម្មផ្សេងៗ មានការឲ្យទាន រក្សាសីលជាដើម ឬគេបានធ្វើ អភិវាទនកម្ម និង វុឌ្ឍាបចាយនកម្ម មានគ្រប់គ្រាន់ហើយ, កុសលកម្មនោះឯង អាចជួយការពារកំចាត់បំបាត់ចៀសនូវផលកម្មពីអតីតឬបច្ចុប្បន្ននេះបានខ្លះដែរ សមដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់សម្ដែងថា :

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ

ប្រែថា ធម៌ទាំង ៤ យ៉ាងគឺ អាយុ ១ ពណ៌សម្បុរកាយ ១ សេចក្ដីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ចដល់បុគ្គលដែលមានសេចក្ដីឱនកាយថ្វាយបង្គំ ចំពោះព្រះរតនត្រ័យជាប្រក្រតី និង បុគ្គលដែលមានសេចក្ដីគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ ។

សូមអធិប្បាយវែកញែកសេចក្ដីកង់ពុទ្ធភាសិតខាងលើនេះ ដោយសង្ខេបថា បុគ្គលណា ជាអ្នកឧស្សាហ៍យកចិត្តទុកដាក់ថ្វាយបង្គំគោរពរឿយៗចំពោះព្រះរតនត្រ័យគឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ បុគ្គលនោះរមែងចម្រើនដោយធម៌ទាំង ៤ យ៉ាង មានអាយុជាដើម, មួយយ៉ាងទៀត បុគ្គលណា បើជាគ្រហស្ថ បានបូជា បានធ្វើសេចក្ដីគោរពកោតក្រែង ដោយកាយ វាចា ចិត្ត ចំពោះភិក្ខុ ឬសាមណេរដែលទើបនឹងបួសបានមួយថ្ងៃ ឬបួសយូរហើយក្ដី ចំពោះមាតាបិតា ឬអ្នកដទៃដែលបរិបូណ៌ដោយគុណមានសីលគុណជាដើមក្ដី, បើជាបព្វជិតវិញ បានធ្វើសេចក្ដីគោរពកោតក្រែងដោយកាយ វាចា ចិត្ត ចំពោះបព្វជិតផងគ្នា ដែលលោកចាស់ទុំជាងដោយបព្វជ្ជា ឬ ដោយឧបសម្បទាក្ដី ចំពោះលោកដែលបរិបូណ៌ដោយគុណមានសីលគុណជាដើមក្ដី បុគ្គលនោះ រមែងចម្រើនដោយធម៌ទាំង ៤ យ៉ាងមានអាយុជាដើម ព្រោះធម៌ទាំង ៤ យ៉ាងនោះ រមែងប្រាស្រ័យទាក់ទងដល់គ្នានិងគ្នា, កាលបើអាយុចម្រើនតាំងនៅអស់កាលត្រឹមណា ធម៌ទាំង ៣ គឺ វណ្ណៈ សុខៈ ពលៈ ក៏រមែងចម្រើនតាំងនៅអស់កាលត្រឹមនោះដែរ ។

មួយយ៉ាងទៀត បុគ្គលណា បានធ្វើបុណ្យកុសលដើម្បីអាយុរបស់ខ្លួនប្រព្រឹត្តទៅបាន ៥០ ឆ្នាំ

លុះដល់អាយុរបស់បុគ្គលនោះប្រព្រឹត្តទៅទើបតែនឹងបាន ២៥ ឆ្នាំ សេចក្ដីអន្តរាយនៃជីវិតប្រុងនឹងកើតដល់បុគ្គលនោះ អំណាចនៃបុណ្យកុសលនោះ អាចជួយឧបត្ថម្ភការពារពាំងសេចក្ដីអន្តរាយនោះមិនឲ្យកើតឡើងបាន ហើយបុគ្គលនោះឯង ក៏មានអាយុប្រព្រឹត្តទៅរហូតដល់គ្រប់ ៥០ ឆ្នាំក៏មាន ដូចជា **អាយុវឌ្ឍនកុមារ** ជាកូនរបស់ព្រាហ្មណ៍ដែលកើតឡើងហើយ មានគ្រោះថ្នាក់ត្រូវស្លាប់ទៅវិញ ក្នុងអាយុទើបតែនឹងបាន ៧ ថ្ងៃ តែដោយអំណាចកុសលមានពិធីចម្រើនព្រះបរិត្តជាដើមនោះ ជួយឧបត្ថម្ភការពារកម្ចាត់នូវគ្រោះថ្នាក់នោះមិនឲ្យចូលមកបៀតបៀនបាន, **អាយុវឌ្ឍនកុមារ** នោះ ក៏បានកន្លងផុតពីគ្រោះថ្នាក់នោះ, អាចរស់នៅរហូតដល់ទៅអាយុ ១២០ ឆ្នាំទើបស្លាប់ នេះឯងជាឧទាហរណ៍ដើម្បីបញ្ជាក់ឲ្យដឹងថា ជីវិតរបស់សព្វសត្វដែលកំពុងប្រព្រឹត្តទៅច្រើនជួបប្រទះនឹងគ្រោះថ្នាក់អន្តរាយផ្សេងៗ ។ អន្តរាយនោះដែលនឹងកើតឡើងគឺបណ្ដាលមកអំពីបាបកម្មពីអតីតក៏មាន បណ្ដាលមកពីបាបកម្មបច្ចុប្បន្នក៏មាន, បណ្ដាលមកពីប្រមាទគឺសេចក្ដីធ្វេសប្រហែសរបស់ខ្លួនក៏មាន ព្រោះហេតុនោះ មនុស្សទាំងឡាយកុំធ្វេសប្រហែស ត្រូវតែប្រុងប្រយ័ត្នរក្សាខ្លួនដោយវិធីអនាម័យជាដើមផង ត្រូវតែបំពេញនូវការកុសលផ្សេងៗ ឲ្យកើតមានបរិបូណ៌ក្នុងខន្ធសន្តានផង ទើបអាចនឹងញុំាងអាយុរបស់ខ្លួនឲ្យប្រព្រឹត្តទៅបានវែង ។

ន័យមួយទៀត ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងសរសើរឥទ្ធិបាទធម៌ ៤ យ៉ាង គឺ **ឆន្ទៈ** គឺសេចក្ដីប៉ុនប៉ង ១ **វិរិយៈ** គឺសេចក្ដីព្យាយាមប្រឹងប្រែង ១ **ចិត្តៈ** គឺសេចក្ដីត្រិះរិះគិត ១ **វីមំសា** គឺប្រាជ្ញាចេះពិចារណាលៃលក ១ ។ ឥទ្ធិបាទធម៌ទាំង ៤ នេះ ជាធម៌មានឥទ្ធានុភាពច្រើន អាចញុំាងបុគ្គលដែលបានចម្រើន បានសន្សំ បានធ្វើឲ្យមានច្រើនប្រចាំនៅក្នុងខ្លួនជានិច្ចហើយ រមែងឲ្យសម្រេចតាមបំណងរបស់ខ្លួនបាន ដូចព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់ត្រាស់នឹងព្រះអានន្ទថា " ម្នាលអានន្ទ, បុគ្គលណាបានចម្រើនធម៌ឥទ្ធិបាទទាំង ៤ មានគ្រប់គ្រាន់ហើយ បុគ្គលនោះ បើប្រាថ្នាចង់ឲ្យអាយុរបស់ខ្លួនឋិតនៅអស់កប្ប ឬលើសពីកប្បទៅទៀត ក៏អាចឋិតនៅបានដូចសេចក្ដីប្រាថ្នា " ។ ពាក្យថា **កប្ប** ប្រែថា កម្រិត ឬថា កំណត់, **អាយុកប្ប** ប្រែថា កម្រិតនៃអាយុ ព្រោះអាយុនៃមនុស្សទាំងឡាយ សុទ្ធតែមានកំណត់ត្រឹមប៉ុណ្ណេះខ្លះ កំណត់ត្រឹមប៉ុណ្ណោះខ្លះ ដោយអំណាចកុសលនិងអកុសល ដែលជាអំពើរបស់ខ្លួនពីអតីតបានកម្រិតទុកមក ប៉ុន្តែមនុស្សទាំងឡាយ ច្រើនតែពុំអាចរក្សាអាយុរបស់ខ្លួនឲ្យចម្រើនឋិតនៅដល់កម្រិត ក៏អស់អាយុស្លាប់មុនកម្រិតនោះទៅក៏មាន ព្រោះហេតុនោះ មនុស្សទាំងឡាយ បើចង់ឲ្យអាយុរបស់ខ្លួនឋិតនៅបានយឺនយូរវែង ត្រូវប្រតិបត្តិតាមធម៌

ឥទ្ធិបាទទាំង៤ឲ្យបានគ្រប់គ្រាន់គឺ  មានសេចក្ដីស្រឡាញ់ជីវិត  ចង់តែរស់នៅឈ្មោះថាមានឥទ្ធិបាទទី ១ គឺ **ឆន្ទៈ**,  កាលបើមានសេចក្ដីស្រឡាញ់ពេញចិត្តហើយ  បានព្យាយាមរក្សាឥរិយាបថគឺដើរ ឈរ អង្គុយ ដេក  ឲ្យប្រព្រឹត្តទៅស្មើល្អ ឬ អ្វីមួយមានអាហារជាដើមជាគ្រឿងនាំឲ្យទំនាស់ដល់ការប្រព្រឹត្តទៅស្រួលនៃជីវិត  ក៏ព្យាយាមលះបង់ចោលចេញភ្លាម  ឈ្មោះថាមានឥទ្ធិបាទទី២ គឺ **វិរិយៈ**,  ការត្រិះរិះគិតពិនិត្យមើលក្នុងដំណើរដែលប្រព្រឹត្តទៅនៃជីវិតពល់វេលា  ឥតឲ្យមានធ្វេសប្រហែស  ពេលស្រួលក៏ដឹង  ពេលមិនស្រួលក៏ដឹង  ឈ្មោះថាមានឥទ្ធិបាទទី ៣ គឺ **ចិត្តៈ**,  ប្រាជ្ញាពិចារណារកហេតុ ឬសមុដ្ឋានឲ្យដឹងថា  ស្រួលនិងមិនស្រួលនោះ  ឲ្យឃើញច្បាស់ថា  មិនស្រួលមកពីអ្វីក៏លះបង់ចោលភ្លាម,  មិនស្រួលមកពីអ្វីក៏ប្រតិបត្តិធ្វើតាមភ្លាម  ឈ្មោះថាមានឥទ្ធិបាទទី៤ គឺ **វីមំសា** ។

ធម៌ឥទ្ធិបាទទាំង៤ យ៉ាងដូចបានពោលមកហើយនោះ  មិនមែនឲ្យបានសម្រេចត្រឹមតែអាយុវែងម្យ៉ាងប៉ុណ្ណោះទេ  ទោះបីធ្វើរបរ ឬកិច្ចការងារផ្សេងៗ ដើម្បីសន្សំទ្រព្យសម្បត្តិក្ដី  កិច្ចការខាងសិក្សារៀនសូត្រដើម្បីឲ្យមានចំណេះចេះដឹងក្ដី  កិច្ចការខាងប្រតិបត្តិតាមធម៌  មានការឲ្យទានរក្សាសីលជាដើម ឬ ប្រតិបត្តិដើម្បីឲ្យបានគុណវិសេសគឺ ឈាន សមាបត្តិ ឬ មគ្គផលជាន់ខ្ពស់ក្ដី  បើបានប្រតិបត្តិបំពេញធម៌ឥទ្ធិបាទទាំង ៤ ឲ្យមានគ្រប់គ្រាន់ហើយ  ក៏សុទ្ធតែបានសម្រេចដល់ទីបំផុតតាមគោលបំណងរបស់ខ្លួន  ពុំមានឃ្លៀងឃ្លាតឡើយ !

ព្រះសាសនមុនី ភិម - តូរ
វត្តឧណ្ណាលោម

# សេចក្ដីព្យាយាម

## វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា

"បុរសស្ត្រីគ្រប់រូបត្រូវតែប្រឹង តាំងព្យាយាម ត្រាតែសម្រេចប្រយោជន៍គ្រប់យ៉ាង" ។

ពុទ្ធភាសិតខាងលើនេះ បង្ហាញឲ្យឃើញថា កិច្ចការគ្រប់បែបសព្វយ៉ាង ក្នុងលោកនេះ អាចនឹងសម្រេចទៅបាន គឺដោយសារសេចក្ដីព្យាយាមការប្រឹងប្រែង ។ បុគ្គលណាមានសេចក្ដីព្យាយាមម៉ឺងម៉ាត់ ទោះនឹងធ្វើកិច្ចការអ្វីៗ ឬរៀនសូត្រវិជ្ជាអ្វីៗ គង់នឹងសម្រេចតាមបំណងពុំខាន ព្រោះកិច្ចការងារ ឬចំណេះវិជ្ជាអ្វីៗក៏ដោយ កាលបើបុគ្គលណាមួយ មានសេចក្ដីប្រាថ្នា ការប៉ុនប៉ង ចង់ធ្វើ ចង់រៀន ចង់ប្រកប ចង់ចេះ ចង់ដឹង ហើយតាំងព្យាយាមយ៉ាងមុតមាំ តាំងចិត្តយ៉ាងម៉ឺងម៉ាត់ ខំប្រឹងធ្វើ ខំប្រឹងរក ខំប្រឹងរៀន ខំប្រឹងប្រព្រឹត្ត ដោយពុំមានបណ្ដែតបណ្ដោយបណ្ដោះដៃ បុគ្គលនោះឯងរមែងសម្រេចសមតាមគោលបំណងរបស់ខ្លួនយ៉ាងទៀងទាត់ពិតប្រាកដ ។

អ្នកប្រាជ្ញទាំងឡាយជាច្រើនរូប មានទស្សនវិទូ វិទ្យាវិទូ និងគណិតវិទូ ជាដើម បានខំព្យាយាមរិះរកវិធី និងមធ្យោបាយគ្រប់បែបយ៉ាង បង្កើតជាក្បួនច្បាប់ផ្សេងៗ សម្រាប់យកទៅអនុវត្ត បង្កើតគ្រឿងប្រដាប់ប្រើប្រាស់គ្រប់បែបយ៉ាង បង្កើតគ្រឿងម៉ាស៊ីនគ្រប់ចំពូក មានម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនកិនស្រូវ, កិនពោតជាដើម, បង្កើតជាយន្តយានផ្សេងៗ មានរថយន្តនិងទោចក្រយានជាដើម និងបង្កើតសម្ភារៈសំណង់ស្ថាប័នផ្សេងៗ ។ ជាពិសេសអ្នកប្រាជ្ញទាំងនោះ បានរិះរកវិធីការពាររោគ បង្កើតក្បួនអនាម័យ និងវិធីពេទ្យ ព្រមជាមួយនេះ បានផលិតឧសថ ថ្នាំសង្កូវ សម្រាប់ព្យាបាលរោគគ្រប់ចំពូក ព្រោះរោគាព្យាធិនេះជាឧបសគ្គមួយដ៏ធំបំផុត សម្រាប់ជីវិតមនុស្សគ្រប់រូប ។ ឯការមិនមានរោគចាត់ជាមហាលាភមួយដ៏ប្រសើរវិសេស "អារោគ្យបរមា លាភា ។ល។

វត្ថុសម្ភារៈទាំងឡាយគ្រប់បែបយ៉ាង ដែលមាននៅក្នុងលោក ដូចជាវិទ្យុ វិទ្យុទូរទស្សន៍ រថយន្តជាដើម ដែលយើងគ្រប់គ្នាប្រើប្រាស់ពល់ថ្ងៃនេះ គឺសុទ្ធតែជាលទ្ធផល កើតចេញមកអំពីសេចក្ដីព្យាយាម ការខំប្រឹងប្រែងរិះរក របស់អ្នកប្រាជ្ញ ។

ដូច្នេះ សេចក្ដីព្យាយាមគឺការខំប្រឹងធ្វើ ខំប្រឹងគិត ខំប្រឹងរក ខំប្រឹងរៀននេះ ជាគុណធម៌មួយដ៏ប្រសើរណាស់ ទាំងជាមធ្យោបាយមួយដ៏រស់រវើក អាចជួយមនុស្សឲ្យសុខស្រួល ប្រាសចាកទុក្ខទោសគ្រប់យ៉ាង ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គខំកសាងសេចក្ដីព្យាយាមនេះជាអតិបរមា ដោយព្រះអង្គខំតស៊ូពុះពារ

គ្រោះថ្នាក់ឧបសគ្គនានាជាច្រើន ក្នុងរយៈកាលកំពុងកសាងបារមី ដូចជា កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ បានយោនយកកំណើតកើតជាព្រះមហាជនក ។ ព្រះអង្គបានខំប្រឹងតស៊ូហែលឆ្លងមហាសមុទ្រដ៏ធំធេងរកមើលកោះត្រើយពុំឃើញ ដោយមានព្រះទ័យដ៏រឹងប៉ឹង ប្រកបដោយសតិសម្បជញ្ញៈ និងសេចក្ដីក្លាហាន លុះត្រាតែទេវតាជួយឧបត្ថម្ភឲ្យបានដល់ត្រើយយ៉ាងឆាប់ ព្រមទាំងបានទៅជាមហាក្សត្រសោយរាជ្យថែមទៀត ។

និទាននេះ សបញ្ជាក់ឲ្យឃើញថា ជីវិតគឺការតស៊ូ ហើយដើម្បីនឹងរក្សាជីវិតឲ្យបានប្រកបដោយសេចក្ដីសុខស្រួល ដើម្បីនឹងចង់ឲ្យផុតអំពីភ័យអន្តរាយ និងដើម្បីបំបាត់ចោលចេញនូវសេចក្ដីទុក្ខលំបាកនោះ មនុស្សម្នាក់ៗ ត្រូវតែខំប្រឹងតស៊ូ ពុះពារឧបសគ្គនានា ត្រាតែបានឈ្នះ សម្រេចតាមបំណង ។ មិនតែប៉ុណ្ណោះ សូម្បីតែទេវតាក៏ជួយស្រោចស្រង់ ជួយយឹតយោង ជួយឧបត្ថម្ភ ជួយសង្គ្រោះចំពោះអ្នកមានព្យាយាមខំប្រឹងតស៊ូនេះថែមទៀត ដូចជាព្រះមហាជនកជាដើម ។

ព្រះពុទ្ធទ្រង់ត្រាស់ថា "**វីរិយេន ទុក្ខមច្ចេតិ** មនុស្សគ្រប់គ្នាអាចឆ្លងផុតអំពីសេចក្ដីទុក្ខបាន ក៏ដោយសារសេចក្ដីព្យាយាម ខំប្រឹងតស៊ូ" ។

យើងគ្រប់គ្នា ទាំងប្រុស ទាំងស្រី ទាំងក្មេង ទាំងចាស់ ដែលបានកើតមកលើផ្ទៃពិភពលោកនេះ គឺជាភ័ព្វវាសនាមួយដ៏ធំណាស់ ។ ដូច្នេះ គប្បីកុំប្រមាទ កុំប្រហែសធ្វេសឲ្យសោះ ព្រោះការប្រហែស-ធ្វេស ការខ្ជិលច្រអូស នឹងនាំឲ្យយើងវិនាសហិនហោច នាំឲ្យស្លាប់ដូចសុភាសិតថា "ប្រហែសបាត់ ប្រយ័ត្នគង់, ប្រហែសស្លាប់ ប្រយ័ត្នរស់" ជាដើម ។ បានសេចក្ដីថា យើងគ្រប់ៗគ្នាត្រូវតាំងព្យាយាមយ៉ាងមុឹងម៉ាត់ ជា **សម្មាវាយាមៈ** គឺព្យាយាមខំប្រឹងតស៊ូត្រូវទំនង ត្រូវបែបបទត្រូវគន្លង ។ ព្រោះថា ព្យាយាមត្រូវទំនង ត្រូវបែបនេះ អាចធ្វើអ្នកដែលកាន់ប្រព្រឹត្តប្រតិបត្តិឲ្យបានសម្រេចប្រយោជន៍គ្រប់យ៉ាង ព្រមទាំងអាចប្ដូរខ្លួនឲ្យបានទៅជាអ្នកមានទ្រព្យសម្បត្តិ ទៅជាគហបតី ឬទៅជាអ្នកប្រាជ្ញ បណ្ឌិត ពហុស្សូត និងបញ្ញវន្ត ។ ជាពិសេស គេអាចបំបាត់សេចក្ដីទុក្ខលំបាកគ្រប់បែបយ៉ាង ដែលបណ្ដាលមកពីក្រពះធ្វើទុក្ខបុកម្នេញ ធ្វើឲ្យចិត្តក្រៀមក្រំស្រងេះស្រងោច ស្លត-ស្ងាត់ សញ្ជប់សញ្ជឹងឲ្យឃ្លាតឆ្ងាយពីខ្លួន ក៏ដោយសារសេចក្ដីព្យាយាម ខំប្រឹងធ្វើ ខំប្រឹងរក ខំប្រឹងរៀន ដូចសុភាសិតថា "ចេះពីរៀន មានពីរក" ។

ហេតុនេះ យើងគ្រប់គ្នាត្រូវតែព្យាយាម ខំប្រឹងតស៊ូកុំរួញរា កុំគប្បីធ្វេសប្រហែសចំពោះកិច្ចការគ្រប់យ៉ាង ។

ភិក្ខុសីលានន្ទ ឈាច-នៃសុត ហៅ សេចលី

# សំឡេងពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ

ពត៌មានផ្សាយតាមសំឡេងវិទ្យុជាតិ លើកទី ៥ ពីថ្ងៃទី ១៤ មិថុនា ព. ស. ២៥១១ / គ. ស. ១៩៦៧

កម្មវិធីនៃការផ្សាយរបស់យើងនៅពេលនេះ ព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ អស់លោក-អ្នកនាងជាទីមេត្រីទាំងឡាយ នឹងបានស្ដាប់

១- អំពីការបង្កើតភ្លេងពិណពាទ្យពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ

២- អំពីសកម្មភាពគណៈកម្មាធិការនាយកនៃពុទ្ធិកសមាគម កម្ពុជរដ្ឋ ក្នុងស្រុកនានា

៣- អំពីប្រាក់កាគទាន និង ប្រាក់អំណោយ ។

អត្ថបទអត្ថាធិប្បាយ :

## ១– អំពីការបង្កើតភ្លេងសម្រាប់ ពុ. ម. ក.

ព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ អស់លោក-អ្នក នាងជាទីមេត្រី, គណៈកម្មការខាងការផ្សាយរបស់ពុ.ម.ក. បានចាប់អារម្មណ៍ទៅលើសិល្បៈផ្នែកភ្លេងបានពិគ្រោះគ្នាថា គួរបង្កើតឲ្យមានភ្លេងមួយវង់សម្រាប់ពុ. ម. ក. ។ ទីបាត់យើងបានទៅទាក់ទងផ្ទាល់នឹងសហជីវិន ព្រហ្មវីរៈ ជាលេខាធិការផ្ទាល់នៅក្រសួងហិរញ្ញវត្ថុ ឲ្យជួយបង្កើតភ្លេងមួយវង់សម្រាប់ពុ. ម. ក. ។ សហជីវិនរូបនេះបានមានឆន្ទៈល្អជួយប្រឹងអស់សមត្ថភាព រកសមាជិកបានចំនួនច្រើនរូប ដែលចេះគ្រឿងភ្លេងស្រាប់ៗផង ឲ្យចូលមករួបរួមហាត់ហ្វឹកហ្វឺនកើតបានជាភ្លេងមួយវង់ ឲ្យនាមថា **ភ្លេងពិណពាទ្យពុទ្ធិក-សមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ** ។ ក្រុមភ្លេងនេះ ដឹកនាំដោយសហជីវិន ព្រហ្មវីរៈ លេខាធិការផ្ទាល់នៅក្រសួងហិរញ្ញវត្ថុ ។ រីឯសមាសភាពនៃក្រុមភ្លេងនេះ មានដូចតទៅ ៖

| | | | | |
|---|---|---|---|---|
| ១– | សហជីវិន | ខៅ - សុន | កាន់ | រនាតឯក |
| ២– | " | ពេជ - សែម | — | — ធុង |
| ៣– | " | ឌី - វិសេដ្ឋ | — | — ដែក |
| ៤– | " | ភិន - វឿន | — | គងតូច |
| ៥– | " | អ៊ុម - ប្រង់ | — | — ធំ |
| ៦– | " | អ៊ុម - ពុត | — | សម្ភោរ |
| ៧– | " | ងិន - ជួន | — | ស្គរធំ |

៨– សហជីវិន សែម-សី កាន់ ស្រឡៃ

៩– " ព្រហ្ម-វណ្ណគុល – ឈើង ។

ក្មេងនេះ បានចាប់បដិសន្ធិនិងបានផ្សាយតាមវិទ្យុជាតិ តាំងពីថ្ងៃទី ៣១-៥-៦៧ មកម៉្លេះ ។ ក្រុងនាមគណៈកម្មាធិការនាយក និងក្នុងនាមគណៈកម្មការខាងការផ្សាយ មានបីតិប្រាមោទ្យឥតឧបមា ចំពោះសមាជិកក្រុមក្មេងពិណពាទ្យនេះ ដែលបានជួយឧបត្ថម្ភខាងផ្នែកផ្សាយអង្គការពុ. ម. ក. មានឈ្មោះលេចនាមជ្រួតជ្រាបផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅ តាមសំឡេងក្មេងពិណពាទ្យនេះ ។

សូមសមាជិកក្រុមក្មេងពិណពាទ្យពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ បានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ មានប្រសិទ្ធិភាព មានចិរកាលអស់កាលជានិច្ចនិរន្តរ៍តទៅ ។

## ២– អំពីសកម្មភាពគណៈកម្មាធិការនាយក ក្នុងស្រុកនានា

## ក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង.–

កាលពីថ្ងៃទី ៨ ខែកុម្ភៈ ១៩៦៧, គណៈបេសកកម្មមួយក្រុម ក្រោមការដឹកនាំនៃសហជីវិន សូ-ណៃម ប្រធាន ដោយមានសមាជិកជាច្រើនរូប បានអញ្ជើញទៅជាមួយផង គឺ

– សហជីវិន អេង សុត
– " កុង នួន
– " សម ចាំង
– " ឈឹម ស៊ុម
– សហជីវិន អ៊ុក ជី
– " តា ប៊ុនឡុង និង
សហជីវិន ឌុម ខែម ជាបុគ្គលិកការិយាល័យ ។

នៅម៉ោង ១៦,៣០នាទី ប្រតិភូនៃគណៈបេសកកម្ម បានទៅដល់វត្តកុលម្ពវ័ន ហៅវត្តតាកុល សង្កាត់ពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាវត្តនៃព្រះគ្រូធម្មធរជិនបុត្ត អនុគណស្រុកកំពង់ត្រឡាច ដើម្បីចូលរួមបួសរួមក្នុងឱកាសអនុស្សាវរីយ៍សន្និបាតទី២៣ នៃលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ ឆ្វេងផង ដើម្បីឃោសនាពន្យល់អំពីអង្គការពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋផង ។

ក្រោយពីការបានក្រាបថ្វាយបង្គំ និងបានថ្លែងអំណរគុណចំពោះទីប្រជុំ ដែលមានព្រះគ្រូធម្មធរជិនបុត្ត ជាប្រធានគណៈសង្ឃសន្និបាតរួចហើយ, គណៈបេសកៈយើងត្រូវបានទទួលសេចក្តីអនុញ្ញាតពីទីប្រជុំ ដើម្បីធ្វើបាឋកថា ជាបឋម សហជីវិន ឈឹម-ស៊ុម បានណែនាំព្រះសង្ឃ-ពុទ្ធ-

បរិស័ទទាំងអស់ ឲ្យស្គាល់នាមគណៈកម្មាធិការនាយកសម្រាប់ឆ្នាំ ១៩៦៧ រួចហើយទើបសហជីវិន សូ-ណែម ប្រធាននៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ ថ្លែងរៀបរាប់ប្រគេន និងជូនពត៌មានស្ដីពីប្រវត្តិនៃពុទ្ធិកសមាគមពិភពលោក ដែលបានកើតឡើងជាដំបូងនៅទីក្រុងកោលម្បូ ប្រទេសស្រីលង្កា ដោយមានគណៈប្រតិភូចំនួន ២៩ ប្រទេស គិតទាំងប្រទេសខ្មែរយើងផង បានចូលទៅរួបរួមប្រជុំពីឆ្នាំ ១៩៥០ ដល់មកឆ្នាំ ១៩៥២ ប្រទេសយើងបានបង្កើតពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ ដោយការជួយឧបត្ថម្ភនៃសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ គណៈមហានិកាយ ស្ថិតនៅក្រោមព្រះបរមរាជូបត្ថម្ភ និងព្រះបរមរាជាធិបតីភាពនៃសម្ដេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង ដោយមានព្រះរាជក្រឹត្យលេខ ២២៤ កបរន ចុះថ្ងៃទី ៣ មិថុនា ១៩៦០ បានទទួលស្គាល់ថា ជាសមាគមមានប្រយោជន៍ជាសាធារណៈ ។ តមក សហជីវិន ប្រធានបានលើកយកគោលបំណង និងកម្មវត្ថុនៃសមាគមត្រង់ចំណុចនីមួយៗមកអធិប្បាយពន្យល់ប្រគេន និងជម្រាបទីប្រជុំស្ដាប់យ៉ាងក្បោះក្បាយ មិនតែប៉ុណ្ណោះ សហជីវិន បានធ្វើអត្ថាធិប្បាយប្រៀបធៀបព្រះពុទ្ធសាសនា ទៅនឹងសាសនាដទៃទៀត មានគ្រិស្ដសាសនាជាដើម ឲ្យឃើញថា តើសាសនាណាមានខ្លឹមសារជាងសាសនាណា, ការប្រៀបធៀបពីសាសនាមួយទៅសាសនាមួយ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាមានខ្លឹមសារជាងសាសនាដទៃឯទៀតៗ ព្រោះព្រះពុទ្ធសាសនាមានទីដៅល្អបំផុត គឺព្រះនិព្វានជាពិសេស ព្រះពុទ្ធអង្គបានបង្ហាញមាគ៌ា ៤ យ៉ាង សម្រាប់មនុស្សលោកដើរតាម និងប្រតិបត្តិតាមគឺ ទុក្ខសច្ច, មគ្គសច្ច, សមុទយសច្ច និង និរោធសច្ច ។

សហជីវិន សូ-ណែម ប្រធាន បានលើកយកចំណុចមួយមកចោទ និងដោះស្រាយថា តើ ពុ.ម.ក. បង្កើតឡើងដើម្បីអ្វី ? ដើម្បីមនុស្សលោក និងដើម្បីធ្វើឲ្យមនុស្សលោកមានឯកភាព សាមគ្គីភាព និងភាតរភាព ជាពិសេស ងាយស្រួលដល់ការទាក់ទងជាអន្តរជាតិ រវាងសហព័ន្ធពុទ្ធសាសនិកក្នុងពិភពលោក ។

ក្នុងករណីនេះ ព្រះសង្ឃដែលជាកូនចៅព្រះពុទ្ធផ្ទាល់នោះ ត្រូវមានភារៈ ២ យ៉ាងគឺ

–គសាងសីល ទាន ភាវនា ។ ជាចាំបាច់ត្រូវសិក្សារៀនសូត្រឲ្យចេះដឹងច្រើនមែនទែន ។ កាលបើចេះដឹងច្រើនហើយ អាចនឹងអប់រំកាយ វាចា ចិត្តឲ្យបានល្អ តាមមាគ៌ាដែលព្រះពុទ្ធទ្រង់បានត្រាយទុក អាចរកសុខ សុភមង្គលវិបុលសុខគ្រប់យ៉ាងសម្រាប់អាត្មាផង សម្រាប់ព្រះពុទ្ធសាសនាផង ។

– ត្រូវផ្សាយនូវព្រះពុទ្ធវាទ ដែលជាទ្រឹស្តីល្អ ឲ្យបានរីកសាយភាយទៅក្នុងសាកលលោក ឲ្យចូលជាអង្គការអន្តរជាតិ ។

ចំណុចនេះហើយ ដែលពុ.ម.ក. បង្កើតឡើងសម្រាប់ជាកម្លាំងជួយលើកតម្កើងព្រះពុទ្ធសាសនា ឲ្យបានរីកចម្រើនគ្រប់ទិសានុទិស ។ កាលបើព្រះពុទ្ធសាសនាបានរីកចម្រើនក្នុងលោក, មនុស្សលោកនឹងចេះដឹងយល់ច្បាស់នូវមាគ៌ាសម្រាប់ស្វែងរកសុខ ចេះយោគយល់គ្នា ពិភពលោកទាំងមូលនឹងស្គាល់តែសុខសន្តិភាពតែម្យ៉ាង ។

ដើម្បីគាំទ្រ និងដើម្បីញុំាងព្រះពុទ្ធសាសនាឲ្យមានចិរកាល មានវឌ្ឍនភាពជឿនលឿនទៅមុខបាននោះ ពុ.ម.ក. ដែលមានខ្ញុំព្រះករុណា ខ្ញុំបាទ (ស៊ូ ណែម) ជាប្រធាន សូមពឹងផ្អែកលើទឹកព្រះទ័យ លើទឹកចិត្ត ព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ ពុទ្ធបរិស័ទទាំងអស់ ក្រោមការដឹកនាំនៃព្រះគ្រូធម្មធរជិនបុត្ត អនុគណ សូមមេត្តាចាប់អារម្មណ៍ទៅលើពុ.ម.ក. មេត្តាជួយទ្រទ្រង់អង្គការនេះ ដោយជួយផ្តល់ភាគទានឲ្យទាន ។

បន្ទាប់មក សហជីវិន អ៊ុក-ជី បានពន្យល់ជូនទីប្រជុំស្តាប់បានជ្រាបនូវឋានៈសមាជិក សមាជិការបស់ពុ.ម.ក. ដោយត្រួសៗថា ឋានៈសមាជិក សមាជិការបស់ពុ.ម.ក. មានច្រើនប្រភេទ តែប្រភេទដែលគេនិយមច្រើនគ្នាគឺ កម្មិកសមាជិក ។ សមាជិកប្រភេទនេះ ត្រូវបង់ប្រាក់ភាគទានសម្រាប់ហិបពុ.ម.ក. ១២០៛ ក្នុងមួយឆ្នាំ ។ សហជីវិន អ៊ុក-ជី សុំឲ្យព្រះគ្រូធម្មធរជិនបុត្ត ជាប្រមុខសង្ឃក្នុងស្រុកកំពង់ត្រឡាចនេះ មេត្តាជួយធ្វើអន្តរាគមន៍ដោយវិធីណែនាំព្រះសង្ឃជាចៅអធិការទាំងអស់ឲ្យជួយពុ.ម.ក. គឺសុំនាមវត្តទាំងអស់ចូលជាកម្មិកសមាជិក ផ្តល់ភាគទានរៀងរាល់ឆ្នាំ ១២០៛ មួយឆ្នាំ ។

តើប្រាក់នេះ យកទៅចំណាយសម្រាប់អ្វីខ្លះ ?

១១– ចំណាយសម្រាប់ទាក់ទងជាអន្តរជាតិ រវាងប្រទេសជាសហព័ន្ធពុទ្ធសាសនិកក្នុងពិភពលោក

១២– ចំណាយសម្រាប់ផ្តល់អាហារូបករណ៍ ឲ្យវរជនដែលចង់ទៅបំពេញវិជ្ជាជាន់ខ្ពស់ នៅឯបរទេស ។ (សព្វថ្ងៃនេះ ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ បានផ្តល់អាហារូបករណ៍ប្រគេនសមណនិស្សិត ២ រូបនៅមហាវិទ្យាល័យ ពូណា និងនៅមហាវិទ្យាល័យសំស្ក្រឹតក្រុង ពារាណសី ប្រទេស ឥណ្ឌា) ។

១៣– បំណាយសម្រាប់បញ្ជូនគណៈប្រតិភូឲ្យទៅបំពេញបេសកកម្មនៅប្រទេសនានា ជាប្រយោជន៍ដល់ព្រះពុទ្ធសាសនា ។ល។

ក្រោយពីសហជីវិន ស៊ូ ណែម ប្រធាន និងសហជីវិន អ៊ុក ជី បានធ្វើសេចក្ដីរាយការណ៍ និងជូនពត៌មានអំពីប្រវត្តិ ពុ.ម ក. - ឋានៈសមាជិក សមាជិកាដល់ទីប្រជុំរួចហើយ, ព្រះគ្រូធម្មធរជិនបុត្ត អនុគណស្រុកកំពង់ត្រឡាចមានអំណរច្រើន បានថ្លែងអំណរគុណចំពោះបេសកកម្មនៃពុ.ម.ក. នេះ រួចព្រះអង្គបានថ្លែងទៅកាន់សង្ឃសន្និបាត និងពុទ្ធបរិស័ទទាំងអស់ សុំឲ្យព្រះសង្ឃជាចៅអធិការគ្រប់វត្តទាំងអស់ក្នុងស្រុកកំពង់ត្រឡាច និងពុទ្ធបរិស័ទទាំងឡាយ ចាប់អារម្មណ៍ទៅលើអង្គការ ពុ.ម.ក. នេះ ព្រោះជាអង្គការបង្កើតឡើង សម្រាប់ទ្រទ្រង់-ការពារព្រះពុទ្ធសាសនារបស់យើងទាំងអស់គ្នា ។

តមកទៀត, ក្នុងចំណោមព្រះសង្ឃជាចៅអធិការទាំងអស់ ឃើញព្រះតេជព្រះគុណ នាម ពូក ចៅអធិការវត្តត្រពាំងធរ មានព្រះកក្ត្រប៉ប្រិម ឡើងជម្រាបទីប្រជុំដោយសច្ចវាចាថា "យល់ព្រមឥតទាស់ចំពោះខ្លួនលោក ព្រមទាំងជួយគាំទ្រអង្គការ ពុ.ម.ក. នេះ ដោយសេចក្ដីជ្រះថ្លាជាអនេក" ។

ជាទីបញ្ចប់ សហជីវិន ទា ប៊ុនឡុង អគ្គហេរញ្ញិកនៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ បានថ្លែងទៅកាន់ព្រះសង្ឃប្រកបដោយគាតរោព មានជាអាទិ៍ថា គ្រប់វត្តក្នុងស្រុកឯទៀតៗ ដែលប្រតិភូនៃគណៈបេសកកម្មនេះ បានទៅដល់រួចហើយនោះ មានផ្ញើបញ្ជីរាយនាមព្រះសង្ឃ ពុទ្ធបរិស័ទចំនួនច្រើន សុំចូលជាកម្មិកសមាជិក ទៅទីចាត់ការនៃ ពុ.ម.ក. អស់ហើយ ហើយនៅក្នុងនេះ ទោះបីមានបរិយាកាសអព្ភូតបន្តិចបន្តួចក៏ដោយ ក៏ខ្ញុំព្រះករុណា ខ្ញុំបាទ មានសេចក្ដីសង្ឃឹមជានិច្ចថា: ព្រះសង្ឃជាចៅអធិការគ្រប់វត្ត ក្នុងស្រុកកំពង់ត្រឡាចទាំងមូល មុខជានឹងជួយទ្រទ្រង់ព្រះពុទ្ធសាសនា គឺអង្គការ ពុ.ម.ក. នេះ ដូចព្រះសង្ឃជាចៅអធិការ ក្នុងស្រុកឯទៀតៗជាពុំខាន ។

## ៣– អំពីប្រាក់ភាគទាន និង អំណោយ

ដូចដែលខ្ញុំព្រះករុណា ខ្ញុំបាទ បានផ្សាយប្រគេន-ជូនស្ដាប់ ជាបន្តបន្ទាប់រួចខ្លះៗមកហើយ នូវនាមសប្បុរសជនគ្រប់ប្រភេទ ដែលជាសមាជិក សមាជិកា ពុ.ម.ក. ហើយបានបង់ប្រាក់ភាគទានដល់ហិប ពុ.ម.ក. ។ ល្ងាចនេះទីចាត់ការនៃ ពុ.ម.ក. នឹងបន្តការផ្សាយរបៀបនេះតទៅទៀត

### ១– ផ្នែកភាគទាន ១ ខែ ១០ រៀល ១ ឆ្នាំ ១២០ រៀល

– បានបង់គ្រប់មួយឆ្នាំហើយ ត្រូវជា ១២០ រៀល

– សម្តេចព្រះពោធិវង្ស ហួត តាត អគ្គាធិការនៃពុទ្ធិកសិក្សា គង់នៅវត្តឧណ្ណាលោម

– ព្រះពុទ្ធឃោសាចារ្យ ភជ កឹង មេគណក្រុង – សាភវ័ន

– ព្រះសិរីសម្មតិវង្ស ប៉ុណ្ណ សុក្កាជ សាស្រ្តាចារ្យពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

– ឯ. ឧ. អ៊ុក ឆុប នៅគ្រឹះស្ថាន លេខ ៣៥ វិថីផានុវង្ស ភ្នំពេញ

– ឃួន ណៃ – លេខ ២០១ វិថីអគ្គីឌួង –

– ប៊ុន ថាន់ និងអ្នកស្រី – លេខ ២០ - ២២ វិថីសម្តេចសុធារស ភ្នំពេញ

– អ្នកស្រី សោម ស៊ុម – លេខ ១៥ – –

– លោក វ័ណ្ណ យន់ អ្នកស្រី ធឹង ស៊ុងអ៊ឹម នៅសាលាសន្សំសុខ –

– សហជីវិន គាំ មៀច – កង់ សំ – –

– ផេង ហៀង – ព្រំ ហ៊ុន – –

– ប៉ែន ឆែម – អ៊ុំ សាលីវ – –

– ឆាយ សេន – សាយ អ៊ាត – –

– គីម ស៊ុម ស្នងការនៃក្រុមអភិបាល នៃ ពុ. ម. ក. – –

– ឧបាសិកា តាំង ឈួន – –

– លន់ យឹម – –

– លោកឃុនព្រះម្នាង យិន គាត គ្រឹះស្ថាន លេខ ១៦ វិថីព្រះយុគន្ធរ –

## ២– ផ្នែកអំណោយ : មួយខែ ១០០ រៀល មួយឆ្នាំត្រូវជា ១.២០០ រៀល
## បានបង់ ៥ ខែហើយ ត្រូវជា ៥០០ រៀល

លោកស្រី តាន់ ឈុនហ៊ាង គ្រឹះស្ថាន លេខ ៣៩ វិថីព្រះមុនីវង្ស ភ្នំពេញ

– សួ ធុំ – ១៩៥ – ព្រះនរោត្តម –

– វ័ណ្ណ ធំ – ១៤ – សម្តេចទៀង –

– ប៊ុណ្ណ ចន្ទបួរ៉ា – ២ – សម្តេចសុធារស –

ចំណែកលោកស្រី គីម ហួតហេង មួយខែ ២០ រៀល បានបង់គ្រប់មួយឆ្នាំហើយ ២៤០ រៀល

“គ្រឹះស្ថានលេខ ១៨ វិថីសម្តេចសុធារស ភ្នំពេញ” ។

**៣– មួយឆ្នាំ៥០រៀល :** តាមរយៈផ្ទាល់នៃទីចាត់ការពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ សប្បុរសជនដូចមានរាយនាមខាងក្រោមនេះ មានទីលំនៅ នៅសង្កាត់លាប ស្រុកកំពង់ត្រាញ ខេត្តពោធិ៍សាត់ បានធ្វើអំណោយប្រចាំឆ្នាំ ៥០ រៀល ក្នុងមួយរូបៗ គឺ :

– លោកអាចារ្យ ប៉ែន ផា ឧបាសិកា ស៊ិន នៅ

– លោក – ញ៉ឹក ជ្រាំ – លឿង

– លោកអាចារ្យ ប៉ែន គោគ – ង៉ែត សាត

– លោកអាចារ្យ ផឹង ហេង – រស់ សរ

– ភិក្ខុ ស៊ឹម សំឌុ

– ថង ប៊ុនថាន់

– ហ៊ួន សារ៉ែន

លោកអាចារ្យ កែប ពៅ ឧបាសិកា ស៊ួង

ឧបាសក ម៉ា ខឹម

ឧបាសិកា ទេស ចក់ ។

សូមស្ទះត្រឹមណេះសិន នៅពេលក្រោយនឹងមានផ្សាយបន្តទៅទៀត ។

គណៈកម្មាធិការនាយកនៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ មានសេចក្តីសង្ឃឹមថា នឹងមានវត្ត - ព្រះសង្ឃ - ពុទ្ធបរិស័ទជាច្រើន វត្ត - អង្គ - រូបទៀត សុំចុះឈ្មោះចូលជាសមាជិក សមាជិកា ពុ.ម.ក. ដើម្បីជួយទ្រទ្រង់ព្រះពុទ្ធសាសនា ទ្រទ្រង់សំឡេងអង្គការ ពុ.ម.ក. របស់យើងទាំងអស់គ្នា ឲ្យមានវឌ្ឍនភាពរីកសាយពេញពិភពលោក ។

សូមព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ អស់លោក - អ្នកនាងជាទីមេត្រីទាំងឡាយ បានប្រកបដោយ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ សមតាមប្រាថ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សំឡេងពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ សូមបន្ទន់កាយគោរពលាព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ អស់លោក - អ្នកនាងជាទីមេត្រីទាំងឡាយ ត្រឹមនាទីនេះសិន សូមរង់ចាំស្តាប់នាទីរបស់យើងនេះ នៅថ្ងៃព្រហស្បតិ៍ ខែបឋមាសាឍ ត្រូវនឹងថ្ងៃទី ២៩ - ៦ - ៦៧ នៅពេលម៉ោងដដែល ។

សូមអរព្រះគុណ សូមអរគុណ

## តម្លៃជាវ

| | |
|---|---|
| ១ ក្បាល | ២៥៛០០ |
| ប្រចាំឆ្នាំ | ៩០៛០០ |

ផ្ញើអាណត្តិប្រៃសណីយ៍ទៅ ៖

លោក **ធា - ប៊ុនឡុង** អគ្គហេរញ្ញិកនៃពុទ្ធិកសមាគម-កម្ពុជរដ្ឋ នៅវត្តឧណ្ណាលោម ភ្នំពេញ ។

**Monsieur TEA - BOUN LONG Trésorier Général de l'Association des Bouddhistes au monastère d'Unnalom à PHNOM-PENH.**

IMPRIMERIE HENR